# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣២ លេខ ៩ ខែកញ្ញា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា នឹងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

---

## បញ្ជីរឿង

ផ្នែកសាសនា — ទំព័រ

- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . . ៩៦១
- គោលព្រះនិព្វាន ព្រះឧបាលិវង្ស សួរ-ហាយ រៀបរៀង . . . ៩៨១
- ព្រះអភិធម្មបិដក (គម្ពីរកថាវត្ថុ) (តមក) លោក ប៊ូ-ប៊ូ រៀបរៀង . ៩៩៩
- មធុរសវាហិណី (តមក) សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង . ១០០៨
- មហោសថជាតក (តមក) លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-តួរ ពិនិត្យ . . . . . . ១០១៣

ផ្នែកអក្សរសាស្ត្រ

- រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . ១០២៣
- រឿងព្រេងប្រទេសអារ៉ាប់ ភិក្ខុ ម៉ែន-រៀម ប្រែពីភាសាអង់គ្លេស . . . ១០៤២
- រឿងព្រេងនឹងរឿងបុរាណជប៉ុនក្នុងមធ្យមសម័យ(តមក)លោក វ៉ាយ-ប៊ុក ប្រែរៀបរៀង១០៥១
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . . ១០៦១
- ពាក្យវប្បធម៌ លោក នាង-ហ៊ួ រៀបរៀង លោក សខ-ចាំង ពិនិត្យ . ១០៦៩

ផ្នែកកំណត់ខនិប្រវត្តិការណ៍

- ពត៌មានផ្សេង ៗ របស់ក្រសួងធម្មការ . . . . . . . ១០៧៦
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . ១០៧៨

---

មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជាវ ២៣០រ០០

# KAMBUJASURIYA

Revue mensuelle de Culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom Penh

## sommaire

### Partie religieuse :

— La Vie du Buddha (suite) par Prah maha PANG-KHAT . . . 961
— Le Nirvana par le Vén. SOR-HAY. . . . . . . . 981
— Prah Abhidhammapitaka (Kathavathu) (suite) par M. BOU-PO 999
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM, revu et corrigé par le Vén. NHEAN-CHHOEUN . . . . . . . . . . 1008
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu par le Vén-KEM-TO 1017

### Partie littéraire :

— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . 1027
— Contes et Légendes arabes traduits par Bhikhhu MEN-REAM 1042
— Contes et Légendes du Japon au Moyen-Age (suite) traduits par M. RAY-BUC . . . . . . . . 1051
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1061
— Activités de la Commission Culturelle par M. NEANG HOU revues par M. SAM-THANG. . . . 1069

### Notes et Chroniques :

— Nouvelles diverses du Ministère des Cultes . . . . . . . . 1076
— Dictionnaire Sanscrit-khmer (suite) par le Vén. PANG-KHAT 1078

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

## ផ្នែកសាសនា

### ពុទ្ធជីវប្បវត្តិ

(តមក)

ព្រះមហា ប៉ាន់-ខាត់ រៀបរៀង

# អវិទូរេនិទាន មហាភិនិក្ខមនកថាទី ៥

១-ទ្រង់ប្រពាតឧទ្យាន, ២-ទ្រង់ទតឃើញទេវទូត៣ខាងដើម, ៣- ទ្រង់ទតឃើញទេវទូតទី៤, ៤- កាលកំពុងប្រពាតឧទ្យាន, ៥. ព្រះរាហុលកុមារប្រសូត, ៦- ពោធិសត្វកើតសង្វេគ ៧- ទ្រង់រូបស្រឡះបាកកាម, ៨- ទ្រង់មានតម្រិះក្នុងផ្នួស, ៩-ពោធិសត្វស្ដេចចេញសាងមហាភិនេស្ក្រមណ៍. ១០ ទ្រង់កាន់យកឧត្តមភេទ ។

---

ឆ្លើយចំណោទយ៉ាងធ្ងរឥតទើសទាល់អ្វីសោះ, គេយកធ្នូមកថ្វាយព្រះពោធិសត្វៗ ចាប់យឹតបាញ់បាត់អស់ ទើបព្រះបាទសុទ្ធោទនៈ ត្រាស់ឲ្យយកធ្នូបុរាណ ( សហស្សថាមធនុ ) ពោធិសត្វលើកឡើងបាញ់យ៉ាងស្រួល កូនសរទៅមុតដើមឈើធ្នុះហើយលិចទៅក្នុងផែនដី ត្រង់ទីនេះ គេឲ្យឈ្មោះថាអណ្ដូងកូនសរ, ទេវទត្តប្រណែនជាល់ដំរី ១ ដៃស្លាប់, ពោធិសត្វយកព្រះហស្តទៅពាល់ដំរីនោះៗងើបឡើងហើយនមស្ការព្រះពោធិសត្វ ។ ឯឈ្មោះអគ្គមហេសីព្រះពោធិសត្វនេះ មានប្លែកច្រើនទៅទៀត, ក្នុងគម្ពីរយើងជាច្រើនរកថាឈ្មោះ យសោធរា ជាបុត្រីព្រះបាទសុប្បពុទ្ធ នឹងនាងអមិតា, ឈ្មោះរាហុលមាតា ឬ ពិម្ពា ឈ្មោះទាំង៣ នេះដូចគ្នាទេគម្ពីរលលិតវិស្ដារៈមហាយានថា ឈ្មោះគោបា ជាបុត្រីសក្យទណ្ឌបាណិ ។ ទណ្ឌបាណិ កាលប្រឡងធ្នូបាននាំយកនាងគោបាទៅផងដែរ ហើយនិយាយថា អ្នកណាមានជ័យជំនះនឹងលើកនាងគោបាឲ្យដល់អ្នកនោះ(នេះតាមទំនៀមប្រពៃណីល្បែងសម័យនោះ) ។ គម្ពីរមហាវស្តុថាអគ្គមហេសីព្រះពោធិសត្វឈ្មោះនាងយសោធរា ដែរ តែជាបុត្រីមហានាម, តាមសិលាចារឹកផ្សេងៗ ខាងឧត្តរឥណ្ឌាថា ព្រះពោធិសត្វមានអគ្គមហេសី ៣ អង្គគឺនាង គោបា១ ឥតបុត្រ, នាងយសោធរា១ ជារាហុលមាតា និងនាងម្រគា ។

## ១- ទ្រង់ប្រពាតឧទ្យាន

ថ្ងៃមួយ ព្រះមហាពោធិសត្វទ្រង់ព្រះសណ្ដាប់ពាក្យគេដំណាលថ្វាយថានៅក្នុងមណ្ឌលឧទ្យាន មានរុក្ខលតាជាតិដុះលូតលាស់សន្ធឹកខៀវខ្ចី មានឮមាត់សត្វបក្សីយាសយំពិរោះរងំអឺងអាប់ ឯស្រះបោក្ខរណីពេញដោយផ្កាឈូកកុមុទឧត្បល មានផ្ការីកស្គុះស្គាយរំលេចពណ៌ផ្លាស់គ្នា ពោលក្លិនក្រអូបឈ្ងុយឈ្ងប់ កាលនោះស្ដេចទ្រង់នឹកក្នុងព្រះទ័យចង់ទៅប្រពាតឧទ្យាន ទើបស្ដេចត្រាស់បង្គាប់ឲ្យសារថីរៀបចំព្រះរាជរថក្បួន ព្រះរាជដំណើរ(១) សារថីទទួលព្រះរាជបង្គាប់ហើយ ក៏រៀបតាក់តែងព្រះរាជរថដ៏វិចិត្រ ទឹមដោយសេះសិន្ធវៈ ៤ មានពណ៌ដូចស្លឹកកុមុទវរជាតិ រៀបស្រេចហើយ ចូលទៅក្រាបបង្គំអញ្ជើញស្ដេច ។ ព្រះមហាពោធិសត្វស្ដេចឡើងលើព្រះទីនាំងមណ្ឌលរាជរថ ហែហមដោយរាជបរិពារចេញពីព្រះនគរឆ្ពោះព្រះភក្ត្រទៅកាន់ឧទ្យានប្រទេស ជាទីកំសាន្តព្រះទ័យ ។

## ២- ទ្រង់ទតឃើញទេវទូតបីខាងដើម

កាលនោះ ពួកទេវតាដឹងថា ព្រះសិទ្ធត្ថកុមារស្ដេចដល់ពេលនឹង

១- គម្ពីរលលិតវិស្តារៈនិងពុទ្ធចរិតអស្វឃោសៈថា ព្រះពោធិសត្វទៅសូមអនុញ្ញាតអំពីព្រះវររាជបិតា ។ ទ្រង់មិនប្រកែកឃាត់ ខ្លាចខាស់ព្រះទ័យព្រះរាជបុត្រ ទើបបានបង្គាប់ឲ្យរៀបតាក់តែងថ្នល់ ឲ្យដេញមនុស្សពិកលពិការ អ្នកកំសត់ទុគ៌តចេញពីផ្លូវ ដើម្បីកុំឲ្យពោធិសត្វស្ដេចទតឃើញ ។

ត្រាស់ដឹងជាព្រះពុទ្ធហើយ គិតគ្នាថានឹងសំដែងនូវបុព្វនិមិត្តថ្វាយ ទើបបង្គាប់ទេវបុត្រមួយអង្គឲ្យនិមិត្តជាមនុស្សជរា ធ្មេញបាក់គ្រហូប សក់ស្កូវព្រោង ខ្នងកោងកុក កាយរតឹមរតាមដោយឆ្អឹងជំនីរដូចជាបង្កន់ ដៃកាន់ឈើច្រត់ញ័រទទ្រើក ៗ ដើរមកកាន់មគ្គវិថី មានអាការមុខគួរឲ្យសង្វេគពេក ពេលនោះ ព្រះបរមពោធិសត្វនិងសារថីបានឃើញនូវមនុស្សជរានោះ ឯអ្នកដទៃមិនបានឃើញមនុស្សជរានោះទេ ដោយទេវានុភាព ព្រះបរមពោធិសត្វ និមិត្តតែបានទតឃើញមនុស្សជរានោះហើយ ទើបស្តេចត្រាស់សួរសារថីថា នែសារថី! ហ្ន៎ មើលមនុស្សនុ៎ះដែលមានសក់ស្កូវព្រោង ខ្នងកោង សាច់យុរយារ ឃើញតែគ្រោងឆ្អឹងរគីង ដៃកាន់ឈើច្រត់ទប់ខ្លួនញ័រទទ្រើក ភ្នែកខូងរូងជ្រៅគ្រប់ដោយរោមចិញ្ចើម មនុស្សប្លែកនេះជាធម្មតាប្រក្រតីគ្នាទេឬដូចម្តេច? ពេលនោះទេវតាដែលជ្រកចូលក្នុងកាយសារថី នាំសារថីឲ្យក្រាបទូលដោយពាក្យសត្យថា មនុស្សនេះ កាលពីដើមនៅក្មេង ប៉ៅទឹកដោះ ហើយក៏ចំរើនធំឡើងជាលំដាប់ ចេះវារ ចេះដើរ ទៅជាមនុស្សកំលោះ មានរូបស័ក្តិសមតទៅទៀត ដល់នូវជរាភាព ជរានេះជាសត្រូវមេបំផ្លិចបំផ្លាញកំឡាំងសតិបញ្ញា ជាមេកំណើតឲ្យកើតសេចក្តីសោកស្តាយយំសង្រេងសង្រៃ ៗ ព្រះពោធិសត្វ ទ្រង់ព្រះសណ្តាប់ពាក្យសារថីក្រាបទូលដូច្នោះហើយ ក៏ញាប់ញ័រចំប្រប់ក្នុងព្រះទ័យ ទើបស្តេចត្រាស់សួរសារថីតទៅទៀតថា

ទោសនេះ ទីងមានដល់អាត្មាអញដែរឬដូចម្តេច ? សារថីក្រាបទូលថា ទោសនេះនឹងមានដល់ព្រះអង្គដែរ លុះកាលណាទ្រង់មានវ័យចំរើនធំឡើង ឬទ្រង់មានវ័យចំរើនច្រើនជ្រុលទៅមុខ ឯសត្វលោក បើទុកជាដឹងថា ជរានេះជាអ្នកបំផ្លាញនូវរូបដូច្នេះ ក៏នៅតែប្រាថ្នាពេញចិត្ត ។ ព្រះពោធិសត្វទ្រង់ព្រះសណ្តាប់ពាក្យថា ជរាៗដូច្នេះ ក៏ស្លុតព្រះទ័យដូចជាមេគោព្ទូវសម្លេងរន្ទះដ៏គឹកកងយ៉ាងខ្លាំង ទ្រង់ដកដង្ហើមធំវែង ១ គ្រវីព្រះសិរបែបដូចជាមានភ័យធំណាស់ ជ្រប់ស្ងួតស្ងប់ព្រះភ័ក្ត្រ ទ្រង់ទតតម្រង់ឆ្ពោះទៅមនុស្សជរានោះ ហើយឃើញមានប្រជាជនដទៃទៀត នៅមានសេចក្តីរីករាយ ទើបទ្រង់ត្រាស់ដោយសង្វេគថា ជរានេះ សម្លាប់បំផ្លាញនូវស្មារតីផង នូវរូបផង នូវសេចក្តីប្រឹងប្រែងផង ឥតសេសសល់ទេ សត្វលោកពុំឃើញអំណាចជរាប្រាកដជាក់ច្បាស់ដូច្នេះទេ បានជាមិនមានសេចក្តីស្លុត , នែសារថី! កាលបើដូច្នេះ អ្នកចូលញ៉ាំងរេះឲ្យត្រឡប់ទៅផ្ទះវិញឆាប់ ៗ ព្រោះចិត្តអាត្មាអញកំពុងជាប់ជានិច្ចក្នុងពាក្យថាជរា ៗ សេចក្តីរីករាយនឹងមានក្នុងទេហក្ខមដូចម្តេចកើត? ព្រះពោធិសត្វស្តេចមានតម្រិះស្ញូនទៅក្នុងជរា ស្តេចយាងចូលទៅកាន់ព្រះរាជវាំងហាក់ដូចជាចូលទៅកាន់ទីសូន្យទទេ, ម្យ៉ាងទៀត កាលដែលព្រះអង្គកំពុងតែរំពឹងគិតថាជរា ៗ ដូច្នេះ ទ្រង់មិនបានសុខស្រួលក្នុងព្រះទ័យសោះ ។ ព្រះវររាជបិតាស្តេចជ្រាបដំណឹងនេះ ស្តេចត្រាស់បង្គាប់ឲ្យពួកស្រីស្នំក្រម

ការតាក់តែងកាយដោយគ្រឿងអលង្ការដ៏វិចិត្រមកប្រលោមពោធិសត្វ ដោយឆាប់រួសរាន់[១] ។ លើកទី ២ ស្តេចទតឃើញមនុស្សព្យាធិ, លើកទី ៣ ទ្រង់ទតឃើញមនុស្សស្លាប់ ។

## ៣–ទ្រង់ទតឃើញទេវទូតទី ៤

ថ្ងៃមួយតមកទៀត ព្រះមហាបុរសរត្ន ប្រថាប់លើព្រះរាជរថ ទឹមដោយសេះសិន្ធព ៤ ចេញទៅប្រពាតឧទ្យានលើកទី ៤ ព្រះវររាជបិតា ទ្រង់បាត់ការឲ្យអ្នកគ្រួតត្រាផ្លូវថែរក្សាគ្រប់ទិសប្រយ័ត្នក្រៃលែង ជាងលើកទី ៣ ទៅទៀត, ដងនោះ ស្តេចទតឃើញរូបបុរសម្នាក់ មានភេទជាសមណៈ ស្លៀកដណ្តប់សម្ពត់កាសាវពស្ត្រ មានឥន្ទ្រិយស្រគត់ស្រគំ គួរឲ្យកើតសេចក្តីជ្រះថ្លា ជារូបដែលទេពតាជាន់សុទ្ធាវាសដែលនោះមកនិម្មិតថ្វាយ ដើរមកកាន់មគ្គវិថីនៃព្រះរាជដំណើរ, ទ្រង់សួរសារថីថា ម្នាលសម្លាញ់! មនុស្សនោះឈ្មោះអ្វី? គ្រានោះជាសម័យមុនពុទ្ធកាល សារថីក៏មិនស្គាល់ភេទបព្វជិត ហើយមិនដឹងជាបព្វជិតមានគុណដូចម្តេចផង តែដោយអំណាចទេវានុភាពដែលជ្រែកចូលក្នុងកាយ នាំសារថីឲ្យ

---

១- សេចក្តីត្រង់ពោធិសត្វប្រពាតឧទ្យានហើយទតឃើញទេវទូតទាំង ៤ នេះ មានសេចក្តីពិស្តារត្រង់លើកទី ១ នឹងលើកទី ៤ ឯលើកទី ២ នឹងទី ៣ មិនមានពិស្តារទេ ព្រោះតែនិយាយថាពោធិសត្វ ស្តេចចេញទៅទៀតលើកទី ២ ឃើញមនុស្សព្យាធិ, លើកទី ៣ ឃើញមនុស្សស្លាប់ ។ ក្នុងគម្ពីរពុទ្ធចរិតអស្សឃោសៈមានសេចក្តីពិស្តារពីរោះគួរជាប់ចិត្តគ្រប់ទាំង៤លើក។ក្នុងអវិទូរេនិទាន ឯកនិបាតវណ្ណនា បឋមភាគថា ឃើញទេវទូតទាំង ៤ នេះ តែក្នុងមួយថ្ងៃ ។

ក្រាបទូលដោយពាក្យសត្យថា បពិត្រព្រះសម្មតិទេព! មនុស្សនេះឈ្មោះបព្វជិត ហើយពណ៌នារឿងបព្វជិតដោយអនេកបរិយាយ ។ ព្រះពោធិសត្វទ្រង់ព្រះសណ្ដាប់ហើយ ពេញព្រះទ័យនឹងភេទបព្វជិត ទ្រង់ព្រះតម្រិះថា ការប្រព្រឹត្តជាសមណៈភេទនេះ ជាកុសលដ៏ប្រសើរណាស់ គួរអាត្មាអញកំណត់កាន់យកឧត្ដមភេទនេះ, ថ្ងៃនោះ ព្រះពោធិសត្វស្ដេចហួសទៅកាន់ឧទ្យានប្រទេស ដើម្បីកំសាន្តព្រះទ័យ ។

## ៤- កាលទ្រង់ប្រពាតឧទ្យាន

ពួកស្ត្រីស្នំក្រមការមានរូបល្អប្រិមប្រិយ ហាក់ដូចស្ត្រីទេពអប្សរបវរកញ្ញា ប្រដាប់ដោយសំពត់កោសេយ្យពស្ត្រ រំលេចពណ៌ប្រាលផ្អៅ នឹងភ្ញីផ្កា ព្រមទាំងកម្រងគ្រឿងក្រអូបគ្រឿងលាប គួរឲ្យកើតសេចក្ដីរីករាយសាទរក្រៃលែង បបួលគ្នាស្រូចូលទៅហែហមព្រះពោធិសត្វ ប្រៀនកំលួនលោមប្រលោមបំរើដោយកាមគុណ ។ ព្រះពោធិសត្វស្ដេចប្រពាតឧទ្យានជាទីរមណីយដ្ឋានកំសាន្តព្រះទ័យ គ្រប់ទីកំបន់ ស្ដេចទតឃើញភូមិឋានមានរុក្ខជាតិលូតលាស់លំពង់សទ្រឹករទៀរទ្រី មានផ្កាបោលក្លិនក្រអូបឈ្ងុយឈ្ងប់, នឹងគន់មើលឯសត្វសកុណាបក្សាសោត កំយាសយំពីរោះរងំដូចស័ព្ទតូរ្យតន្ត្រី ឯស្រះបោក្ខរណីក៏ប្រដាប់ដោយបញ្ចបទុមជាតិកុមុទឧត្បលលំបង់សត្តបង្កជ បោលក្លិនខ្ចរទៅទាំងសកលឧទ្យានប្រទេស ។ ព្រះពោធិសត្វ

ស្តេចប្រពាតអស់ទិវសភាគសម័យទៀបសាយ័ណ្ហហើយ ទ្រង់ហែហមដោយអនេកនិករសុរង្គនាង ចុះស្រង់ជម្រះព្រះកាយក្នុងស្រះបោក្ខរណី លុះទិវាករអស្តង្គត ទើបស្តេចបទចរចាកមង្គលស្រះ ទ្រង់និសីទនាការលើផែនថ្មសិលាអាសន៍ ទ្រង់មានបំណងចង់ព័ទ្ធព្រះសិរ្សដោយគ្រឿងរាជវិភូសនាលង្ការ ពួកស្រីស្នំក្រមការរាជបរិពារ មានខ្មាន់ព្រះកេសជាដើម អញ្ជើញគ្រឿងប្រដាប់គីវាលង្ការ នឹងគ្រឿងប្រស់ព្រំមកថ្វាយ ។

ខណៈនោះ ក្តៅដល់អាសនៈអមរិន្ទ្រាធិរាជ ស្តេចបើកទិព្វចក្ខុក្រឡេកមកឃើញដូច្នោះ ទ្រង់ត្រាស់បង្គាប់វិស្សកម្មទេវបុត្រថា ហៃសម្លាញ់! ក្នុងពាក់កណ្តាលអធ្រាត្រយប់នេះ ព្រះសិទ្ធត្ថកុមារ ស្តេចនឹងចេញសាងមហាភិនេស្ក្រមណ៍, ពេលនេះ ជាបច្ឆិមាលង្ការនៃព្រះមហាបុរស ចូរអ្នកទៅប្រដាប់ថ្វាយព្រះមហាបុរសត្នឥឡូវនេះ ។ វិស្សកម្មទេវបុត្រយកភេទខ្លួនជាខ្មាន់ព្រះកេស ចាប់វេឋនពស្ត្រអំពីដៃមនុស្សមកព័ទ្ធព្រះសិរ្សថ្វាយ រួចប្រដាប់ដោយបិលន្ធនាភរណៈល្អដូចមហាព្រហ្ម ។ ព្រះពោធិសត្វស្តេចឡើងកាន់ព្រះរាជរថនិវត្តចាកឧទ្យានប្រទេស ហែហមដោយពួកពលសកលយោធានឹងពួកអនេកបរិពារខត្តិយកញ្ញា ។

## ៥– ព្រះរាហុលកុមារប្រសូត

គ្រានោះ ព្រះនាងពិម្ពាប្រសូតរាហុលកុមារ, ព្រះបាទសុទ្ធោទនៈ

ទ្រង់ជ្រាបដូច្នោះ ទើបត្រាស់ឲ្យប្រើរាជបុរសម្នាក់នាំសារទៅក្រាបទូលព្រះបរមពោធិសត្វ, ឯព្រះបរមពោធិសត្វ ទ្រង់សណ្ដាប់ពាក្យនេះហើយ ទ្រង់មានព្រះបន្ទូលថា ទុករាហូចាប់អញហើយតើ! ចំណងកើតហើយតើ! ។ ឯព្រះបាទសុទ្ធោទនៈត្រាស់សួររាជបុរសថា កូនអាត្មាអញនិយាយដូចម្ដេចខ្លះ? រាជបុរសក៏ក្រាបទូលតាមពាក្យៈពោធិសត្វ ហើយទ្រង់ថ្វាយព្រះនាមព្រះរាជនត្តាថា "រាហុលកុមារ(១)" ។ ចំណែកខាងព្រះបរមពោធិសត្វស្ថិតលើរាជរថ ហែហមដោយរាជបរិពារ ស្ដេចច្តោះព្រះក៏ត្រៃទៅកាន់ព្រះរាជនគរ ដល់ហើយ ប្រទក្សិណប្រាង្គប្រាសាទរាជនិវេសន៍ ៣ ជុំ, កាលនោះ ព្រះនាងខត្តិយកញ្ញាមួយព្រះអង្គ ព្រះនាមកីសាគោតមី ស្ដេចប្រថាប់ទៀបសីហបញ្ជរព្រដ៏ភូមិតលដ្ឋាននៃប្រាសាទ បានទតឃើញព្រះមហាបុរសត្ថសោភាដោយរូបសម្បត្តិ ក៏មានព្រះទ័យត្រេកអរសោមនស្ស ទើបត្រាស់សរសើរដោយបទគាថាដូច្នេះ ៖

និព្វុតា នូន សា មាតា និព្វុតោ នូន សោ បិតា
និព្វុតា នូន សា នារី យស្សាយំ ឦទិសោ បតិ ។

ព្រះអង្គីរសកុមារ មានរូបសម្បត្តិល្អប្រាកដដូច្នេះ បើព្រះអង្គជាព្រះរាជបុត្រព្រះមាតាអង្គណា ព្រះមាតាអង្គនោះក៏នឹងអាចរំលត់ទុក្ខបាន, បើ

១- រាហុល < រាហុ + ល = រាហូចាប់ ។

ព្រះអង្គជាព្រះរាជបុត្រព្រះបិតាអង្គណា ព្រះបិតាអង្គនោះក៏នឹងអាចរំលត់ទុក្ខបាន, បើព្រះអង្គជាព្រះភស្ដានៃនាងរាជនារីអង្គណា ព្រះនាងរាជនារីអង្គនោះក៏នឹងអាចរំលត់ទុក្ខបាន ។

កាលព្រះបរមពោធិសត្វ ទ្រង់ព្រះសណ្ដាប់ពាក្យនេះហើយ ទើបទ្រង់ព្រះចិន្ដាថា ព្រះនាងនេះ ទតឃើញនូវរូបសិរីសម្បត្តិនៃអាត្មាអញហើយពោលថា អាចនឹងរំលត់នូវទុក្ខនៃមាតាបិតានឹងភរិយាបានដូច្នេះ ឲក្នុងកាលណាហ៎ា ទើបអាត្មាអញនឹងរំលត់ទុក្ខនេះបាន? ទ្រង់ពិចារណាដោយព្រះប្រាជ្ញាញាណ ដែលប្រាសចាកសេចក្ដីត្រេកអរក្នុងកិលេស-កាមគុណហើយ ទ្រង់ទតឃើញប្រចក្សថា កាលណា បើភ្លើងគឺរាគគ្គិទោសគ្គិ មោហគ្គិជាដើមរលត់សូន្យហើយ កាលនោះ ទើបឈ្មោះថាទុក្ខនោះរលត់សូន្យអន្ដរធានអស់ទៅវិញពិត, ព្រះនាងនោះពោលនូវពាក្យដ៏ពីរោះឲ្យអាត្មាអញស្ដាប់ បើដូច្នេះ អាត្មាអញនឹងប្រព្រឹត្តស្វែងរកនូវធម៌គឺព្រះនិព្វានក្នុងថ្ងៃនេះ, អាត្មាអញគួរនឹងធ្វើគ្រឿងសក្ការបូជាស្នងព្រះនាងអង្គនេះទើបគួរ ហើយទ្រង់ដោះនូវគ្រឿងប្រដាប់ពីព្រះសុរង្គដ៏វិចិត្រដោយកែវមុក្ដាមានតម្លៃមួយសែនកហាបណៈ ឲ្យរាជបុរសនាំយកទៅថ្វាយព្រះនាងកីសាគោតមី ។ ព្រះនាងយល់ថា ព្រះសិទ្ធត្ថកុមារមានព្រះទ័យប្រតិព័ទ្ធស្នេហាចំពោះខ្លួន ក៏ទទួលគ្រឿងបណ្ណាការនោះ

ដោយបីតិសោមនស្សយ៉ាងក្រៃលែង ។ ព្រះបរមពោធិសត្វប្រកបដោយសិរីជ័យឧត្តម ស្តេចឡើងកាន់មហាប្រាសាទ ផ្ទំលើទែនទិព្វសេយ្យាសន៍ រុងរឿងដោយពន្លឺប្រទីបផ្កាលាក្តីក្រោងក្រាតទូទៅ តាំងថ្ងៃព្រះរាជនិវេសនដ្ឋាន , ពួកខត្តិយកញ្ញាប្រដាប់កាយដោយគ្រឿងអលង្ការដ៏វិចិត្រ មានរូបឆោមលោមពណ៌សក្តិសម សុទ្ធសឹងល្អៗដូចស្រីទេពអប្សរបវរកញ្ញា ប្រគំដេញដំពិណពាទ្យតូរ្យតន្ត្រី ច្រៀងកំព្ស្វរស័ព្ទសំឡេងពីរោះរងំមុខគួររីករាយសប្បាយក្រៃលែង បបួលគ្នាប្រលោមព្រះពោធិសត្វឲ្យស្តេចត្រេកអរក្រសាលក្នុងបញ្ចពិធកាមគុណ ។

## ៦_ពោធិសត្វកើតសង្វេគ

ព្រះពោធិសត្វគ្រាន់តែធៀងព្រះនេត្រទតមហោស្រព ផ្ទៀងព្រះសោតស្តាប់ចម្រៀងបន្តិច ក៏ទ្រង់និទ្រាលក់ទៅ, ឯពួកនាដកិត្តស្ត្រីបាំឃើញព្រះបរមពោធិសត្វស្តេចផ្ទំលក់ដូច្នោះ ក៏បបួលគ្នាដេកលន់លក់អស់ទៅ ។ លំដាប់នោះ ព្រះពោធិសត្វស្តេចទ្រង់តើនឡើង ទតព្រះនេត្រឃើញពួកស្រីខត្តិយកញ្ញាដេកលក់មានអាការៈផ្សេងៗគួរឲ្យសង្វេគដោយទេវានុភាពបណ្ដាល ស្ត្រីខ្លះ ដេកពោលគ្រឿងប្រដាប់តូរ្យតន្ត្រី ស្ត្រីខ្លះទៀតអាក្រាតសំលៀកបំពាក់ហៀរហូរទឹកមាត់ត្រដាក់ សង្កៀតធ្មេញស្រមុកខ្ញូរមុខគួរខ្លាច មានដៃជើងបត់បែនប្រេងប្រង៉ាង ពព័ទ្ធព័ន្ធគងគាក់

លើគ្នា មានអាការដូចជាសាកសពប្រេតប្រផាំងដែលគេចោលក្នុងព្រៃស្មសានឋានស្ងាត់គួរឲ្យខ្លាចរអើមក្រៃពេក, សូម្បីផ្ទៃមហាប្រាសាទ ដែលតាក់តែងវិចិត្រដោយប្រទីបផ្កាលា ដុតដោយប្រេងក្រអូប ផ្សាយក្លិនសុគន្ធពិដោរឈ្ងុយឈ្ងប់ក្លឹក្រោនក្រាយ ពេលស្មើប៉ះទៅចាប់កំរងផ្កា លេចពណ៌ល្អស្រស់ទូទាំងផ្ទៃប្រាសាទល្អដូចលំនៅអមរិន្ទ្រាធិរាជក៏ដោយ ព្រះពោធិសត្វមានព្រះទ័យតក់ស្លុតរន្ធត់ ហាក់ដូចជាទ្រង់ប្រថាប់នៅកណ្ដាលទ្រុងព្រៃស្មសានឋានស្ងាត់ ដែលពាសពេញដោយខ្មោចស្រស់ មានក្លិនអសោចិក្រៃពេក, ភពទាំង ៣ ក៏ប្រាកដហាក់ដូចជាគេហដ្ឋាន ដែលភ្លើងកំពុងឆេះសន្ធោសន្ធៅ, ទ្រង់នឿយណាយបាកកាមគុណ ទើបទ្រង់លាន់ព្រះឱស្ឋត្រាស់ថា « ឧបទ្ទុតំ វត ភោ! ឧបសដ្ឋំ វត ភោ! អើឧបទ្រពណាស់តើ! អើឧបសគ្គទើសទាស់ណាស់តើ!" ដូច្នេះ ។

## ៣-ទ្រង់រួចស្រឡះបាកកាម

ព្រះមហាបុរសនេះ ទ្រង់ពិចារណាឃើញទោសកាមដូច្នេះហើយ ទ្រង់មានព្រះតម្រិះនឹងចេញបាកកាម ដូចសេចក្ដីដែលទ្រង់ត្រាស់ចំពោះមហានាមសក្យៈថា [១] ៖

"កាលតថាគតនៅជាពោធិសត្វ មុនអំពីការត្រាស់ដឹង

១ ចូឡទុក្ខក្ខន្ធសូត្រ សីហនាទវគ្គ ម. មូ, សៀវ. ២០ ទំព័រ ៣៣៧ ។

តថាគតបានឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃថា កាម ទាំងឡាយ មានសេចក្ដីសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនុ៎ះមានច្រើនក្រៃពេក, បើតថាគត វៀរចាកកាមទាំងឡាយហើយ វៀរចាកអកុសលធម៌ទាំងឡាយហើយ តែមិនទាន់បាននូវបីតិនិងសុខៈ ឬគុណជាតិដទៃល្អិតលើសជាងបីតិនិងសុខៈនោះទេ ក៏តថាគតដឹងប្រាកដថា ត្រូវត្រឡប់មករកកាមទាំងឡាយវិញ ដោយពិត ។ លុះតថាគត បានវៀរចាកកាមទាំងឡាយហើយ បានវៀរចាកអកុសលទាំងឡាយហើយ បាននូវបីតិនិងសុខៈផងនិងគុណដទៃដែលល្អិតលើសជាងបីតិនិងសុខៈនោះផង ទើបតថាគតដឹងប្រាកដថា មិនវិលត្រឡប់ មករកកាមទាំងឡាយវិញឡើយ" ។

៨- ទ្រង់មានតម្រិះក្នុងផ្នួស

*សេចក្ដីមួយទៀតថា កាលដែលទ្រង់បានត្រាស់ដឹងហើយ ក៏ទ្រង់*

*បានត្រាស់បញ្ជាក់ទោសកាមនោះចំពោះភារទ្វាជៈថា (១)*

«ម្នាលភារទ្វាជៈ! កាលតថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ តថាគតត្រិះរិះថា ឃរាវាសចង្អៀតពេកណាស់ ជាផ្លូវនៃធូលី ឯបព្វជ្ជាទើបទំនេរ បើអាត្មាអញនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ឲ្យបរិបូណ៌ក្រៃលែង ឲ្យបរិសុទ្ធក្រៃលែង ឲ្យផូរផង់ដូចជាស័ង្ខដែលគេដុះខាត់បានឡើយ បើដូច្នោះ គួរតែអាត្មាអញកោរសក់ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈទាំងឡាយ ហើយចេញចាកផ្ទះបួសទៅកាន់ផ្នួសវិញ» ។

*ក្នុងខណៈនោះ ព្រះពោធិសត្វមានព្រះទ័យឱនទោរទន់ទៅរកសមណភេទ ទ្រង់ព្រះតម្រិះថា អាត្មាអញនឹងចេញកសាងមហាភិនេស្ក្រមណ៍ក្នុងរាត្រីនេះ, ទើបទ្រង់ក្រោកចាកព្រះទែនសេយ្យាសន៍ យាងទៅដាស់ឆន្នអាមាត្យ ។ រីឆន្នអាមាត្យ ដេកដាក់ក្បាលលើធរណីទ្វារ បានឮព្រះសូរសៀងត្រាស់សួរដូច្នោះ ក៏ក្រោកទូលថា ខ្ញុំព្រះអង្គឈ្មោះឆន្នៈ ជាអ្នកកេក្រព្រះអង្គ ។ ព្រះពោធិសត្វមានព្រះបន្ទូលថា ឆន្នៈ! អាត្មាអញ*

១-សគារវសូត្រ ព្រាហ្មណវគ្គ សៀវ. ២៥ ទំព័រ ២៦៤ ។

នឹងចេញកសាងមហាភិនេស្ក្រមណ៍ក្នុងរាត្រីនេះ អ្នកចូរទៅរៀបចំសេះមួយឲ្យយើងឆាប់ ៗ ឆន្នអាមាត្យទទួលព្រះរាជបង្គាប់ហើយ យកគ្រឿងអស្សូបករណ៍ ដើរទៅកាន់រោងសេះកណ្ឋករាជ (១) រៀបចំចងគ្រឿងអស្សកណ្ឋដ៏វិចិត្រដោយអលង្ការផ្សេង ៗ ឯព្រះពោធិសត្វ កាលទ្រង់ត្រាស់បង្គាប់ឲ្យឆន្នអាមាត្យទៅរៀបចំសេះ ស្តេចក៏មានព្រះតម្រិះថា អាត្មាអញគួរទៅមើលភក្ត្រឱរសអាត្មាអញសិន , ទើបស្តេចចងចរចូលទៅកាន់សិរីគព្ភដ្ឋាននៃព្រះនាងពិម្ពារាជទេវី ទ្រង់បើកបន្ទប់ដែលរុងរឿងដោយពន្លឺប្រទីប ទតឃើញព្រះអគ្គមហេសី ផ្ទំលក់ស្និទ្ធលើព្រះទែនសេយ្យាសន៍ យកព្រះករប្រតិស្ឋានលើព្រះសិរ្សព្រះរាជឱរសឥតដឹងព្រះអង្គ, ព្រះពោធិសត្វទ្រង់ព្រះសណ្ឋិតឈរលើធរណីទ្វារ សំឡឹងមើលព្រះរាជបុត្រនឹងព្រះរាជទេវី ហើយទ្រង់ព្រះតម្រិះថា បើអាត្មាអញលើកព្រះហស្តព្រះរាជទេវីចេញ ហើយលើកយកព្រះរាជឱរស ខ្លាចក្រែងព្រះរាជទេវីតើនចាកនិទ្រារម្មណ៍ នឹងធ្វើឲ្យអន្តរាយដំណើរចេញកសាងមហាភិនេស្ក្រមណ៍នៃអាត្មាអញមិនបាន, ណ្ហើយចុះ កាលណាបើអាត្មា

---

១ សេះកណ្ឋកៈនេះ (ប-កន្ថក,សំ កណ្ឋក) បណ្ដោយ៨ហត្ថ វាស់តាំងពីកដល់កន្ទុយ, កំពស់សមនឹងទ្រង់ទ្រាយ សម្បុរសសុទ្ធដូចសង្ខ័ដែលគេខាត់ថ្មីៗ ក្បាលខ្មៅដូចចំពុះក្អែក, ម្ខុប្រទេសដូចបណ្ដូលស្មៅយាក្នុង, មានកំឡាំងខ្លាំងក្រៃ គួរជាព្រះទីនាំងស្ដេចចក្រពត្រាធិរាជ,។

អញបានត្រាស់ដឹងជាព្រះពុទ្ធប្រាកដហើយ សឹមអាត្មាអញនឹងវិលត្រឡប់មកមើលភ័ក្ត្រកូនវិញ, ទ្រង់ព្រះតម្រិះដូច្នេះស្រេចហើយ ទើបស្ដេចចទបចុះចាកប្រាសាទទៅកាន់កណ្ឋកមនោម័យ ទ្រង់មានព្រះបន្ទូលនឹងកណ្ឋកៈថា ម្នាលកណ្ឋកៈ! អ្នកចូរចម្លងយើងឲ្យឆ្លងរួចក្នុងមួយរាត្រីនេះ យើងអាស្រ័យអ្នកជាយាន នឹងបានត្រាស់ជាព្រះពុទ្ធ ហើយចម្លងសត្វលោកព្រមទាំងទេវលោកដាក់លើថ្នល់ត្រើយត្រាណបានអមតនិព្វាន ។ កណ្ឋករាជមនោម័យ បានទទួលស្ដាប់ព្រះបន្ទូលប៉ុណ្ណោះហើយ មានចិត្តត្រេកអរក្រៃពេក បន្លឺឧរហសិតាការដំលាន់ឮគឹកកងរំពងឡើង ។

## ៩- ពោធិសត្វស្ដេចចេញសាងមហាភិនេស្ក្រមណ៍

គ្រានោះ ព្រះបរមពោធិសត្វទ្រង់សេះកណ្ឋករាជ ចេញចាករាជនិវេសន៍ក្នុងកណ្ដាលរាត្រី ដូចសេចក្ដីដែលទ្រង់មានព្រះពុទ្ធដីកាចំពោះពោធិរាជកុមារថា[១]

“ម្នាលរាជកុមារ! កាលតថាគតនៅជាពោធិសត្វនៅឡើយ មានសេចក្ដីត្រិះរិះថា សេចក្ដីសុខ បុគ្គលមិនគប្បីបានដោយសេចក្ដីសុខទេ, សេចក្ដីសុខ បុគ្គលត្រូវបានដោយសេចក្ដីទុក្ខ។

១ – ពោធិរាជកុមារសូត្រ រាជវគ្គ ម.ម. សៀវ. ២៤ ទំព័រ ៣៥៩ ។

ម្នាលរាជកុមារ ! សម័យក្រោយមក តថាគតនៅកម្លោះ មាន សក់ខ្មៅស្រិល ប្រកបដោយវ័យដ៏បំរើន គឺនៅក្នុងបឋមវ័យ នៅឡើយ កាលមាតាបិតា មិនបង់ឲ្យបួស មានមុខទទឹក ដោយទឹកភ្នែក កំពុងទ្រហ៊ុំយំ ក៏បានកោរសក់ និងពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះបួស មកបួស" ។

*សេចក្តីមួយទៀត កាលដែលព្រះអង្គជិតនឹងចូលបរិនិព្វាន ក៏ទ្រង់ បានត្រាស់ចំពោះសុភទ្ទថា* (១)

"ម្នាលសុភទ្ទ! កាលតថាគតមានវ័យ២៩ឆ្នាំបានបួសហើយ ជាអ្នកស្វែងរកនូវកុសល ។ ម្នាលសុភទ្ទ! កាលណា បើ តថាគតបួសបានជាង៥០ឆ្នាំហើយ ញុំាងប្រទេសគឺវិបស្សនាមគ្គ ឲ្យប្រព្រឹត្តទៅជាប្រក្រតី ដើម្បីធម៌ដែលគួរត្រាស់ដឹងគឺ អរិយ មគ្គ, ព្រោះហេតុនោះ (សមណៈ)ខាងក្រៅសាសនាតថាគត នេះ មិនមានឡើយ" ។

*ព្រះបរមពោធិសត្វស្តេចឡើងលើខ្នងកណ្ឋកមានោមយ័ មានឆន្ន*

---

១-មហាបរិនិព្វានសូត្រ មហាវគ្គ ទីឃ. សៀវ. ១៦ ទំព័រ ៣១៧ ។

អាមាត្យជាគ្នា ស្តេចយាងចេញទៅដល់មាត់ទ្វារ[១]ធំ ទ្រង់ព្រះតម្រិះថា បើគ្មានអ្នកណាបើកទ្វារទេ អាត្មាអញនឹងជិះលើសេះគាបឲ្យជាប់ដោយភ្លៅ ឲ្យឆន្នៈតោងពីក្រោយ ហើយនឹងលោតរំលងកំពែងកំពស់ ១៨ ហត្ថនេះ ចេញទៅខាងក្រៅឲ្យបាន ។ ឯឆន្នអាមាត្យនឹងកណ្ឋកអស្សតក៏មានគំនិត ដូចព្រះពោធិសត្វដែរ ។ ទេពតាអ្នកចាំទ្វារ ដឹងហេតុដូច្នោះហើយញាណជាចិត្ត នឹកខ្លាចដល់អាជ្ញានៃទេពតាមានសក្តិធំៗ ក៏បើកទ្វារថ្វាយ ។

កាលនោះ ជាថ្ងៃពេញបូណ៌មីខែអាសាឡ្ហ ប្រកបដោយឧត្តរាសាឡ្ហនក្ខត្តឫក្ស ព្រះចន្ទពេញវង់ភ្លឺស្រអែតទៅកណ្តាលពួកតារាករដ៏អនេក ចរលឿនលយតាមនភាល័យ ។ ព្រះពោធិសត្វស្តេចចរតាមអាកាសវិថី រុងរឿងដោយទេវនិករទាំងមុឺនលោកធាតុ ដែលធ្វើគ្រឿងសក្ការបូជាដោយផ្កាកម្រងគ្រឿងក្រអូបផ្សេងៗ ប្រគំដេញដំតូរ្យតន្ត្រីដេរដាសពាសពេញផ្ទៃអាកាស ព្រះពោធិសត្វស្តេចចេញទៅក្នុងរាត្រីមួយប៉ុណ្ណោះ ឆ្លងបាននគរ ៣ គឺនគរកបិលព័ស្តុ ១ នគរវេសាលី ១ នឹងនគរសាវត្ថី ១ ចម្ងាយ

---

១·ទ្វារធំកំពែងក្រៅនេះ គេមិនអាចបើកបានទេ ព្រោះមានកម្លះទ្វារពីរជាន់ កម្លះមួយជាន់ៗ មនុស្សមួយពាន់នាក់ទើបបើកបាន, ព្រះបាទសុទ្ធោទនៈបង្គាប់ឲ្យធ្វើដូច្នេះ ដើម្បីការពារព្រះពោធិសត្វកុំឲ្យចេញបាន, តែមានសេចក្តីថា ព្រះពោធិសត្វមានកម្លាំងខ្លាំងណាស់ បើគិតធៀបនឹងកម្លាំងដំរី ខ្លាំងស្មើនឹងដំរីមួយពាន់កោដិ, បើធៀបនឹងកម្លាំងមនុស្ស ខ្លាំងស្មើនឹងមនុស្សមួយសែនកោដិនាក់ ។

ផ្លូវ៣០ យោជន៍ ហើយស្ដេចញុំាងសេះឲ្យផ្ទោះឆ្លងស្ទឹងអនោមានទី ដែលមានទទឹង ៨ ឧសភ ទៅត្រើយខាងនាយ ប្រៀបដូចជាទ្រង់ឆ្លងឱឃសង្សារ ស្ដេចចុះចាកកណ្ឋកមនោម័យ ហើយទ្រង់និសីទនាការសណ្ឋិតលើផ្នុកខ្សាច់ ដែលមានសម្បុរដូចប្រាក់ ទ្រង់មានព្រះបន្ទូលត្រាស់បង្គាប់ឆន្នអាមាត្យថា ម្នាលឆន្នសំឡាញ់ ! អ្នកចូរនាំយកគ្រឿងអាភរណៈទាំងឡាយ ព្រមទាំងសេះសិន្ធពនេះវិលទៅនគរវិញចុះ យើងនឹងបួសក្នុងទីនេះ, មានព្រះបន្ទូលដូច្នេះហើយ ទ្រង់ដោះគ្រឿងអាភរណៈទាំងឡាយ ចេញអំពីព្រះអង្គ ហើយប្រទានទៅឆន្នអាមាត្យ ។ ឯឆន្នអាមាត្យ ក្រាបទូលសូមបួសជាមួយផង ព្រះពោធិសត្វស្ដេចមិនទ្រង់អនុញ្ញាត ហើយឆន្នអាមាត្យក៏នាំគ្រឿងអាភរណៈព្រមទាំងសេះត្រឡប់ព្រះនគរវិញ ។

## ១០-ទ្រង់កាត់យកឧត្ដមភេទ

ព្រះពោធិសត្វស្ដេចទ្រង់ព្រះចិន្ដាថា កេសាអាត្មានេះ មិនសមដល់សមណភេទទេ ទើបទ្រង់ចាប់ព្រះខ័នដោយព្រះហស្ដស្ដាំ ចាប់ព្រះកេសាដោយព្រះហស្ដឆ្វេង កាត់ព្រះកេសាដោយព្រះអង្គឯង ព្រះកេសា[១]

---

១-ព្រះកេសានៅសល់ ២ ធ្នាប់នេះ មិនលូតលាស់ទៀត សូម្បីព្រះមស្សុ ក៏ដូចគ្នា មិនបាច់កោរកាត់ទៀតទេ នៅតែប៉ុណ្ណោះរហូតដល់បរិនិព្វាន ។

ទៅសល់ក្រហែលពីរធ្នាប់ ក៏វិលជាទក្ខិណាវដ្តទាំងអស់ រួចទ្រង់ចាប់ព្រះចូឡាមូលីបោះទៅលើអាកាសផ្សងថា បើអាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ សូមឲ្យចូឡាមូលីនេះ ឋិតនៅលើអាកាស, បើមិនបានត្រាស់ទេ ឲ្យធ្លាក់មកលើផែនដីវិញចុះ ។ កាលណោះ ព្រះឥន្ទ្រាធិរាជ ទតឃើញដោយទិព្វចក្ខុហើយ យកប្រអប់កែវទៅទទួលព្រះចូឡាមូលីនោះ យកទៅប្រតិស្ឋានទុកក្នុងចូឡាមណីចេតិយ, ព្រះអដ្ឋកថាចារ្យពោលសរសើរជាបទព្រះគាថាដូច្នេះ ៖

ឆេត្វាន មោលឹ វរគន្ធវាសិតំ
វេហាសយំ ឧក្ខិបិ អគ្គបុគ្គលោ
សហស្សនេត្តោ សិរសា បដិគ្គហិ
សុវណ្ណចង្កោដវរេន វាសវោតិ

«ព្រះអគ្គបុគ្គលទ្រង់កាត់ព្រះមោលី ដែលអប់ហើយដោយគ្រឿងក្រអូបដ៏ប្រសើរ ហើយទ្រង់បោះទៅឯអាកាសវេហាស៍, ព្រះសហស្សនេត្តាវាសវៈ ស្ដេចទទួលព្រះមោលីនោះទុកក្នុងប្រអប់ជាវិការៈនៃមាសដ៏ថ្លៃថ្លាដោយសិរ្សៈខ្លួន» ។

ក្នុងលំដាប់នោះ ព្រះពោធិសត្វទ្រង់ព្រះចិន្តាតទៅទៀតថាកាសិកពស្ត្រនេះ មិនសមគួរដល់សមណភេទទេ; គ្រានោះ ឃដិការមហា-

ព្រហ្ម ជាមិត្រចាស់ព្រះអង្គក្នុងសាសនកាលព្រះពុទ្ធកស្សបៈ ដឹងហេតុដូច្នេះ ក៏គិតថា សំឡាញ់អាត្មាអញចេញសាងផ្នួសក្នុងថ្ងៃនេះហើយ បើដូច្នោះ គួរតែអាត្មាអញនឹងយកគ្រឿងសមណបរិក្ខារ(១) ទៅថ្វាយសំឡាញ់នេះ, គិតដូច្នេះហើយ ក៏នាំយកគ្រឿងបរិក្ខារ ៨ ទៅថ្វាយព្រះពោធិសត្វ ដូចមានបទព្រះគាថាដែលលោកអ្នកប្រាជ្ញបានចងទុកជាគាថាពន្ធដូច្នេះ ៈ

តិចីវរញ្ច បត្តោ ច វាសិ សូចិ ច ពន្ធនំ

បរិស្សាវនេន អដ្ឋេតេ យុត្តយោគស្ស ភិក្ខុនោ ។

"គ្រឿងបរិក្ខាររបស់ភិក្ខុ អ្នកមានព្យាយាមគួរប្រកប មាន ៨ ប្រការ គឺ ត្រៃចីវរ (ស្បង់ ចីពរ សង្ឃាដី) ១, បាត្រ១, កាំបិតកោរ១, បំពង់ម្ជុល១; កាយពន្ធន៍១, សំពត់ត្រងទឹក១," ។

ព្រះពោធិសត្វ ទទួលគ្រឿងបរិក្ខារអំពីឃដិការមហាព្រហ្មហើយ ទ្រង់ប្រដាប់ត្រៃចីវរកាសាវពស្ត្រ ជាទង់ជ័យព្រះអរហន្ត ដោយបុព្វាភិ-យោគ ដែលទ្រង់ធ្លាប់សិក្សាមកអំពីបុរេភព ជាបព្វជិតភេទឧត្តម ហើយទ្រង់ប្រគល់ព្រះភូសាទាំងគូដែលទ្រង់ជាគ្រហស្ថ ប្រទានទៅមហាព្រហ្ម។ ទទួលយកព្រះភូសានោះ ហើយថ្វាយបង្គំលា នាំយកទៅបញ្ចុះនៅក្នុងទុស្សចេតិយក្នុងព្រហ្មលោក ។

១-លលិតវិស្តារៈថា មហាព្រហ្មក្លែងខ្លួនជាព្រានព្រៃកាន់ធ្នូ ពោធិសត្វសុំដូរសំលៀកបំពាក់ព្រានព្រៃនោះ ប្រទានគ្រឿងអំពរទៅព្រានព្រៃវិញ ។ (នៅមានត)

## គោលព្រះនិព្វាន

## ព្រះឧបាលិវង្ស សូរ-ហាយ

រៀបរៀង

ព្រះនិព្វានជាគោលដៅមួយដ៏ធំបំផុតរបស់ព្រះពុទ្ធសាសនា ។ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងធម៌បញ្ញត្តិវិន័យ ប្រៀនប្រដៅសាធារណជនក្នុងកាលដែលទ្រង់បំពេញពុទ្ធកិច្ច ៤៥ ឆ្នាំ គប់តាំងអំពីថ្ងៃដែលព្រះអង្គបានត្រាស់ដឹងរហូតដល់ថ្ងៃបរិនិព្វាននោះ ពុំមែនដើម្បីអ្វីក្រៅពីការណែនាំសត្វលោកឲ្យស្គាល់នូវទីដៅដ៏ប្រសើរបំផុតគឺព្រះនិព្វាននោះឡើយ ។

និព្វានជាអត្ថទី ៤ នៃអភិធម្មត្ថសង្គហៈ, ជាគុណជាតដ៏ល្អិតបំផុតដែលបុថុជ្ជនគាប់ឃើញច្បាស់ដោយបញ្ញា បានដោយក្រណាស់, និព្វានជាលទ្ធផលនៃពុទ្ធបរិស័ទ ដែលប្រតិបត្តិដោយសេចក្តីព្យាយាមដ៏ត្រឹមត្រូវតាមមជ្ឈិមាបដិបទា ឬ តាមកុសលធម៌ទាំងឡាយមានបុញ្ញកិរិយាវត្ថុ ១០ ជាដើម ។ និព្វានជាឥដ្ឋារម្មណ៍ (អារម្មណ៍ជាទីប្រាថ្នា, ជាទីគាប់ចិត្ត) នៃកល្យាណបុថុជ្ជននឹងអរិយបុគ្គលដោយពិត ប៉ុន្តែជាអនិដ្ឋារម្មណ៍នៃបាបជនឬពាលជន ដែលឆ្ងាយស្រឡះអំពីកល្យាណបុថុជ្ជននឹងអរិយបុគ្គល ។ ក្នុងឱកាសនេះសូមសំដែងចំពោះព្រះនិព្វាន ដើម្បីជាសណ្តាប់នៃពុទ្ធបរិស័ទដោយសង្ខេបដូចតទៅនេះ៖

ពាក្យថា "ឯញាណ" បានដល់សេចក្ដីស្ងប់, យើងអាចយល់បាន ដោយច្បាស់លាស់ចំពោះព្រះនិព្វាន អាស្រ័យមានពុទ្ធភាសិតដូចតទៅ នេះ :-

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះ រមែងជាអ្នកអាចឃើញច្បាស់នូវសីតិភាព ។ ធម៌ ៦ យ៉ាងនោះគឺ:

១ ការសង្កត់ចិត្តក្នុងសម័យដែលគួរសង្កត់បាន

២-ផ្គងចិត្តឡើងក្នុងសម័យដែលគួរផ្គងបាន

៣-ធ្វើចិត្តឲ្យរីករាយក្នុងសម័យដែលគួរឲ្យរីករាយបាន

៤-ដាក់ចិត្តព្រងើយក្នុងសម័យដែលគួរដាក់ចិត្តបាន

៥-អាធ្យាស្រ័យដ៏ប្រណីតអាចធ្វើបាន

៦-ចិត្តត្រេកអរយ៉ាងខ្លាំងក្នុងព្រះនិព្វាន ។

ពាក្យថា "ជាអ្នកអាចឃើញច្បាស់នូវសីតិភាព" តាមភាសាបាលីប្រើពាក្យថា ភព្វោ អនុត្តរំ សីតិភាវំ សច្ឆិកាតុំ ប្រែថា បុគ្គលគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវសីតិភាពដ៏ប្រសើរបំផុត ឬជាកំពូល ។ ពាក្យថា សីតិភាព នេះប្រែថា "ត្រជាក់ត្រជុំ" ។ អដ្ឋកថាចេញសេចក្ដីថា ព្រះនិព្វាន ដែលជាគុណជាតដ៏ត្រជាក់សុខស្ងប់ក្រៃលែង ព្រោះរលត់ភ្លើងកិលេស ភ្លើងទុក្ខអស់ហើយ ។

អារម្មណ៍នៃអរិយបុគ្គល ដែលចូលដល់ព្រះនិព្វាន ក្រៅអំពីអត្ថបទក្នុងសូត្រនេះ មានអត្ថបទមួយទៀតជាពុទ្ធភាសិតដែលបញ្ជាក់ឲ្យឃើញថា និព្វាន គឺអ្វី ? មានគុណសម្បត្តិដូចម្ដេច ? ពុទ្ធភាសិតនេះសំគាល់ត្រង់ការទទួលអារម្មណ៍ របស់អរិយបុគ្គល ដែលចូលដល់ព្រះនិព្វានហើយ មានចិត្តប៉ះពាល់នូវព្រះនិព្វានហើយ ក្នុងពេលណា ដែលចិត្តបានជួបប្រទះនូវព្រះនិព្វានហើយ ពេលនោះ អរិយបុគ្គលគ្រប់រូបតែងមានការទទួលអារម្មណ៍ដុះចេញមកថា ៖–

គុណជាតនុះស្ងប់ នុះប្រណីត នុះឯងជាទីបន្សាត់បង់នូវសេចក្ដីស្រវឹង ជាទីកំចាត់បង់នូវសេចក្ដីស្រេកឃ្លាន ជាទីដកចោលនូវសេចក្ដីអាល័យ ជាទីកាត់បង់នូវវដ្ដៈ ជាទីអស់ទៅនៃតណ្ហា ជាទីប្រាសចាកកិលេស ជាទីរលត់កិលេស នេះឯងហៅថា «និព្វាន[1]» ។

អត្ថបទខាងលើនេះ តាមភាសាបាលីថា ៖-

ឯតំ សន្តំ ឯតំ បណីតំ យទិទំ មទនិម្មទនោ បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្ដុបច្ឆេទោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ ពាក្យបាលីទាំងនេះ អ្នកដែលមិនស្ទាត់ជំនាញភាសាបាលី ក៏គួរតែព្យាយាមទន្ទេញ

---

១- មាន ២ យ៉ាងគឺ៖ សឧបាទិសេសនិព្វាន ១ អនុបាទិសេសនិព្វាន ១ ។

ឲ្យចាំ ព្រោះពាក្យនេះជាគោលសំដែងនូវអត្ថបទ ទំនងគុណជាតនៃព្រះនិព្វានយ៉ាងជាក់លាក់បំផុត, សូមពិនិត្យពាក្យប្រែតទៅនេះ

ឯតំ សន្តំ គុណជាតនុះស្ងប់

ឯតំ បណីតំ នុះប្រណីត

យទិទំ គុណជាតនេះឯងគឺ

មទនិម្មទនោ ជាទីបន្សាត់បង់នូវសេចក្តីស្រវឹង

បិបាសវិនយោ ជាទីកំចាត់បង់នូវសេចក្តីស្រេកឃ្លាន

អាលយសមុគ្ឃាតោ ជាទីដកចោលនូវសេចក្តីអាល័យ

វដ្ដុបច្ឆេទោ ជាទីកាត់បង់នូវវដ្ដៈ

តណ្ហក្ខយោ ជាទីអស់ទៅនៃតណ្ហា

វិរាគោ ជាទីរលាយរាគៈ

និរោធោ ជាទីរំលត់កិលេស

និព្វានំ ជាទីអស់គ្រឿងចាក់ស្រែះ ។

ពុទ្ធភាសិតនេះសំដែងបញ្ជាក់ថា និព្វានគឺសេចក្តីស្ងប់ដ៏ប្រសើរ ។ ពាក្យថា "ប្រសើរ" នោះ ក្នុងអដ្ឋកថា អធិប្បាយថា "ខ្ពស់ផុតរកអ្វីប្រៀបផ្ទឹមបាន" ។ ក្នុងទីនេះ សេចក្តីស្ងប់ដែលហៅថាព្រះ និព្វាននោះ សំដៅយកសេចក្តីស្ងប់ដ៏ត្រជាក់ត្រជុំប្រសើរខ្ពស់បំផុត ៗ បុគ្គលដែល

បានចូលដល់សេចក្តីស្ងប់ស្ងាត់នេះហើយ មិនចេះធុញទ្រាន់ មិនចេះផ្អែតឡើយ បានសេចក្តីថា ៖ តែងទទួលសេចក្តីស្ងប់ចិត្ត-ផ្អែតចិត្ត-រីករាយចិត្តជានិច្ច។ ន័យនេះសមដូចពុទ្ធភាសិតមួយកន្លែងទៀតថា ៖-

បវិវេកំ រសំ បិត្វា រសំ ឧបសមស្ស ច
និទ្ទរោ ហោតិ និប្បាបោ ធម្មប្បីតិរសំ បិវំ ។

អ្នកដែលបានផឹកនូវរសនៃសេចក្តីស្ងាត់ចាកកិលេស បានផឹកនូវរសនៃសេចក្តីស្ងប់ហើយ រមែងជាអ្នកមិនបានសេចក្តីខ្វល់ខ្វាយ ជាអ្នកមិនបានបាប កាលផឹកនូវរសនៃធម្មប្បីតិ ។

ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា
អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។

អ្នកដែលមានបីតិក្នុងធម៌ មានចិត្តផូរផង់ តែងនៅជាសុខ បណ្ឌិតតែងរីករាយក្នុងធម៌ដែលព្រះអរិយៈទ្រង់ប្រកាសហើយសព្វ ៗ កាល ។

ពុទ្ធភាសិតមួយកន្លែងទៀតមានសេចក្តីស្រដៀងគ្នានឹងពុទ្ធភាសិតខាងលើនេះថា ៖

ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសម-
ថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោ-
ធោ និព្វានំ ។

និព្វានទុះស្ងប់ ទុះប្រណីត នេះឯងជាទីរម្ងាប់នូវសង្ខារទាំងពួង

ជាទីលះបោលនូវឧបធិទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីប្រាសចាកកិលេស ជាទីរលត់នូវកិលេស ហៅថា និព្វាន ។

និព្វានដែលសំដៅយកសេចក្ដីស្ងប់នេះ អាចធ្វើសេចក្ដីចូលចិត្តឲ្យច្បាស់ថា «មិនមែនសំដៅយកសេចក្ដីស្ងប់ធម្មតា ដែលធ្លាប់ដឹងបានមួយដងមួយយាមនោះទេ» គឺសំដៅយកសេចក្ដីស្ងប់ជាកំពូល គ្មានអ្វីបង្កបង្កើតទៀត មិនមែនកើតមកពីអ្វី ឬ ប្រែប្រួលពីអ្វីទៀតឡើយ ជាសេចក្ដីពិតដែលមាននៅខាងលើធម្មជាតិទាំងអស់ ទាំងវត្ថុទាំងនាមធម៌ ។ វត្ថុទាំងឡាយដែលមានបច្ច័យតុបតែង កាលបើអស់ហេតុអស់បច្ច័យហើយ រមែងរលិលចូលទៅក្នុងសេចក្ដីស្ងប់ស្ងៀម ដែលអស់វដ្ដសង្សារនៃសាកលចក្រវាឡ, សេចក្ដីស្ងប់ចាកកិលេសនោះ ទើបបានតាំងនៅជាស្ថាពររកទីបំផុតគ្មាន ។

## ដឹងច្បាស់នូវព្រះនិព្វានដូចម្ដេច ?

សេចក្ដីស្ងប់ដែលហៅថានិព្វាននេះ លោកអ្នកគិតអាចគិតស្មានបានតាមន័យនៃតក្កៈ (សេចក្ដីត្រិះរិះ)ថា វត្ថុណាដែលអស់ទៅនៃហេតុបច្ច័យ ឬដែលកំចាត់ហេតុបច្ច័យចេញបានអស់ហើយ សល់នៅតែសេចក្ដីទទេស្អាត ប្រាសចាកខ្លួនប្រាណ ប្រាសចាកចិត្តនោះ ៗ, ហើយក្នុងសេចក្ដីទទេស្អាតនោះ គ្មានវត្ថុអ្វីក្រៅពីសេចក្ដីស្ងប់ស្ងៀមនៃផលញាណទេ ។

សេចក្តីស្ងប់ដែលពោលមកនេះ មាននៅជានិច្ច មិនចាំបាច់មានទីតុបតែង ព្រោះមិនមានរូបរាងប្រាកដដូចម្តេចទេ ប៉ុន្តែយើងអាចដឹងបានថា វត្ថុគ្រប់យ៉ាងដែលមានប្រាកដនោះ សុទ្ធតែកើតមកពីហេតុបច្ច័យច្រើនយ៉ាងរួមផ្សំគ្នាកើតឡើងជាវត្ថុ ៗ ឯនិព្វានមិនមានវត្ថុអ្វីដែលមានខ្លួនប្រាណពិតប្រាកដទេ ។ សេចក្តីអធិប្បាយដែលពោលមកនេះ ហាក់ដូចនឹងចូលចិត្តឆ្ងាយ តែសូមកុំភ្លេចថា និព្វានគឺជាផលញាណដែលយើងអាចទទួលឯកត្តបរមសុខបាន គឺការទទួលអារម្មណ៍នៃសេចក្តីស្ងប់ពិត ៗ ទើបបានឈ្មោះថា ដឹងច្បាស់ក្នុងព្រះនិព្វាន, ព្រោះនិព្វាននោះ មាននៅផល-ញាណអាចទទួលអារម្មណ៍ជាវិសាលសុខ ដែលផ្សេងពាក្យសុខក្នុងភពទាំង ៣ ។

ពាក្យថា ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ក្នុងគម្ពីរបដិសម្ភិទាមគ្គ ដែលព្រះសារីបុត្តអធិប្បាយថា „បានដល់ការទទួលនូវបរមសុខវិសេស ទើបឈ្មោះថានិព្វាន" ដោយបាលីថា សច្ឆិ-កិរិយាបញ្ញា ផស្សនដ្ឋេ ញាណំ ប្រែថា បញ្ញាជាគ្រឿងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន, ឈ្មោះថា ញាណដោយប៉ះពាល់នូវព្រះនិព្វានអាចប្រៀបនឹងពុទ្ធភាសិតថា ផុសន្តិ ធីរា និព្វានំ យោគ-ក្ខេមំ អនុត្តរំ ប្រែថា អ្នកប្រាជ្ញទាំងឡាយតែងប៉ះពាល់នូវព្រះនិព្វាន

ដែលជាទីក្រមកក្សាន្តចាកកិលេសយ៉ាងប្រសើរបំផុត ។

## និព្វានជាទីស្ងប់នៃសង្ខារទាំងពួង

ពាក្យថា «និព្វាន» គឺជាទីស្ងប់នៃសង្ខារទាំងពួង, សង្ខារ ប្រែថា ធម៌ដែលមានបច្ច័យជាគ្រឿងតុបតែង, ក្នុងទីនេះសង្ខារសំដៅយកនាមរូប ។

កាលបើវិញ្ញាណបានកប់ប្រសប់នឹងសេចក្ដីស្ងប់ដ៏ប្រណីតនេះហើយ អវិជ្ជា តណ្ហា និងឧបាទាន ក៏ឃ្លាតចាកបន្តិចម្ដងៗ ដរាបដល់មិនសេសសល់ ។ ក្នុងពេលដែលកិលេសមិនមាននៅក្នុងសន្តានហើយ មិនមានអ្វី ដែលនាំឲ្យមានកម្មទៀតឡើយ កាលបើអស់ទាំងកម្មទាំងកិលេសហើយ បដិសន្ធិវិញ្ញាណនៃជាតិតទៅទៀតក៏មិនមាន, កាលបើអស់បដិសន្ធិវិញ្ញាណហើយ នាមរូបក៏មិនមាន ព្រោះហេតុនោះនិព្វាន ទើបបាន ឈ្មោះថាជាទីស្ងប់នៃសង្ខារទាំងពួង ។ សេចក្ដីអធិប្បាយនេះ យើងអាចឃើញបានដោយច្បាស់ចំពោះពាក្យសួរ និងពាក្យតបរបស់អជិតមាណព និងព្រះសម្មាសម្ពុទ្ធដូចតទៅនេះ :-

អជិតមាណពបានក្រាបបង្គំទូលព្រះពុទ្ធបរមគ្រូថា :

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមក្រាបបង្គំទូលសួរថា បញ្ញា សតិ និងនាមរូបទាំងនេះ រមែងរលត់អស់ទៅក្នុងទីណា ? សូមព្រះអង្គមេត្តាប្រោសតបឲ្យទាន ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា :

នែអជិតៈ ! អ្នកបានសួរនូវប្រស្នាណាចំពោះតថាគត តថាគតនឹងប្រាប់នូវប្រស្នានោះដល់អ្នក; នាមនិងរូបតែងរលត់មិនមានសល់ក្នុងទីណា បញ្ញានិងសតិក៏រលត់បង់ក្នុងទីនោះដែរ ទាំងនេះក៏ព្រោះវិញ្ញាណរលត់ ។

បញ្ញានិងសតិជាចំណែកមួយនៃនាមធម៌ក្នុងកងសង្ខារ ។ ចម្លើយដែលទ្រង់តបទៅកាន់អជិតមាណព ជាទីគួរចាប់ចិត្តយ៉ាងក្រៃលែង ព្រោះបញ្ញានិងសតិជាសង្ខតធម៌ ជារបស់ត្រូវរលត់ជាមួយនឹងវិញ្ញាណដែរ ។ បញ្ញានិងសតិនេះជានាមធម៌ ជារបស់មិនទៀងទាត់នៅឡើយ ប៉ុន្តែផលនៃនាមធម៌ជាច្រើនយ៉ាង មានពោធិបក្ខិយធម៌ជាដើម ដែលអាចនាំចិត្តធ្វើឲ្យចិត្តរួចចាកអាសវកិលេសទាំងពួង ប្រមូលកំឡាំងឲ្យកើតអរហត្ត-ផលញាណបានដោយពិត ។

## និព្វានជាទីលះបង់នូវឧបធិទាំងពួង

ពាក្យថា «ឧបធិ» ក្នុងទីនេះ សំដៅយកកិលេស ដូចជាពាក្យថា ឧបធិវិវេកោ សេចក្ដីស្ងប់ស្ងាត់ចាកឧបធិក៏មាន សំដៅយកបញ្ចក្ខន្ធក៏មាន ដូចបាលីថា:—

រូបេ ច សទ្ទេ ច អថោ រសេ ច
គាមិត្ថិយោ ចាភិវឌ្ឍិ យញ្ញា

ឋានំ មលច្ឆិ ឧបធិសុ ញត្វា
តណ្ហា ច យិដ្ឋេ ច ហុតេ អនញ្ញំ

យញ្ញទាំងឡាយតែងពោលសរសើររូប សម្ទុង រស កាមទីងស្ត្រី
ទាំងឡាយ ខ្ញុំព្រះអង្គយល់ថា នោះជាមន្ទិលក្នុងឧបធិទាំងឡាយ ហេតុ
នោះ ទើបមិនត្រេកត្រអាលក្នុងការសែនព្រែន នឹងការបន់ស្រន់ ។

ឧបធិក្នុងទីនេះ អដ្ឋកថាប្រាប់ថាបានដល់បញ្ចក្ខន្ធ ។ ឯពាក្យថា
"និព្វាន" នេះ ជាទីលះបង់ទាំងកិលេសទាំងបញ្ចក្ខន្ធ ឥតមានសេស
សល់ឡើយ ។

និព្វានជាវិរាគធម៌

ក្នុងទីខ្លះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ហៅនិព្វានថា "វិរាគធម៌" ដែល
ប្រែថា ធម៌ជាទីប្រាសចាកនៃកិលេស គឺសំដៅសេចក្តីថា ចិត្តរបស់បុគ្គល
ណាមួយ កាលបើបានប្រទះនឹងវិរាគធម៌ហើយ ឈ្មោះថាបានដឹងនូវព្រះ
និព្វានហើយ ។ កិលេសទាំងឡាយរមែងវិនាសចេញពីចិត្ត មិនមាន
សេសសល់ ។ ពាក្យថា "វិរាគធម៌" ក្នុងទីនេះ ក៏គឺសេចក្តីស្ងប់
ដែលប្រាសចាកតម្រេក ដែលយើងអាចយល់បានយ៉ាងច្បាស់ ដោយ
ពុទ្ធភាសិតដូចតទៅនេះ :-

យាវតា ភិក្ខវេ ធម្មា សង្ខតា វា អសង្ខតា

វា វិរាគោ តេសំ អគ្គមក្ខាយតិ យទិទំ មទនិម្មទ-នោ បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្ដុបច្ឆេទោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។

ម្នាលភិក្ខុទាំងឡាយ សង្ខតធម៌ ឬ អសង្ខតធម៌មានចំនួនប៉ុន្មាន វិរាគធម៌ យើងពោលថា ជាកំពូលនៃសង្ខតធម៌និងអសង្ខតធម៌ទាំងអស់នោះ, វិរាគធម៌ គឺធម៌ជាទីបន្ទាត់បង់នូវសេចក្តីស្រវឹង ជាគ្រឿងកំចាត់នូវសេចក្តីស្រេកឃ្លាន ជាគ្រឿងលោសនូវសេចក្តីអាល័យ ជាគ្រឿងរំលត់ទៅនៃកិលេស ហៅថា និព្វាន ។

## និព្វានជាអសង្ខតធម៌

ត្រង់បទថានិព្វានជាអសង្ខតធម៌នេះ យើងអាចយល់បានយ៉ាងជាក់លាក់ ដោយអាស្រ័យពុទ្ធភាសិត ក្នុងពុទ្ធុទាន ខុទ្ទកនិកាយ ដូចតទៅនេះ ៖-

អត្ថិ ភិក្ខវេ អជាតំ អភូតំ អកតំ អសង្ខតំ ។ នោ ចេ តំ ភិក្ខវេ អភវិស្ស អជាតំ អភូតំ អកតំ អសង្ខតំ ។ នយិធ ជាតស្ស ភូតស្ស កតស្ស សង្ខ-តស្ស និស្សរណំ បញ្ញាយេថ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ អជាតំ អភូតំ អកតំ អសង្ខតំ តស្មា

ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយតិ ។

ម្នាលភិក្ខុទាំងឡាយ អាយតនៈដែលមិនកើត មិនលូតឡើង ដែលមិនមានបច្ច័យធ្វើ មិនតាក់តែងមាននៅ, ម្នាលភិក្ខុទាំងឡាយ បើអាយតនៈ ដែលមិនកើត មិនលូតឡើង មិនមានបច្ច័យធ្វើ មិនតាក់តែង មិនបានមានហើយ ការរលាស់នូវវត្តដែលនាំឲ្យកើត លូតលាស់ ដែលមានបច្ច័យធ្វើ ដែលតាក់តែងក្នុងលោកនេះ មិនប្រាកដឬទេ ? ម្នាលភិក្ខុទាំងឡាយ អាយតនៈដែលមិនកើត មិនលូតឡើង មិនមានបច្ច័យធ្វើ មិនតាក់តែង រមែងមាននៅប្រាកដ ព្រោះហេតុណា ហេតុនោះ ការរលាស់ចេញនូវវត្តដែលកើត ដែលលូតលាស់ ដែលមានបច្ច័យ ដែលតាក់តែងរមែងប្រាកដ ។

## និព្វានជាអាយតនៈ

ក្នុងខុទ្ទកនិកាយ មានបាលីបញ្ជាក់ដូចតទៅនេះ ៖

អត្ថិ ភិក្ខវេ តទាយតនំ ។ យត្ថ នេវ បឋវី ន អាបោ ន តេជោ ន វាយោ ន អាកាសានញ្ចាយតនំ ន អាកិញ្ចញ្ញាយតនំ ន នេវសញ្ញានាសញ្ញាយតនំ ។ នាយំ លោកោ ន បរលោកោ ន

ឧភោ ចន្ទិមសុរិយា ។ តមហំ ភិក្ខវេ នេវ អាគតិំ វទាមិ ន គតិំ ន ឋិតិំ ន ចុតិំ ន ឧបបត្តិំ ។ អប្បតិដ្ឋំ អប្បវត្តំ អនារម្មណមេវ តំ ។ ឯសេវន្តោ ទុក្ខស្ស ។

ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះមែនមាននៅ ប៉ុន្តែក្នុងអាយតនៈ នោះមិនមានដី មិនមានទឹក មិនមានភ្លើង មិនមានខ្យល់ អាកាសានញ្ចាយតនៈក៏មិនមែន អាកិញ្ចញ្ញាយតនៈក៏មិនមែន នេវសញ្ញានាសញ្ញាយតនៈក៏មិនមែន លោកនេះក៏មិនមែន លោកដទៃក៏មិនមែន ព្រះចន្ទនឹងព្រះអាទិត្យក៏មិនមែន ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវអាយតនៈនោះថានៅមានដំណើរ គឺការមកទៅ ឈរ ច្យុតិ កើតឡើយ ។ អាយតនៈនោះមិនមានទីតាំង មិនប្រព្រឹត្តទៅ មិនមានអារម្មណ៍សោះឡើយ នេះហើយជាទីបំផុតនៃសេចក្ដីទុក្ខ ។

ពុទ្ធភាសិតនេះហៅនិព្វានថា «អាយតនៈ» ។ ពាក្យថា អាយតនៈនេះសំដៅយកធម្មាយតនៈ គឺជាធម្មារម្មណ៍ដែលសុទ្ធចិត្តចាប់តោងតាមខ្សែឈាន ឬ វិបស្សនាឡើងទៅកាន់លោកុត្តរធម៌ ។ ការដែលនឹងចូលចិត្តគោលនិព្វានឲ្យបានជ្រៅជ្រះ ត្រឹមត្រូវតាមសេចក្ដីពិតនោះ គួរសិក្សាពុទ្ធភាសិតមួយកន្លែងទៀត ក្នុងពុទ្ធុទានដែរដូចតទៅនេះ ៖

និស្សិតស្ស ចលិតំ ។ អនិស្សិតស្ស ចលិតំ

នត្ថិ ។ ចលិតេ អសតិ បស្សទ្ធិ ។ បស្សទ្ធិយា សតិ រតិ ន ហោតិ ។ រតិយា អសតិ អាគតិ គតិ ន ហោតិ ។ អាគតិគតិយា អសតិ ចុតូបបាតោ ន ហោតិ ។ ចុតូបបាតេ អសតិ នេវិធ ន ហុរំ ន ឧភយមន្តរេ ។ ឯសេវន្តោ ទុក្ខស្ស ។ (រតិនឹងរតិយា អដ្ឋកថា កែថា នតិ នតិយា) ។ ការញាប់ញ័រតែងមានដល់បុគ្គលអ្នកអាស្រ័យតណ្ហា ការញាប់ញ័រ មិនមានដល់បុគ្គលដែលមិនអាស្រ័យតណ្ហាទេ, កាលបើសេចក្ដីញាប់ញ័រមិនមាន បស្សទ្ធិ សេចក្ដីស្ងប់រមែងមាន; កាលបើបស្សទ្ធិមាន រតិគឺសេចក្ដីត្រេកអររមែងមិនមាន; កាលបើរតិមិនមាន ដំណើរជាទីមកជាទីទៅក៏មិនមាន; កាលបើដំណើរជាទីមកជាទីទៅមិនមាន ការច្យុតិនឹងការកើតក៏មិនមាន; កាលបើការច្យុតិនឹងការកើតមិនមាន លោកនេះនឹងលោកដទៃក៏មិនមាន; ទីកណ្ដាលនៃលោកទាំងពីរក៏មិនមាន នេះឯងជាទីបំផុតនៃសេចក្ដីទុក្ខ ។

## និព្វានមិនមែនចិត្ត

ចិត្តដែលរួចចាកអាសវក្កិលេសហើយ ហៅថា ចិត្តដល់នូវនិព្វានដោយពិត ប៉ុន្តែកាលបើចិត្តដល់នូវនិព្វានហើយ លែងហៅថាចិត្តទៀតហើយ ។ ពាក្យថា "និព្វាន" នេះលោកសំដៅយកអនុបាទិសេសនិព្វាន-

ធាតុ ។ សមដូចបាលីក្នុងអភិធម្មសង្គណីដែលតាំងជាបញ្ហាថា

កតមេ ធម្មា ចិត្តា ចក្ខុវិញ្ញាណំ សោតវិញ្ញា-ណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោធាតុ មនោវិញ្ញាណធាតុ ឥមេ ធម្មា ចិត្តា ។

កតមេ ធម្មា នោ ចិត្តា វេទនាក្ខន្ធោ សញ្ញា-ក្ខន្ធោ សង្ខារក្ខន្ធោ សព្វញ្ច រូបំ អសង្ខតា ច ធាតុ ឥមេ ធម្មា នោ ចិត្តា ។

ធម៌ទាំងឡាយដូចម្តេច ហៅថាចិត្ត ? គឺចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោធាតុ ១ មនោ-វិញ្ញាណធាតុ ១ ធម៌ទាំងនេះហៅថាចិត្ត ។

ធម៌ទាំងឡាយដូចម្តេច ហៅថាមិនមែនចិត្ត ? គឺវេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ រូបទាំងអស់ ១ អសង្ខតធាតុ ១ ធម៌ទាំងនេះហៅថាមិនមែនចិត្តទេ ។

ពាក្យថា "អសង្ខតធាតុ" បានដល់ធាតុដែលមិនមានបច្ច័យតាក់តែង លោកសំដែងយកនិព្វានដែលបញ្ជាក់ថា: និព្វាន ពុំមែនជាចិត្តឡើយ ។

## និព្វានមិនមែនសូន្យ

និព្វានជាគុណជាតដែលមាននៅជាស្ថាពរ មិនមានការប្រែប្រួល

ជាលទ្ធផល ដែលកើតមកអំពីចិត្តបរិសុទ្ធនៃពុទ្ធបរិស័ទ ។ និព្វានពុំមែនជាទីវាលល្ហល្ហេវដូចអាកាសធាតុទេ ត្រង់ពាក្យដែលថា "និព្វានសូន្យនោះ" មិនមែនសូន្យខ្លួនឯងទេ គឺសូន្យស្ងាត់ចាកកិលេសគ្រប់យ៉ាងសូន្យស្ងាត់ចាកជាតិ ជរា ព្យាធិ មរណៈ សមដូចពុទ្ធភាសិតថា "និព្វានំ បរមំ សុញ្ញំ" និព្វានជាគុណជាតសូន្យដ៏ក្រៃលែង, និព្វានំ បរមំ វទន្តិ ពុទ្ធា ព្រះពុទ្ធទាំងឡាយ តែងពោលថា និព្វានជាគុណជាតប្រសើរក្រៃលែង" ។

ពាក្យថា "និព្វានសូន្យនោះ" សំដៅយកការស្ងាត់ចាកសង្សារវដ្តក្រៀនវិលវល់ ដូចប្រទះនឹងការកើតស្លាប់ ពុំមែននិព្វានសូន្យទទេឯងៗនោះឡើយ ។ ដូចពាក្យថា "គាមោ សុញ្ញោ ឃរំ សុញ្ញំ គេហំ សុញ្ញំ ប្រែថា ស្រុកសូន្យ, ក្រុងសូន្យ, ផ្ទះសូន្យ" ។ ពាក្យថា "ស្រុកសូន្យ" បានដល់ស្រុកសូន្យចាកមនុស្ស ក្នុងកាលដែលមានអាសន្នរោគ ឬ អហិវាតករោគ មនុស្សក្នុងស្រុកភៀសខ្លួនរត់ចេញចោលស្រុក ស្ងាត់ពីស្រុកសូន្យឈឹង ។ ក្រុងសូន្យ, ផ្ទះសូន្យ ក៏មានសេចក្តីដូចគ្នា ។ ស្រុកសូន្យ, ក្រុងសូន្យ, ផ្ទះសូន្យនោះគឺសូន្យស្ងាត់តែមនុស្ស ដោយមិនមានមនុស្សនៅក្នុងស្រុក, ក្នុងទីក្រុង, ក្នុងផ្ទះប៉ុណ្ណោះ ពុំមែនសូន្យស្រុក សូន្យទីក្រុង សូន្យផ្ទះ ដោយគ្មាន

ស្រុក គ្មានទីក្រុង គ្មានផ្ទះនោះឡើយ ។

ស្រុកសូន្យ, ទីក្រុងសូន្យ, ផ្ទះសូន្យនោះ គឺស្រុកមាននៅ, ទីក្រុងមាននៅ, ផ្ទះមាននៅដោយពិត ប៉ុន្តែមិនមានមនុស្សនៅ សេចក្ដីនេះយ៉ាងណា និព្វានមាននៅជាប្រាកដដូចជាសស្រុតតែមួយគ្រាន់តែសូន្យស្ងាត់ចាកជាតិ ជរា ព្យាធិ មរណៈ ប៉ុណ្ណោះក៏យ៉ាងនោះដែរ ។

## ស័ព្ទនៃពាក្យបរិនិព្វានព្រមទាំងអធិប្បាយ

ពាក្យថា «និព្វាន» មកអំពី និ ឧបសគ្គ ប្រែថា «មិនមាន; ចេញ, នាំចេញ» ទីង វា ធាតុ ប្រែថា «ចាក់ដោត, ឈឺចាប់, ក្ដៅកេលពល រលត់, វិលវល់» ទីង យុ បច្ច័យ; យកវាជាវា យក និ មកផ្សំនឹងវាជានិព្វា យកយុបច្ច័យជាអន សម្រេចរូបទៅជានិព្វាន មានសេចក្ដីដូចតទៅនេះ

១ ប្រែថា មិនមានគ្រឿងចាក់ដោត ។ ពាក្យថា ចាក់ដោត បានដល់កូនសរគោលគឺកិលេសមានរាគៈ ទោសៈ ជាដើម ដែលអាចចាក់ដោតសព្វសត្វ ឲ្យបានទទួលទុក្ខវេទនាក្នុងកងវដ្ដសង្សារ រកទីបំផុតបានដោយក្រ ។

២- ប្រែថា មានការឈឺចាប់ដកចេញហើយ ។ ពាក្យថា «ឈឺចាប់» បានដល់សេចក្ដីទុក្ខទាំងពួង ដែលកើតឡើងព្រោះជាតិ ជរា ព្យាធិ មរណៈ ។ ដែលហៅថា «និព្វាន» បានដល់ការដកចេញបាននូវសេចក្ដីទុក្ខទាំងពួងអស់ហើយ ឬថាជាគ្រឿងបញ្ចប់ជាតិ ជរា

ព្យាធិ មរណៈអស់ហើយ ។

៣- ប្រែថា មានកំដៅរលត់ហើយ ។ ពាក្យថា «កំដៅ» បានដល់សេចក្ដីក្ដៅ ពេលពល អន្ទះអន្ទែង ដោយភ្លើងកិលេសទាំង ភ្លើងទុក្ខ ៗ ដែលហៅថា «និព្វាន» បានសេចក្ដីថា មានភ្លើងកិលេស ទាំងភ្លើងទុក្ខរលត់អស់ហើយ ។

៤- ប្រែថា មិនមានគ្រឿងវិលវល់ ៗ ពាក្យថា «គ្រឿងវិលវល់» បានដល់បដិសន្ធិវិញ្ញាណ ដែលអាចត្រាច់ឆ្គាត់ ចាប់កំណើតទៅក្នុងទីផ្សេងៗ ដោយអំណាចវដ្ដៈ (គ្រឿងវិល) ៣ យ៉ាងគឺ កិលេសវដ្ដៈ ការវិលទៅដោយអំណាចកិលេស ១ កម្មវដ្ដៈ ការវិលទៅដោយអំណាចកម្ម ១ វិបាកវដ្ដៈ ការវិលទៅដោយអំណាចវិបាក ១ ។ ដែលហៅថា "និព្វាន" បានដល់ការអស់គ្រឿងវិលវល់ទៅក្នុងលោកហើយ គឺថាជាគ្រឿងបញ្ចប់ដំណើរ ដែលតែងត្រាច់ឆ្គាត់ តែងអន្ទោលទៅក្នុងភព ៗ ដែលហៅថា និព្វាននោះ ដោយមានកិច្ចការដើម្បីខ្លួន ឬ ដើម្បីលោក ចប់ស្រេចហើយ ។

៥- ប្រែថា មិនមានព្រៃពោលគឺកិលេស ។ ពាក្យថា «ព្រៃ» ក្នុងទីនេះ សំដៅយកព្រៃញាតស្បាតពោលគឺកិលេសមានរាគៈ ទោសៈ មោហៈជាដើម ដែលហៅថា «និព្វាន» នោះ គឺជាគុណជាតដ៏បរិសុទ្ធចេញផុតចាកព្រៃស្អាប់ គឺកិលេសអស់ហើយ ។

---

# ព្រះអភិធម្មបិដក

## គម្ពីរព្រះកថាវត្ថុ

(តមក)

លោក ប៊ូ-ប៉ូ ប្រែរៀបរៀង

---

ពាណិជទាំងឡាយដល់នូវមរណភ័យ ជាអាហារនៃត្រីក្នុងមហាសមុទ្រ ផលកំ គហេត្វា បុរសម្នាក់ជាពាណិជមកក្នុងនាវានោះ លុះសំ-ពៅធ្លាយហើយបានក្តារមួយបន្ទះ ខំប្រឹងតោងក្តារហែលចូលទៅដល់កំពង់ឈ្មោះសុប្បារកៈ ។ មនុស្សទាំងឡាយបានឃើញបុរសនោះអាក្រាតគ្មានសំពត់បិទបាំងកាយ ព្រោះសំពត់ស្លៀកដណ្តប់របូតទៅតាមទឹកសមុទ្រអស់ ។ បុរសនោះរកអ្វីស្លៀកពុំបាន ក៏យកមែកឈើស្ងួតមកបន្ក្រងនឹងវល្លិ៍ធ្វើជាសំពត់ស្លៀកដណ្តប់ ហើយទៅដល់ពេងទេព្រក្ស រើសបានអំបែងមួយចំហៀងកាន់ដើរសូមទានបាយទឹក អ្នកកំពង់សុប្បារ-កៈអាស្រ័យ ។ មនុស្សទាំងពួងបានឃើញបុរសនេះ ក៏នាំគ្នាសរសើរថាជាព្រះអរហន្ត សោមនស្សជ្រះថ្លាឲ្យបាយបបរទឹកចំណីចំណុកផ្សេង ៗ ដោយសទ្ធា ហើយយកសំពត់ស្លៀកដណ្តប់មកឲ្យបុរសនោះទៀតផង ។

ចំណែកបុរសនោះគិតតែក្នុងចិត្តថា អាត្មាអញបានលាភសក្ការៈទាំងអម្បាលនេះ មកពីអញអាក្រាតខ្លួនទេ ឥតស្លៀកសំពត់ពាក់អាវ

បើអញស្លៀកពាក់សំពត់អាវ លាភសក្ការៈទាំងពួងមុខជាលែងកើតមានដល់អញទៀត គិតដូច្នេះហើយ មិនព្រមទទួលយកសំពត់អាវដែលគេយកមកឲ្យ ស្លៀកតែស្លឹកឈើមែកឈើដើរត្រាច់ភិក្ខាចារ ។ មនុស្សទាំងឡាយឃើញអាការសន្តោសនៃបុរសនោះ ក៏នាំគ្នាសរសើរថាជាព្រះអរហន្តមួយអង្គ ។ បុរសនោះគិតថា លោកេ អរហន្តា ជនទាំងឡាយពួកណាមួយជាព្រះអរហន្តក្តី ជាអ្នកប្រតិបត្តិដើម្បីនឹងឲ្យបានដល់ព្រះអរហន្តក្តី អាត្មាអញនេះ ក៏រាប់ចូលក្នុងជនពួកនោះបានម្នាក់ដែរ មិនត្រូវអញសង្ស័យទៀតឡើយ ។

អថស្ស សាលោហិតា គ្រានោះ មានព្រហ្មមួយអង្គ ជាបុរាណសាលោហិតមកពីបុព្វជាតិ ចូលមកដល់សំណាក់នៃពាហិយបុរសហើយ ទើបមានវាចាថា ពាហិយ ! អ្នកចូរកុំសំគាល់ខ្លួនដូច្នោះឡើយ ខ្លួនអ្នកមិនមែនជាព្រះអរហន្តទេ មិនមែនជាអ្នកប្រតិបត្តិដើម្បីនឹងឲ្យបានសម្រេចអរហត្តទេ ។

តំ ទិស្វា ចំណែកពាហិយបុរសនោះ លុះក្រឡេកមើលទៅឃើញព្រហ្មស្ថិតនៅឯអាកាស ស្រែកប្រាប់មកខ្លួនដូច្នោះហើយក៏សួរថា អ្នកណាជាព្រះអរហន្ត ហើយអ្នកនោះនៅឯណា ?

កាលពាហិយបុរសបានដឹងសេចក្តីច្បាស់លាស់អំពីព្រហ្មនោះហើយ

ក៏ប្រញាប់ទៅឯនគរសាវត្ថី បានជួបនឹងព្រះបរមសាស្តាកំពុងស្តេចបិណ្ឌបាត កើតចិត្តជ្រះថ្លា បន្ទន់ខ្លួនចូលទៅជិតហើយចាប់ទុកព្រះបាទក្រាបទូលថា បពិត្រព្រះបរមគ្រូទ្រង់សីលាទិគុណគួរឲ្យអស្ចារ្យ ! សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសសំដែងធម្មទេសនា ដើម្បីប្រយោជន៍ និងសេចក្តីសុខដល់ខ្ញុំព្រះអង្គអស់កាលដ៏យូរអង្វែងទៅ ។

សម្តេចព្រះបរមសាស្តាក៏ទ្រង់ត្រាស់ទេសនានៅកណ្តាលផ្លូវ ។ សោ ធម្មំ សុត្វា កាលពាហិយបុរសកំពុងតាំងចិត្តស្តាប់ហើយគិតពិចារណាទៅតាមក្រសែព្រះធម្មទេសនា ក៏បានសម្រេចអរហត្តផល ហើយក្រាបទូលសូមបព្វជ្ជាឧបសម្បទា ព្រះពុទ្ធអង្គទ្រង់ត្រាស់អនុញ្ញាតឲ្យពាហិយបុរសទៅរកបាត្រនិងត្រៃចីវរ កាលពាហិយបុរសកំពុងដើរត្រាច់រង្គាត់ស្វែងរកបាត្រនិងត្រៃចីវរតាមផ្លូវ ស្រាប់តែនាងយក្ខិនីម្នាក់ក្រឡាខ្លួនជាមេគោមកបុះនឹងស្នែងត្រូវចំកណ្តាលដើមទ្រូងនៃពាហិយបុរសក្ស័យជីវិតហើយបរិនិព្វាននៅកន្លែងនោះឯង ។

អ្នកប្រាជ្ញគប្បីជ្រាបថា ពាហិយបុរសនេះ ក៏បានសម្រេចអរហត្តក្នុងកាលខ្លួននៅជាគ្រហស្ថដែរ ចាត់ចូលក្នុងគីហិអរហាតថា ដូចវិសជ្ជនាមកនេះ ឯង ។

រឿងពាហិយបុរសចប់ប៉ុណ្ណេះ ។

# រឿងព្រះបាទសុទ្ធោទនមហារាជ

គីហិ អរហា ហោតិ កោ បន អរហា សុទ្ធោទនោ មហារាជា អរហាតិ សោហិ អជ្ឈាគារំ វសន្តោ សោតាបត្តិផលំ បត្តោ បច្ឆា ធម្មទេសនំ សុត្វា អរហត្តំ បត្វា បរិនិព្វាយីតិ ។

*ការនេះនឹងបានវិសជ្ជនាគីហិអរហាកថាតទៅ ដោយតាំងជាពាក្យសកវាទី និងបរវាទីថា ៖*

*សកវាទី–បុគ្គលជាគ្រហស្ថ បានសម្រេចអរហត្តហើយ និព្វាននោះ មានខ្លះដែរឬទេ ?*

*បរវាទី–មានខ្លះដែរ គឺព្រះបាទសុទ្ធោទនមហារាជ ជាព្រះរាជាធិបតីក្នុងក្រុងកបិលភស្តុ បានសម្រេចអរហត្តផល ហើយចូលកាន់ព្រះនិព្វាន ។*

*សកវាទី–ព្រះបាទសុទ្ធោទនបរមក្សត្រប្រកបព្រមដោយបញ្ចកាមគុណ បើដូច្នោះ ព្រះអរហន្តបុគ្គលត្រេកអរទៅក្នុងបញ្ចកាមគុណដែរឬ ?*

*បរវាទី–អ្នកកុំនិយាយដូច្នោះ ព្រះបាទសុទ្ធោទនៈនោះ តាំងអំពីបានសម្រេចអរហត្តផល ក៏កាត់អាល័យក្នុងរាជសម្បត្តិដាច់អស់រលីងហើយ មិនបានត្រេកអរក្នុងបញ្ចកាមគុណទេ ខ្ញុំនាំរឿងនោះមក*

ពណ៌នាដោយសង្ខេប ដូចតទៅនេះ ៖

អថ ខោ ភគវា ក្នុងកាលដែលសម្តេចព្រះមានព្រះភាគស្តេចចូលទៅអាស្រ័យនៅក្នុងជេតពន នាព្រៃមហាវ័ន ជិតក្រុងសាវត្ថី ព្រះបាទស្រីសុទ្ធោទនមហារាជ ទ្រង់ព្រះពេតាពាធយ៉ាងធ្ងន់ ៗ ព្រះសម្ពុទ្ធទ្រង់ជ្រាបដោយព្រះញាណហើយ ស្តេចយាងទៅសួរជាមួយព្រះវិណាស្រពសង្ឃប្រាំមយអង្គជាបរិវារ ធ្វើឥទ្ធិបាដិហារ្យស្តេចទៅកាន់ព្រះនគរកបិលពស្តុដោយអាកាស លុះដល់ព្រះនគរកបិលពស្តុហើយ ក៏ចុះពាកវេហាស៍ កាន់ភូមិភាគប្រថពី ស្តេចចូលទៅក្នុងព្រះរាជនិវេសន៍ចូលទៅដល់ក្រឡាព្រះបន្ទំនៃសម្តេចព្រះបិតា គង់លើបវរបញ្ញត្តាសនៈខាងព្រះសិរនៃសម្តេចព្រះពុទ្ធបិតា ហើយត្រាស់សួរព្រះអាការប្រឈួន ៗ

តំ សុត្វា សម្តេចព្រះពុទ្ធបិតាបានទ្រង់ព្រះសណ្តាប់ ទើបក្រាបទូលថា ខ្ញុំព្រះអង្គនេះមិនអាចនឹងអត់ធន់បានទេ ហួសកំឡាំងដែលនឹងគង់ជីវិតនៅបាន ៗ សម្តេចព្រះអនន្តញាណត្រាស់ថា មហាបពិត្រព្រះអង្គចូរកុំញាំងសេចក្តីបរិតក្កឲ្យកើតខ្លាំងពេក ត្រាស់ដូច្នេះហើយ ទើបលូកព្រះហស្តខាងស្តាំស្ទាបព្រះសិរនៃសម្តេចព្រះពុទ្ធបិតា ធ្វើនូវព្រះពុទ្ធា-ធិដ្ឋានថា តថាគតបានធ្វើកងការកុសលកសាងព្រះបារមីមកបួនអសង្ខេយ្យកម្រៃមួយសែនកប្ប ដោយប្រាថ្នានឹងប្រោសសត្វសត្វឲ្យរួចផុត

ពីសង្សារវដ្ដ ព្រះកេសាពាធខាងព្រះសិរ នៃសម្ដេចព្រះបិតា ចូរអន្តរធានទៅ ៗ ក្នុងខណៈនោះ ព្រះកេសក្នុងព្រះសិរ នៃព្រះបាទសុទ្ធោទនមហារាជក៏អន្តរធានបាត់អស់ទៅ ដូចជាពារីក្នុងស្លឹកបទុមជាតិរមៀលធ្លាក់ទៅដូច្នោះ ៗ

លំដាប់នោះ សម្ដេចព្រះបាទស្រីសុទ្ធោទនមហារាជ ទើបស្ដេចទង្វាការតាកព្រះវៃនសិរីសេយ្យាសន៍ លើកព្រះករអភិវាទសម្ដេចព្រះបរមត្រៃលោកនាថសាស្ដាចារ្យ ក្រាបទូលនូវអាការនៃទុក្ខវេទនាថា ខ្ញុំព្រះអង្គបានស្រាកស្រាន្តចាករោគាពាធហើយ សម្ដេចព្រះបរមត្រៃលោកនាថទ្រង់ពិចារណាហើយជ្រាបថា សម្ដេចព្រះពុទ្ធបិតានឹងបានសម្រេចអរ-ហត្តផលហើយនឹងបានគង់ព្រះជន្មនៅ ក្រោយពីថ្ងៃនេះទៅបានតែ ៧ ថ្ងៃទៀតប៉ុណ្ណោះទេ លុះទ្រង់ជ្រាបយ៉ាងនេះហើយ ទើបប្រោសប្រទានព្រះធម្មទេសនាអស់ ៧ ថ្ងៃ ទាំងទិវានឹងរាត្រី ជានិច្ចកាលមិនដាច់ សំដែងព្រះត្រៃលក្ខណកថា មានអនិច្ចលក្ខណៈជាដើម ហើយត្រាស់ទេសនាព្រះអរិយសច្ចទាំងបួនប្រការ ៗ សម្ដេចព្រះពុទ្ធជនកាធិបតីបានទ្រង់ព្រះសណ្ដាប់ ក៏បានសម្រេចអរហត្តផល ព្រមដោយបដិសម្ភិទាញាណ ក្នុងថ្ងៃជាគំរប់ ៧ ទើបពិចារណាមើលនូវព្រះជន្មាយុសង្ខារ ទ្រង់ជ្រាបថានឹងមិនបានស្ថិតនៅយូរ ក៏ក្រាបទូលសូមអនុញ្ញាតនឹងបរិនិព្វាន ៗ សម្ដេចព្រះទ្រង់ញាណត្រាស់អនុញ្ញាតថា ចូរទ្រង់មើលកាលដ៏សមគួរចុះ ហើយ

សម្ដេចព្រះជនកាធិបតីលើកព្រះករប្រណម្យស្ដូមខមាទោសថា សូមព្រះអង្គជាទីពឹងរបស់សត្វលោកអត់ទោសដែលខ្ញុំព្រះអង្គភ្លាំងភ្លាត់ប្រមាទពីកាលមុន ៗ រួចមកហើយនោះឲ្យដល់ខ្ញុំព្រះអង្គផង ។ ព្រះមានព្រះភាគទ្រង់អត់ទោសថ្វាយហើយ ព្រះបាទស្រីសុទ្ធោទនមហាពជតំទំរេតព្រះអង្គចុះទៅលើព្រះនៃទបវរសេយ្យាសន៍ រលត់ព្រះអស្សាសៈនឹងបស្សាសៈអស់ព្រះជន្មាយុសង្ខារស្ដេចចូលកាន់ព្រះនិព្វានក្នុងថ្ងៃនោះ ។

សម្ដេចព្រះទសពលញាណមានធម្មសង្វេគត្រាស់សំដែងព្រះធម្មទេសនាមានអនិច្ចលក្ខណៈជាដើម ចប់ហើយទ្រង់ត្រាស់ទីងព្រះអរិយកស្សបមហាថេរដែលជាអ្នកចាស់ជាងព្រះអរិយសង្ឃទាំងពួងថា ម្នាលកស្សប ! តថាគតនឹងធ្វើឈាបនកិច្ចសពព្រះបិតា អ្នកចូរទៅពិចារណារកមើលទីកន្លែងឲ្យសមគួរនឹងធ្វើឈាបនកិច្ចព្រះសរីរៈនៃព្រះបរមបិតា ។

ព្រះមហាកស្សបត្ថេរទទួលព្រះពុទ្ធដីកាហើយ មានភិក្ខុសង្ឃជាបរិវារ ព្រមទាំងសក្យរាជនឹងរាជបរិវារជាច្រើន ទៅឯទីឈាបនកិច្ចហើយធ្វើដើងថ្ករ ។

អមរគណា កន្លងខណៈនោះ ពួកអមរទេវតាក្នុងមុនបក្រាវឡមានអង្គអមរិន្ទ្រទេវរាជជាប្រធាន មកសះមោសរសន្និបាតប្រជុំគ្នានាំយកកុជាតារបុស្សកប្រដាប់ដោយកំពូលប្រាំយេ ព្រមទាំងគ្រឿងប្រដាប់ព្រះសរីរសពផ្សេង ៗ នឹងគ្រឿងក្រអូបទិព្យសំគាល់ផ្សេង ៗ មកថ្វាយ ៗ

ចំណែកព្រះមហាកស្សបត្ថេរ កាលធ្វើចិតកាធាររដើនថ្កូររួចស្រេចហើយ ត្រឡប់មកក្រាបទូលសម្តេចព្រះបរមសាស្តា ។ ក៏លើកឧត្តមង្គសិរោត្តម នៃសម្តេចព្រះស្រីសុទ្ធោទនមហារាជពុទ្ធបិតាហើយ ជុសលាងសំអាតដោយទុកឈាកសុគន្ធរសវារី ព្រះធម្មសេនាបតីសារីបុត្រដ៏ជាព្រះអគ្គសាវកខាងស្តាំ ក៏ជួយស្រោចស្រង់ព្រះទុកឈាកលើព្រះកាយនៃសម្តេចព្រះបរមជនកាធិបតី ។

ខណៈនោះ សម្តេចព្រះជិនស្រីទ្រង់ត្រាស់នឹងភិក្ខុសង្ឃទាំងពួងថា អ្នកចូរឃើញនូវព្រះពុទ្ធបិតារបស់តថាគតចុះ ត្រាស់ដូច្នេះហើយទើបមានព្រះពុទ្ធដីកានឹងព្រះសារីបុត្រថា ម្នាលសារីបុត្រ ! បុគ្គលណាប្រព្រឹត្តសុចរិតធម៌ ហើយមានចិត្តប្រាថ្នានឹងទៅកាន់ព្រះនិព្វាន បុគ្គលនោះចូរប្រតិបត្តិបិតាមាតាចុះ ត្រាស់រួចហើយទ្រង់លើកសពព្រះបិតាដាក់ក្នុងកេទមញ្ញុស គឺហិបកែវហើយដង្ហែទៅឯឈាបនដ្ឋាន ដំកល់ក្នុងកុដាគារបុស្សក សម្តេចអមរិន្ទ្រធ្វើប្រទក្សិណព្រះបរមសព ហើយយកកែវជាតិរស្មួយដួងមកបម្រុងនឹងថ្វាយព្រះភ្លើង ។ ព្រះបរមសាស្តាឃាត់ថា ព្រះអង្គកុំអាលអុជអគ្គី ទុកឲ្យតថាគតអុជមុន ព្រះឥន្ទក៏ថ្វាយដួងកែវមណីទៅព្រះសាស្តា ។ ទ្រង់អុជអគ្គីធ្វើឈាបនកិច្ច ។ លំដាប់នោះ ទេវនិករមានសម្តេចអមរិន្ទ្រជាដើម នឹងបរមក្សត្រសក្យរាជ, មនុស្សទាំងឡាយ

កំពុងអគ្គីជាលំដាប់ ។

អ្នកប្រាជ្ញទាំងឡាយគប្បីធ្វើមនសិការកំណត់ទុកក្នុងចិត្តថា សម្ដេចព្រះបាទស្រីសុទ្ធោទនមហារាជ ជាព្រះពុទ្ធបិតា បានសម្រេចអរហត្តផល ហើយអស់ព្រះជន្មចូលកាន់និព្វានដោយភេទជាគ្រហស្ថ កំគួរនឹងបាត់ចូលក្នុងគីហិអរហាកថានេះ ។

រឿងព្រះបាទសុទ្ធោទនមហារាជ ចប់ប៉ុណ្ណេះ ។

គីហិអរហាកថា ចប់ប៉ុណ្ណេះ ។

# មធុរសវាហិណី

សម្ដេចព្រះធម្មលិខិត លី-ឯម ប្រែរៀបរៀង

(តមក)

---

គ្រានោះ មានពួកមនុស្សដែលនៅក្នុងរទេះមួយផ្សេងដោយឡែក បានឃើញពាណិជនោះស្រេកទឹកខ្លាំង ក៏មានសេចក្ដីករុណាអាណិតពន់ពេក ហើយនិយាយប្រាប់ថា នែពាណិជ ! អ្នកត្រូវអញ្ជើញមកខាងនេះ ដ្បិតមានទឹកបន្តិចក្នុងអណ្ដូងទឹកតូចនេះ ចូរអ្នកទៅមើលឲ្យឃើញច្បាស់ ហើយផឹកចុះ ។

ឯពាណិជក៏បានចុះទៅក្នុងអណ្ដូងនោះហើយ ដងទឹកផឹកក្នុងខណៈនោះឯង ។

ឯទឹកនោះ ក៏ប្រែត្រឡប់ទៅជាទឹកមានឱជារសផ្អែម ប្រាកដស្មើដោយទឹកផ្លែច័ន្ទដោយពិត ។

ឯពុទ្ធវម្មពាណិជនោះសោត កាលបើបានផឹកទឹកដ៏មានឱជារសនោះហើយក៏គិតរំពឹងពិចារណាយ៉ាងនេះថា : ឱហ្ន៎! នេះជាផលានិសង្សហូរជូនមកពុំដាច់ នៃទឹកច័ន្ទដែលអាត្មាអញបានថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃក្នុងកាលនោះ, ឥឡូវនេះបានឲ្យផលសម្រេចជាទិដ្ឋធម្មក្នុងថ្ងៃនេះឯង ។ លុះពាណិជគិតយ៉ាងនេះហើយ ក៏មានចិត្ត

សោមនស្សជ្រះថ្លា បានឡើងពីគណ្ឌត្រឡប់មកកាន់វេទិវិញបាន ត្រួតមើលភាជន៍កាន់ទឹកទាំងអស់ក្នុងវេទិរបស់ខ្លួន ។

ឯភាជន៍ទាំងនោះសឹងពេញបរិបូណ៌ដោយទឹកចន្ទន៍មានឱជារសផ្អែម កើតប្រាកដក្នុងកាលនោះឯង ។

លុះឯពាណិជនោះបានឃើញទឹកដ៏ជាទិព្វមានឱជារសពេញភាជន៍ទាំងអស់ ពុំបានស្រកស្រុតទៅ សឹងនៅពេញដដែល ក៏កើតបីតិផ្សព្វផ្សាយសព្វកាយទាំងអស់ ហើយគាត់ឃោសនាប្រាប់មនុស្សទាំងឡាយថា: នែអ្នកទាំងឡាយ! ចូរអ្នកទាំងអស់គ្នាផឹកទឹកទិព្វនេះ ឲ្យឆ្អែតបរិបូណ៌គ្រប់គ្នា តាមត្រូវការចុះ ។

ពួកមនុស្សទាំងនោះ បានស្តាប់ពាក្យឃោសនា ហើយក៏មកជួបជុំមួយពេល បានឃើញទឹកដ៏ជាទិព្វកើតប្រាកដដូច្នោះហើយ ក៏មានចិត្តស្ងើចពន់ពេក ហើយបបួលគ្នាដងទឹកនោះផឹកតាមប្រាថ្នា ពុំចេះអស់សឹងមានឱជារសផ្អែមឆ្ងាញ់ជាងទឹកទាំងពួងក្នុងលោកនេះ ឥតមានរសទឹកដទៃប្រៀបផ្ទឹមបានឡើយ ។

ចំណែកឯពាណិជក៏បានប្រកាសសំដែងសរសើរនូវពុទ្ធានុភាពក្នុងកណ្តាលទីប្រជុំនៃមនុស្សទាំងឡាយនេះ ហើយសូត្រជាបទគាថាថា:

បស្សថេតំ កត្តា កោ អានុភាវំ មហោសិនោ

អចិន្តិយមប្បេយ្យំ សន្ទិដ្ឋិកមកាលិកំ ...

ម្នាលអ្នកទាំងឡាយដ៏ចំរើនអើយ! ចូរអ្នករំពឹងមើលនូវអានុភាពនៃទានដ៏អស្ចារ្យដែលបណ្ឌិតពុំបានស្មានទុកមុន ជាទានឲ្យផលទាន់ក្នុងពុំរង់ចាំកាល ដែលខ្ញុំថ្វាយហើយចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ប្រសើរមានសីលគុណជាដើមដោយពិត ។

បសន្នមានសា តុម្ហេ ទិន្នំ ទានិយកំ មយា
វិបច្ចតិ ឥធេវ តំ ទានំ មុទ្ទិកាហសា ។

ទានប្រកបដោយទឹកបានឯណា ដែលខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយហើយចំពោះព្រះពុទ្ធជាម្ចាស់, ទាននោះមានទឹកចន្ទជាទីត្រេកអររមែងឲ្យផលដ៏ជាក់ស្តែងក្នុងបច្ចុប្បន្ននេះឯង ។

ឱជវន្តំ សុទុត្តំ វា សីតលំ មធុរោទកំ
ទិព្វានំវ ទេវានំ ជាតអត្តតមក្ខាយំ
សីលវន្តេសុ គោ ធាម ន ធនេយ្យ វិចក្ខណោ
ឥធ លោកេ បរត្ថេសុ សុខទំ ទានមុត្តមំ ។

ម្យ៉ាងទៀតទឹកផ្អែមត្រជាក់មានឧជារសដ៏ស្អាត បីដូចទឹកដ៏ជាទិព្វរបស់ទេវតាទាំងឡាយមិនបេះអស់ទៅ គួរជាទីអស្ចារ្យឡើង (ដល់ខ្ញុំ) អ្នកប្រាជ្ញណាមិនដែលឲ្យទានដល់បុគ្គលអ្នកមានសីលទាំងឡាយ ក៏ត្រូវតែ

ឲ្យទានដោយពិត ៗ ឯទានដ៏ឧត្តម ដែលបុគ្គលបានឲ្យហើយ រមែងឲ្យនូវសេចក្ដីសុខក្នុងលោកនេះនឹងក្នុងបរលោកពុំខានឡើយ ៗ

យទិច្ឆិតំ គហេត្វាន បិវិត្វា មធុរោទកំ
ភាជនានិ ច បូរេត្វា យន្តិ សព្វេ យទិច្ឆិតំ ៗ

មនុស្សទាំងពួងនោះយកទឹកផ្អែម ហើយផឹកឲ្យឆ្អែតគួរតាមប្រាថ្នាផង ផងយកដាក់ក្នុងភាជន៍ឲ្យពេញតាមប្រាថ្នាផង ហើយត្រាច់ទៅចុះ ៗ

លុះពុទ្ធមាមកពាណិជបានពោលគាថាយ៉ាងនេះហើយ ក៏បញ្ជាមនុស្សទាំងគោទាំងឡាយ ឲ្យក្រេបផឹកទឹកច័ន្ទទិព្វដ៏មានឱជារសផ្អែមពិសារទាំងអស់គ្នា ក្នុងកាលនោះឯង ៗ

ចំណែកពួកមនុស្សក្ដី គោទាំងឡាយក្ដី ក៏បានក្រេបផឹកទឹកផ្អែម ដកបដល់ឆ្អែតគ្រប់ ៗ គ្នា ឯទឹកច័ន្ទក្នុងភាជន៍នោះក៏ពុំបេះអស់ សឹងនៅពេញភាជន៍វិញដដែល ដោយបុញ្ញឫទ្ធិនោះគួរជាទីអស្ចារ្យពន់ពេក ៗ

លំដាប់តពីនោះ ពាណិជក៏បានប្រកបជំនួញដោយឈ្មួញរទេះទាំងឡាយ តែងត្រាច់ទៅកាន់នគរតូចធំក្នុងជម្ពូទ្វីបទាំងអស់ លក់ទំនិញតាមធម្មតា បានទៅដល់នគររាជគ្រឹះហើយគិតថា អាត្មាអញនឹងចូលទៅនមស្ការថ្វាយបង្គំព្រះមានព្រះភាគ ហើយសឹមធ្វើដំណើរចេញទៅទើបគួរ, លុះពាណិជគិតយ៉ាងនេះហើយ ក៏ចូលទៅកាន់វិហារវេឡុវ័ន

បានថ្វាយបង្គំព្រះសាស្តាចារ្យ ហើយអង្គុយក្នុងទីសមគួរ ។

ចំណែកឯព្រះបរមសាស្តាចារ្យ ព្រះអង្គបានធ្វើបដិសណ្ឋារៈស្រស់ស្រាយជាមួយនឹងពុទ្ធវម្ពាណិជនោះឯង ។

ឯពាណិជ ក៏បានយកសេចក្តីដែលជាអស្ចារ្យនោះ ក្រាបបង្គំទូលចំពោះព្រះមានបុណ្យជាម្ចាស់ ដោយសេចក្តីសព្វគ្រប់ដូច្នេះថា: បពិត្រព្រះមានជោគជ័យចំរើន! ខ្ញុំព្រះអង្គបានឃើញបាដិហារិយ៍របស់ព្រះអង្គ គួរជាទីអស្ចារ្យ អត់ទ្រាំទុកពុំបាន ទើបចូលមកកាន់សំណាក់ព្រះអង្គនេះឯសេចក្តីអស្ចារ្យនោះ កើតប្រាកដដូចខ្ញុំព្រះអង្គក្រាបបង្គំទូលហើយយ៉ាងនេះពិត សូមព្រះអង្គទ្រង់ជ្រាប ។

ឯព្រះមានព្រះភាគបានទ្រង់ព្រះសណ្តាប់ហើយ ក៏ទ្រង់សំដែងព្រះធម៌វិសេសទេសនា ជាសណ្តាប់ដល់ពាណិជនោះឯង ។

លុះពាណិជនោះបានស្តាប់ព្រះធម៌ទេសនាហើយ ក៏និមន្តព្រះសាស្តាជាម្ចាស់ ព្រមទាំងព្រះភិក្ខុសង្ឃដើម្បីទទួលភត្តទៅក្នុងថ្ងៃស្អែក កាលបើដល់ពេលថ្វាយភត្តហើយ ពាណិជក៏បានថែងមហាទានថ្វាយដល់ព្រះភិក្ខុសង្ឃ មានអង្គព្រះសម្មាសម្ពុទ្ធជាប្រធាន លុះព្រះសម្ពុទ្ធបានធ្វើភត្តកិច្ចឆាន់រួចស្រេចហើយ ពាណិជក៏ទទួលទេះបរចេញទៅកាន់ផ្ទះខ្លួនវិញហោង ។

ជាប់ដើមតាំងពីថ្ងៃនោះមក ពុទ្ធវម្មពាណិជនៃងហាត់ខែងធ្វើបុណ្យច្រើនប្រការ មានឲ្យទានជាដើមដរាបដល់អស់ជីវិត ក៏បានទៅចុតិកើតក្នុងវិមានមាសជាទិព្វ មានកំពស់ប្រមាណ ១២ យោជន៍ ក្នុងស្ថានទេវលោក មានស្រីទេពអប្សរចោមរោមជាបរិវារ ប្រកបព្រមដោយទេវសិរីដ៏ប្រសើរ ទេវបុត្តនោះនៃងសោយទិព្វសម្បត្តិ ជាសុខក្សេមក្សាន្តក្នុងស្ថានសួគ៌នោះឯង ។

ដោយអានុភាពបុញ្ញកម្មនោះ សឹងមានភាជន៍ទិព្វសម្រេចដោយកែវ ៧ ប្រការ ដ៏ពេញដោយទឹកចន្ទជាទិព្វដ៏មានខុជាសេដ៏វិសេស គួរជាទីអស្ចារ្យក្រៃលែង ។ ឯទេវតាទាំងឡាយបានដកទឹកចន្ទទិព្វនោះហើយក៏លេងល្បែងច្រៀងរាំប្រគំតូរ្យតន្ត្រី បំរើទេវបុត្តនោះជាប្រក្រតី ។

ព្រោះហេតុដូចនេះ បានជាព្រះអរហន្តទាំងឡាយ ពោលជាបទគាថាដូចនេះថា:

ឥ វិបុលជិឥសារំ ញាណមាលោ ជលេវំ
លភតិ វិបុលភោគំ តោយមត្តស្ស នានា
វិចិត្តគុណគណា ភោគេសុ វត្ថេសុ តុម្ហា
លភថ ចលុ វិសេសំ សីលវន្តេសុ នានា

ជនជាសប្បុរស សូម្បីមិនបានជីងច្បាស់នូវផលានិសង្ស មាន

ប្រមាណច្រើនដ៏ជាខ្ទឹមសារក្នុងសាសនានៃព្រះជិនស្រី គង់អាចបាននូវភោគសម្បត្តិជាទិព្យ មានប្រមាណច្រើនដោយហេតុដែលបានថ្វាយទឹកចំនួនមានប្រមាណតិចប៉ុណ្ណោះដែរ ព្រោះហេតុនោះអ្នកទាំងឡាយសុទ្ធតែចម្រើនគុណដែលខ្លួនបានដឹងហើយ គួរតែថ្វាយទឹកបានជាគ្រឿងភេសជ្ជៈចំពោះវត្ថុទាំងបីគឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាដែនកើតភោគសម្បត្តិដោយពិតៗ សូមអ្នកទាំងឡាយបានសម្រេចនូវសម្បត្តិដ៏វិសេស ព្រោះបានឲ្យទានដល់បុគ្គលដែលមានសីលប៉ុណ្ណោះឯង ។

សំដែងរឿងនិទាន ពុទ្ធវម្មពាណិជជាគំរប់ ៩ ក្នុងវគ្គទីមួយ ក៏ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណោះឯង ។

## រូបទេវីវត្ថុកថា

សំដែងរឿងនិទាននាងរូបទេវីតទៅទៀត ដោយបទបាលីថា:

អតីតេ កិរ វិបស្សិស្ស ភគវតោ កាលេ ដូច្នេះជាដើម

អធិប្បាយថា: កិរ បានឮរឿងៗមក ក្នុងកាលព្រះមានព្រះភាគទ្រង់ព្រះនាមវិបស្សី ៗ គង់នៅយូរហើយ ក្នុងរាជធានីនោះមាននាងគាមទារិកាម្នាក់បានដើរទៅកាន់វិហារ ក៏បានឃើញភិក្ខុមួយអង្គមានជម្ងឺ ហើយនាងមានសន្តានញាប់ញ័រករុណាភិក្ខុនោះបានចូលទៅជិតថ្វាយបង្គំសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ! តើជម្ងឺអ្វីបៀតបៀន

សរីរៈលោកម្ចាស់ឲ្យឈឺចាប់នេះ ?

ភិក្ខុនោះតបថាៈ ម្នាលនាង ! អាពាធចុកសៀតក្នុងផ្ទៃដ៏ក្រៀវក្រា បៀតបៀនអាត្មាភាព ។ ឯនាងគាមទារិកានោះ លុះបានស្តាប់ហើយ ក៏បវារណានិមន្តភិក្ខុនោះថាៈ បពិត្រលោកម្ចាស់ដ៏ចំរើន ! បើដូច្នោះខ្ញុំម្ចាស់នឹងផ្សំថ្នាំម្យាប់រោគនោះ ប្រគេនលោកម្ចាស់ឥឡូវនេះឯង ។ លុះបាននិមន្តស្រេចហើយ ក៏ត្រឡប់ទៅកាន់ផ្ទះនាងវិញ បានថ្លែងពតិមាននោះជំរាបមាតាបិតាឲ្យបានជ្រាបសេចក្តីសព្វគ្រប់ កាលបើមាតាបិតារបស់នាងបានអនុញ្ញាតឲ្យហើយ នាងក៏រៀបណ្តាប់តាក់តែងផ្សំថ្នាំដោយរសផ្សេង ៗ ធ្វើជាបបរថ្នាំបំរុងទុកជាស្រេច ។

លុះថ្ងៃព្រឹកឡើង ភិក្ខុអ្នកមានជម្ងឺនោះក៏បានឃ្លុំចីវរជាបរិមណ្ឌល ត្រាច់ទៅដើម្បីបិណ្ឌបាត្រ បានចូលទៅកាន់ផ្ទះនាងគាមទារិកានោះឯង ។

ឯនាងគាមទារិកា កាលបើបានឃើញព្រះថេរៈនិមន្តមកដល់ផ្ទះហើយក៏កើតសេចក្តីសោមនស្សជ្រះថ្លាក្រោកឡើងទៅទទួលយកបាត្រ រួចហើយ ចាត់ចែងក្រាលអាសនៈប្រគេនព្រះថេរៈនោះ ។

លុះព្រះថេរៈបានស្ថិតនៅលើអាសនៈស៊ប់ហើយ នាងក៏អង្គាសព្រះថេរៈឲ្យឆាន់បង្ហាន់យ៉ាងស្រួល បានធ្វើសក្ការបូជាដោយគោរព ។

កាលបើព្រះថេរៈបានឆាន់ភេសជ្ជាហារ ដែលជាថ្នាំសក្តិសិទ្ធិរួចភ្លាម

អាពាធក្នុងសរីរៈរបស់លោកក៏រម្ងាប់ទៅមួយរំពេចដែរ ដោយកម្មដ៏សក្ត របស់នាងកាមទារិកានោះឯង ។

លុំដាប់តពីនោះមក ព្រះថេរៈអង្គនោះ លោកពុំបាននិមន្តទៅកាន់ផ្ទះនាងកាមទារិកានោះទៀតឡើយ ។

លុះថ្ងៃជាខាងក្រោយ នាងកាមទារិកាក៏បានចូលទៅកាន់ព្រះវិហារ ថ្វាយបង្គំព្រះថេរៈនោះ ហើយ ទូលសួរថា ព្រះករុណាពុំបាននិមន្តទៅកាន់ផ្ទះរបស់ខ្ញុំម្ចាស់ តើព្រោះហេតុអ្វី? ព្រះថេរៈតបថា: ម្នាលឧបាសិកា! បានជាអាត្មាមិនទៅកាន់ផ្ទះនាងទៀត ព្រោះអាត្មាបានសះជារោគស្រឡះហើយ ។

ឯនាងឧបាសិកា លុះបានដឹងថា ព្រះថេរៈបានជាសះរោគហើយក៏ទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន! ការនេះប្រពៃណាស់ហើយៗ ។ នាងមានសេចក្តីសោមនស្សជ្រះថ្លាកើតឡើងក្នុងសន្តានពុំមានដាច់ ហើយថ្វាយបង្គំលាព្រះថេរៈត្រឡប់ទៅកាន់ផ្ទះនាងវិញហោង ។

ដោយតេជៈផលានិសង្សបុញ្ញកម្មនោះ ៗ លុះនាងអស់អាយុក៏បានឡើងទៅកើតក្នុងស្ថានតាវត្តិង្សទេវលោកនាយ ដូចជាស្ត្រីភ្ញាក់អំពីដេកលក់មួយរំពេចនោះឯង ។ មានវិមានមាសជាទិព្វដុះឡើងប្រមាណកំពស់ ១២ យោជន៍ ប្រកបដោយស្ត្រីទេពអប្សរជាច្រើនកើតប្រាកដដល់នាងទេពធីតានោះឯង ។ (នៅមានត)

# មហោសថជាតក

(តមក)

លោក អ៊ឹម-ភន ចម្លងពីសាស្ត្រស្លឹករឹត

ព្រះពុទ្ធវង្ស គឹម-តូរ ពិនិត្យ

---

ទើបពោធិសត្វអ្នកដណ្តឹងថា ម្នាលគ្នាយើងទាំងឡាយអើយ ពុំមានអ្នកឯណាឯងអាចហ៊ានស្រដីពិតទូលព្រះមហាក្សត្រាធិរាជឬទេហ្ន៎ ? អស់អ្នកផងទាំងឡាយឮហើយឆ្លើយថា បពិត្រព្រះមហោសថអើយ រីអ្នកដែលហ៊ានស្រដីក្រាបពិតទូលនោះមិនជាទម្ងន់ឡើយ ឆាយណាស់ឯងអេះ ៗ ព្រះមហោសថអ្នកប្រាជ្ញស្តាប់ហើយឆ្លើយថា អើបើដូច្នោះ អស់គ្នាយើងទៅហៅមកអញនឹងប្រើបន្តិចហ៎ះ, ទើបអស់អ្នកផង ឲ្យទៅជ្រើសរើសរកយកអ្នកដឹងឈ្មោះបេះតែងថ្លែងសំដី ហ៊ានពិតទូលនោះ នាំមកកាន់ព្រះមហោសថអ្នកប្រាជ្ញ ៗ ទើបព្រះអង្គបង្គាប់ថា ម្នាលព្រះស្តែង ចូរហៅទៅកាន់ព្រះរាជមន្ទីរព្រះមហាក្សត្រាធិរាជ នាកាលបៀបទៀបនឹងដល់ព្រះរាជវាំងព្រះមហាក្សត្រ ចូរព្រះស្តែងរំសាយសក់ចុះលើស្មា ហើយលើកដៃដាក់លើត្បូងដៃមួយគក់ទ្រូងទ្រហោស្រែកយំដោយនូវទំនួញនោះផ្សេងៗ ទោះមានអ្នកផងដណ្តឹងប្រការដូចម្តេច ១ ក្តី ក៏ប៉ព្រះស្តែងស្រដី

ដល់តិចឡើយ ហើយរឹងជាទួញយំខ្លាំងណាស់ទៀត ហើយចូលទៅឲ្យបានដល់ព្រះរាជមន្ទីរនោះហោង, បើព្រះមហាក្សត្រាធិរាជ ស្តេចត្រាស់ដណ្តឹងឯង ក៏ព្រះស្តែងលើកកំបង់អញ្ជលីក្រាបថ្វាយបង្គំហើយទូលបណ្តើរថា បពិត្រព្រះសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអើយ, សូមទាន ផ្សែតអាពុកអញខ្ញុំព្រះបាទអម្ចាស់ មានគភ៌ធំណាស់ចាស់ថ្ងៃ គប្បីលម្មទឹងប្រសូតកូនហើយ ក៏ឥឡូវនេះ ទឹងប្រសូតពុំរួចឡើយ ជាគំរប់ ៧ ថ្ងៃទឹងថ្ងៃនេះហើយ, រីអស់ឆ្មបពេទ្យមេមត់ សឹងប្រយុទ្ធសោយដៃអស់ហើយ ខ្ញុំឥតបើទឹងពុំនាក់សំណាក់ឯណាឡើយ មានតែព្រះអង្គឯង ជាពំនាក់ខ្ញុំហោង, ឥឡូវនេះ ខ្ញុំមកសំណាក់ក្រាបទូល សូមពេទ្យល្អឯងទឹងឲ្យជួយយកកូនអំពីគភ៌ផ្ទៃនៃអាពុកខ្ញុំហោង, រីមហាក្សត្រាធិរាជមានព្រះបន្ទូលថា បុរសនេះវាស្រដីរវើរវាយអ្វីដូច្នេះហ៎ះទូ ជួនរណាប្រុសក៏ទឹងមានកូនប្រសូតនោះហ៎ង អញមិនដែលមានដូចព្រះស្តែងស្រដីនោះហ៎ង វានេះឆ្កួតទេដឹងអេះ ? កាលណាបើមហាក្សត្រាធិរាជ ស្តេចមានព្រះបន្ទូលដណ្តឹងថាដូច្នោះហើយ ក៏ព្រះស្តែងទូលវិញថា បពិត្រព្រះនរបតីស្រីសម្មតិទេពក្សត្រថ្លៃប្រសើរអើយ បើប្រុសមិនដែលមានប្រសូតកូនដូច្នោះហើយ តើហេតុអ្វីព្រះអង្គស្តេចឲ្យយកគោមង្គល១សភរាជ ឲ្យទៅសិរីវឌ្ឍកសេដ្ឋី នូវអស់អ្នកស្រុកបាចីនយវមជ្ឈ-

ត្រាម  ប្រើធ្វើគោឲ្យប្រសូតកូនហ៎ះមហាពជ  ថាបើអាពុកខ្ញុំមិនដែល មានប្រសូតកូនហើយ, គោម្គល ៖ សកពជនោះ កំពុំអាចនឹងប្រសូតបាន ដូចអាពុកខ្ញុំហោង ។ បុរសនោះ  ស្តាប់ពាក្យព្រះមហោសថអ្នកប្រាជ្ញ ផ្តាំចាំឥតសំណល់ ដកល់ទុកក្នុងចិត្តស្រេចហើយ ក្រាបលាធ្វើអស់អាថ៌ សេចក្តី  ដូចទ័យយើងស្រដីរៀងមកកាលព្រះមហោសថអ្នកផ្តាំនោះឯង ហោង ។ មហាក្សត្រាធិពជជ្រាបហើយ មានព្រះបន្ទូលថា ហៃព្រះ ស្តែង  អ្នកឯណាអាចរិះគិតជាអាថ៌ប្រស្នាតបតមកដូច្នេះហ្នឹង? បុរស នោះ ក្រាបថ្វាយបង្គំប្រណម្យទូលថា បពិត្រមហាពជអើយ ព្រះមហោ· សថអ្នកប្រាជ្ញឯង  អាចប្រើមកធ្វើជាអាថ៌ប្រស្នាតបនឹងព្រះអង្គ, មហា ក្សត្រស្តាប់ហើយ  មានព្រះហឫទ័យនោះដំ·ពញនូវព្រះអំណរអរក្រៃពេក ហោង ។

ឧទ្ធនន្តិ ។  នេះនឹងស្រដីពីការល្បងបាយនោះមិញ ។

អបរស្មឹ  ទិវសេ  បណ្ឌិតំ  វីមំសិស្ញាមាតិ  ចន្ទត្វា ចាឍីឍយមជ្ឈតាមភសិតោ  គិរ  បណ្ឌិតា  អម្ហាកំ អដ្ឋង្គសមន្នាគតំ អម្ពិលោទនំ បចិត្វា បេសេន្តុ ។ ល ។

មានកាលសម័យថ្ងៃមួយទៀត, មហាក្សត្រាធិពជ ជំនុំរិះគិតនឹងអស់ អ្នកប្រាជ្ញទាំង ៤ ស្តេចនឹងឲ្យល្បងលងព្រះមហោសថអ្នកប្រាជ្ញវិញទៀត

ទើបមានព្រះបន្ទូលប្រើអាមាត្យ មួយនាំពត៌មានចេញទៅឋានសិរីវឌ្ឍក-
សេដ្ឋី មួយអញ្ជើញនូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាមថា មានព្រះបន្ទូល
ពិសេសត្រាស់ប្រើមកកាន់អ្នក ឲ្យអ្នកដណ្តាំបាយជូរ ហើយឲ្យមានប្រ-
ការនោះតាំង ៧ ជំពូក មួយគឺមិនឲ្យយកអង្ករដណ្តាំ, មួយគឺមិនឲ្យយក
ទឹក, មួយគឺមិនឲ្យយកឆ្នាំង, មួយគឺមិនឲ្យដេកជើងក្រាន, មួយគឺមិនឲ្យ
យកភ្លើង, មួយគឺមិនឲ្យយកអុស, មួយគឺមិនឲ្យយកប្រុសឬស្រីដណ្តាំ,
កាលណាបើដណ្តាំបានជាបាយស្រេចហើយ មិនឲ្យដើរទៅដោយនូវផ្លូវ
ឡើយ, បើអ្នកដណ្តាំបាយនាំទៅថ្វាយបានមានសុភាពដូច្នេះ នេះក៏ជា
ការឥតទោសឡើយ, បើមិនបានដូចព្រះបន្ទូលបង្គាប់នេះហើយ ព្រះអង្គ
នឹងឲ្យត្រូវទោសព្រះរាជទណ្ឌជាដំណាំងមួយពាន់ជងផង ។ រីសិរីវឌ្ឍក
សេដ្ឋី នូវអស់អ្នកស្រុកមហាជនផងទាំងឡាយ ឮព្រះបន្ទូលដល់ហើយ
សឹងជិះគិតគាត់អាចិសេចក្តីប្រាជ្ញានោះពុំបានឡើយ ហើយនាំអាចិប្រស្នា
ទៅកាន់ព្រះមហោសថអ្នកប្រាជ្ញ ឲ្យព្រះអង្គពិចារណាដោះអាចិប្រស្នា
នោះហោង, ទើបព្រះមហោសថព្រះអង្គដឹងអាចិសេចក្តីប្រស្នានោះមិន
កំបាំងឡើយ, ទើបអ្នកថា ម្នាលគ្នាយើង កុំបីអ្នកទាំងឡាយគិតបារម្ភ
ឡើយ ជាភ្នាក់ងារអញឯង នាលោកថា មិនឲ្យយកអង្ករដណ្តាំនោះ
លោកថាឲ្យយកស្រូវវិញ, លោកថាមិនឲ្យយកទឹកនោះ លោកថា

ឲ្យយកបន្ទៀមវិញ, នាលោកថាមិនឲ្យយកថ្នាំងនោះ លោកឲ្យយកឯខ្ទះវិញ, នាលោកថាមិនឲ្យយកជើងក្រាននោះ លោកថាឲ្យយកឈើពោះពៅវិញ, នាលោកថាមិនឲ្យយកភ្លើងនោះ លោកប្រើវៀរភ្លើងយើងប្រក្រតី ហើយប្រើយកឫស្សីមកធ្វើជាពំនួតពួតយកភ្លើងជាថ្មីវិញ, លោកថាមិនឲ្យយកទុសនោះ លោកឲ្យលែងទុសឈើឫស្សីចេញ ហើយលោកឲ្យយកតែស្លឹកឈើមកដុតវិញ, នាលោកថាមិនឲ្យយកប្រុសដណ្ដាំ មិនឲ្យយកស្រីដណ្ដាំនោះ លោកឲ្យយកខ្ទើយដណ្ដាំវិញ, នាលោកថាមិនឲ្យដើរដោយផ្លូវទៅថ្វាយបាយដូរនោះ លោកប្រើឲ្យលះបង់នូវផ្លូវធ្លាប់, លោកឲ្យដើរកាត់ដំកាយដើងដើរទៅថ្វាយបាយដូរហោង ៗ រីអស់អ្នកផងទាំងឡាយ សឹងធ្វើខ្វល់ខ្វាយអណ្ដាប់ដោយបង្គាប់ព្រះមហោសថនោះហោង, ហើយឲ្យយកអម្បោះបង្កកថ្នាំង នាដណ្ដាំបាយដូរនោះ ឲ្យនាំទៅថ្វាយមហាក្សត្រាធិរាជនោះហោង ៗ បពិត្រអើយ, កាលនោះ បើមហាក្សត្រាធិរាជនោះជ្រាបសុភាពដូច្នោះហើយ ទើបមានព្រះបន្ទូលថា អើ! អ្នកឯណាអាចមានព្រះប្រាជ្ញាដោះអាថ៌ប្រស្នានេះហ្នឹង? អស់អ្នកផងទាំងឡាយក្រាបថ្វាយបង្គំទូលថា បពិត្រមហារាជអើយ! នាអស់អាថ៌ប្រស្នាទាំងនេះ មានតែព្រះមហោសថបុត្រគហបតីឯង អាចធ្វើជាប្រស្នាឲ្យដណ្ដាំបាយថ្វាយព្រះបាទម្ចាស់ឥឡូវនេះឯង, មហាក្សត្រាធិរាជ

ជ្រាបសុភាពដូច្នោះហើយ ស្តេចមានព្រះហឫទ័យដ៏ពេញនូវព្រះអំណរ អរគ្រៃពេកហោង ។

ពាលុកាតិ ខេះ ទឹងស្រដីពីការល្បងពួរខ្សាច់នោះវិញ ។ អបរស្មឹ ទិវសេ បណ្ឌិតសេដ្ឋី ឥមំ សនត្តិ តាមភសីនំ ភាសនំ បហិណឹសុ ។ ល ។ មានកាលសម័យថ្ងៃមួយ មហាក្សត្រាធិរាជស្តេចជំទិរះគិតទឹងអ្នកប្រាជ្ញ ៤ នោះស្រេច ស្តេចទឹងឲ្យល្បងលងព្រះមហោសថអ្នកប្រាជ្ញ ទើបព្រះអង្គឲ្យនាំពតិមានទៅកាន់សិរីវឌ្ឍកសេដ្ឋីថា ព្រះបន្ទូលពិសេសត្រាស់ប្រើយើងមកកាន់អ្នក នូវអស់អ្នកស្រុកប៉ាចីនយវមជ្ឈគ្រាមថា ដ្បិតព្រះមហាក្សត្រាធិរាជ មានព្រះបំណងទឹងចង់ឲ្យអស់អ្នកឯងវេញពួរខ្សាច់ទៅថ្វាយ ដ្បិតពួរហាស់អំពីបុរាណនោះគណ្តុរពុកាត់អស់ហើយ ឥឡូវនេះឲ្យអ្នកវេញជាថ្មី ឲ្យបាននាំទៅថ្វាយ, បើអ្នកវេញពួរនោះបានយកទៅថ្វាយ អើក៏ជាការឥតទោសឡើយ, បើពុំបាននាំពួរខ្សាច់នោះទៅថ្វាយទេ នោះយល់ជាអ្នកមានទោសធ្ងន់ ត្រូវព្រះរាជទណ្ឌជាជំណាំងមួយពាន់ដងហោង ។ កាលណាបើសិរីវឌ្ឍកសេដ្ឋី នូវអស់អ្នកផងទាំងឡាយ គិតហើយធ្ងល់ពុំអាចទឹងយល់អាថ៌ប្រស្នានោះឡើយ, ហើយនាំគ្នាទៅដណ្តឹងព្រះមហោសថអ្នកប្រាជ្ញ ទ្រង់ស្តាប់ពាក្យអ្នកផងទាំងឡាយដណ្តឹងដូច្នោះហើយ ក៏ព្រះអង្គរិះគិតដោយ

នូវព្រះប្រាជ្ញាទិព្វវិសេសឯងថា មានតែរិះគិតជាអាចប្រស្នាតបតទៅវិញ ទើបបាន, កាលណាអ្នកគិតស្រេចហើយស្រដីថា ម្នាលអស់អ្នកទាំងឡាយអើយ, កុំបីអស់អ្នកទាំងឡាយគិតឡើយ ទុកដាក់ឲ្យអញឯង ទើបអ្នកឲ្យទៅហៅអ្នកជំចេះដឹងកទូងជំឈ្លាសវៃសំដីបាន ៤ នាក់ហើយ ព្រះអង្គបង្គាប់ប្រាប់ថា ហៃអ្នកទាំងឡាយអើយ, ចូរអ្នកទាំងឡាយទៅក្រាបទូលព្រះមហាក្សត្រថា បពិត្រព្រះនារាយណ៍នរបតីស្រីសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអើយ ! វិសិរិវឌ្ឍកសេដ្ឋី នូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាម សឹងមកជំនុំគ្នាពិចារណា នឹងវេញពួរខ្សាច់នោះពុំអាចដឹងជាធំជាតូចដូចម្ដេចឡើយ, ហេតុនោះហោង ទើបឲ្យមកក្រាបទូលព្រះអង្គឲ្យសូមយកពួរខ្សាច់ចាស់អំពីបុរាណសំណល់ដែលគណ្ដាវាកាត់គង់មួយចំអាមក្ដី មួយហត្ថក្ដី ចូរព្រះអង្គឲ្យមកយើងខ្ញុំនឹងយកទៅជាក្បួននឹងមើលវេញ ឲ្យដូចអំពីបុរាណហោង ថាបើព្រះមហាក្សត្រាធិរាជមានព្រះបន្ទូលមកនឹងអ្នកទាំងឡាយថា ព្រះស្ដែងអើយ នាពួរខ្សាច់អំពីបុរាណនោះពុំដែលមានឡើយ, ម្នោះហើយអ្នកទាំងឡាយថ្វាយបង្គំប្រណម្យទូលឡើងវិញទៀតថា បពិត្រមហារាជអើយ ថាបើព្រះអង្គមានព្រះបន្ទូលថា ពួរខ្សាច់អំពីបុរាណពុំដែលមានដូច្នោះហើយ តើហេតុអ្វីព្រះអង្គប្រើទៅកាន់សិរីវឌ្ឍកសេដ្ឋី នូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាម ឲ្យវេញពួរខ្សាច់ថ្មី

មានក្លិនទៅក៏ បានយើងខ្ញុំទិញវិញបាន ថាបើឥតក្លិនហើយ តើទិញវិញដូចម្តេចបាន? បុរសនោះស្តាប់ពាក្យព្រះមហេសីហើយ ចាំទុកឥតសំណល់ដំកល់ក្នុងចិត្តស្រេច ហើយក្រាបលាព្រះមហេសី ឲ្យអ្នកប្រាជ្ញទៅធ្វើដូចបង្គាប់នោះហោង ។

បពិត្រអើយ, កាលណាបើព្រះមហាក្សត្រាធិរាជជ្រាបហើយ មានព្រះបន្ទូលដណ្តឹងថា អើ! អ្នកឯណាអាចមានគំនិតបេះអាចិប្រស្នាតបតមកដូច្នេះ តើប្រាជ្ញអ្នកឯណាឯងហ្នឹង ? ទើបបុរសនោះស្តាប់ព្រះបន្ទូលពិសេសត្រាស់ដណ្តឹងមកកាន់អាត្មា ហើយក្រាបទូលថា បពិត្រព្រះនរាយណ៍នរបតីស្រីសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ! សូមទានគឺប្រាជ្ញព្រះមហេសីបុត្រសិរីវឌ្ឍកសេដ្ឋីឯង ប្រើអស់យើងខ្ញុំនោះនាំអាចិប្រស្នាមកក្រាបទូលព្រះអង្គហោង ។ ព្រះមហាក្សត្រស្តាប់ហើយ ក៏មានព្រះហឫទ័យទោះ ដំពេញទូវព្រះអំណរអរក្រពេកហោង ។

ឥន្ទ្រាភគ្គិ ។ នេះ ទីស្រដីពីការលៀងស្រះនោះម៉ិញ ។ អបរស្មឹ ទិវសេ បណ្ណាកំ វីមំសនត្ថំ រាជា ឧទកកិទ្យំ កិទ្យតុកាមោ បញ្ហំវិជបនុមសញ្ញំ ទោក្ខារណី បេសេន្តុ អបេសេន្តានំ សហស្សទណ្ឌាណ្ហាតិ ។ល។

មានកាលសម័យថ្ងៃមួយវិញទៀត ព្រះមហាក្សត្រាធិរាជ ព្រះអង្គ

ប្រើរាជអាមាត្យមួយទៅកាន់សិរីវឌ្ឍកសេដ្ឋីថា ព្រះបន្ទូលពិសេសត្រាស់ប្រើឲ្យមកដល់អ្នក ដ្បិតមានព្រះបំណាំងនឹងចង់ស្រង់ទឹកស្រះ ដ្បិតស្ដេចជ្រាបសុភាពថា មហាបថកូនអ្នកបានជីកស្រះធំឧត្តមល្អ មានទឹកនោះជ្រៅជ្រះត្រចះថ្លា ដំដេរផ្កាសពាសទីទៅទូវឈូកទាំង ៥ ពណ៌ ប្រាសច្រាលរន្ទាលផ្អិនផ្អៀវដ៏រីកស្គុះស្គាយពណ្ណរាយ ហេតុនោះហោង ឲ្យអ្នកលើកស្រះនោះឲ្យផងទាំងទឹកទាំងដីទាំងឈូក ខ្ញុំឃាតសង្កាតនាំទៅឲ្យផាប់ប្រញាប់ទៅថ្វាយ ថាបើអ្នកបាននាំយកស្រះនោះទៅថ្វាយ ក៏ជាការផុតទោសឡើយ ថាបើពុំបាននាំទៅថ្វាយហើយ ក៏អ្នកនឹងមានទោសធ្ងន់ ត្រូវព្រះរាជទណ្ឌជាដំណាំងមួយពាន់ដុនពុំលែងឡើយ ។ រីឯសិរីវឌ្ឍកសេដ្ឋីនូវអស់អ្នកស្រុកបាចីនយវមជ្ឈគ្រាមនោះ ឮព្រះបន្ទូលដូច្នោះហើយក៏សឹងមកជុំគ្នា ពុំអាចដើម្បីនឹងដឹងអាថ៌ប្រស្នានោះបានឡើយ ហើយសិរីវឌ្ឍកសេដ្ឋីឲ្យទៅដណ្ដឹងសួរពោធិសត្វ លុះពោធិសត្វស្ដាប់តែពាក្យអស់អ្នកផងទាំងនោះប្រាប់សព្វប្រការហើយ ព្រះអង្គដឹងអស់អាថ៌ប្រស្នានោះពុំកំបាំងឡើយ ហើយទើបអ្នកគិតថា ប្រស្នានេះដូច្នេះហើយគេ មានតែរះជាអាថ៌ប្រស្នាឲ្យតបតស្នងទៅវិញទើបបានអេះ ព្រះអង្គរិះគិតដូច្នោះហើយ ឲ្យទៅហៅអ្នកដំបេះគន្ទាសឈ្មោសសំដីនោះមកដល់ហើយទើបព្រះអង្គបង្គាប់ប្រាប់ថា ម្នាលគ្នាយើងអើយ ចូរគ្នាយើងទៅលេង

ទឹកមានឲ្យក្អែកនោះក្រហមប្រាល ឲ្យមានសក់នោះទទឹក ដ៏មានសំពត់សំលៀកនោះសឹងទទឹក ហើយមានខ្លួននោះសឹងប្រឡាក់នូវភក់ ហើយមានដៃនោះកាន់នូវព្រ័ត្រត្បូវល្វិដំបងព្រននង់អង្រែ ហើយរត់ទៅកាន់ទ្វារព្រះរាជវាំងបើគេទៅក្រាបទូលហើយ សន្សឹមចូលទៅឲ្យបានដល់យល់ព្រះមហាក្សត្រាធិរាជ ហើយក្រាបថ្វាយបង្គំប្រណម្យទូលថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ដ្បិតព្រះអង្គប្រើរាជអាមាត្យទៅកាន់សិរីវឌ្ឍកសេដ្ឋី នូវអស់អ្នកស្រុកបាបីនយវមជ្ឈគ្រាម ប្រើឲ្យស្រះមកថ្វាយព្រះអង្គនោះមិញ អស់យើងខ្ញុំមកជំនុំគ្នា យល់ស្រះមួយនោះធំសមគួរនឹងព្រះអង្គ យើងខ្ញុំយកព្រ័ត្រត្បូវបងគ្រៀកទីងសន្ទឹងទង់កើបមក យកដំបងព្រននំគៀងគាំទាំមកថ្វាយព្រះអង្គ។ រីស្រះនោះធ្លាប់តែនៅព្រៃមិនដែលប្រសព្វនឹងមនុស្សម្នាមហាជនផងទាំងឡាយ នូវរទេះដំរីសេះផង សឹងតែដើរទៅវិញទៅមកពុំដែលស្គាត់ឡើយ, រីឯស្រះនោះមិញភ្ញាក់ផ្អើលភិតខ្លាចបំរះប្រាសព្រាត់ទៅមកជាប់ព្រ័ត្រត្បូវផង វាផ្ទះស្ទុះរត់រួចទៅហោង ។ សូមទានយើងបានអង្រែព្រននំដំបងតាមដេញជិតម្រកិតរត់ដើងស្កាត់ទៅពុំអាចនឹងទាន់ឡើយ វារត់ជ្រលួសហួសទៅនាលំនៅព្រៃដដែលវិញហោង ។

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងមរណមាតា

(តមក)

លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រស្លឹករឹត

---

សារិកាកែវកល្យាណ ប្រាប់ដើមដានសារសេចក្ដី បពិត្រម្ចាស់សិរីសេស្ដេចកណ្ដុរសេវថ្លៃថ្លា ៗ ឯនាមខ្ញុំម្ចាស់នោះ សន្មតឈ្មោះនាងសារិកា កណ្ដុរស្ដាប់វាចា សួរទៀតថានៃមាសថ្លៃ ៗ ហេតុម្ដេចគេចោចស្ងាប ពេមជកបឥតអាស្រ័យ គ្មានគង់មួយសរសៃ ចូរមាសថ្លៃប្រាប់យើងក៏ ៗ នាងប្រាប់ថាខ្លួនខ្ញុំ ក្សត្រឧត្ដមទ្រង់មេត្តា ចិញ្ចឹមខ្ញុំនេះណា ឲ្យរក្សាទីបន្ទំ ៗ ឥឡូវនេះព្រះអង្គ លើកបត្រង្គសេនាធំ ទៅប្រាប់ខ្មាំងពិតពុំ– ទាន់វិលវិលមកភាក ៗ មានសំម្នាក់ចិត្តកាច ចោរកំណាចជ្រើសពាធា នាមឈ្មោះនាងធន្លា វាចាប់ខ្ញុំទីងសម្លាប់ ៗ ប្រើខ្ញុំស្រីម្នាក់ខ្លួច ឲ្យវាចោចពេមប្រញាប់ ហើយឲ្យចំញាំកាប់ សាច់ឆ្អឹងខ្ញុំទីងខសុំ ៗ ចោចរូបមេពាសី ចុះទៅដីដើរឆ្ងាយពី ឯខ្ញុំរត់បាកទុំ មកពឹងពួននៅនេះហោង ៗ ខ្លួនខ្ញុំកំព្រាក្រៃ ឥតអាស្រ័យទីពឹងផង ខ្ញុំសុំអ្នកជាបង ឲ្យនៅផងដោយមេត្តា ៗ ទម្រាំដុះពេមស្លាប

គ្រប់ដកបរិវត្តា លុះជាខ្លួនកាលណា ខ្ញុំនឹងក្រាបលាទៅហោង ។ កណ្តុរស្តាប់សារិកា អង្វរថាសុំនៅផង ហើយសុំខ្លួនជាបង មានចិត្តគិតទឹកមេត្តា ។ សង្វេគទឹកអាណិត ផ្អន់ផ្អែតផ្អិតណែនទុក ហើយលួងលោមទៅថា ហៃប្អូនក្ងាមាសបងអើយ ។ តាំងពីថ្ងៃនេះទៅ ប្អូននាងនៅកុំភ័យឡើយ នាងនៅនឹងបងហើយ កុំបារម្ភនឹងភោគ្គា ។ សឹមបងប្រើសព្វពល ចេញខ្វាយខ្វល់គ្រប់ទិសា រកអស់តាំងភោជនា ចិញ្ចឹមនាងឲ្យសប្បាយ ។ រីឯមេធ្មា ចិត្តឫស្យាពោរអន្តរាយ ធ្វើតោះប្អូនតាមឆាយ បងធានាសម្លាប់ភ ។ នាងស្តាប់ឆ្លើយសាសងកុំអ្នកបងចង់វេក ព្រោះក្រែងមានពៀរនឹងគ្នា តទៅមុខទៀតមិនខាន ។ មួយទៀតគេជាមនុស្ស ខ្លួនធំខ្ពស់កំលាំងមាន យើងជាសត្វតិរច្ឆានខ្លួនតូចទាបកំលាំងតិច ។ ទឹងយុទ្ធទឹងតតាំង ប៉ះកំលាំងគេដូចម្តេចខ្លួនយើងកំលាំងតិច សូមអ្នកបងស្ងៀមទៅជា ។ កណ្តុរសុបានស្តាប់នាងសាស័ព្ទឃាត់កាំងក ឆ្លើយថាប្អូនកុំរ៉ា បងពុំព្រឹកោមរូបប្រាណ ។ មិនស្មើមនឹងឆន្ទា កំលាំងក៏មានចុំនាន យើងជាសត្វតិរច្ឆាន មិនខ្សោយប្រាណទេប្អូនអាយ ។ ទើបស្តេចកណ្តុរសុ ប្រើអស់បរិវារតាំងឡាយ ឲ្យចេញទៅខ្វល់ខ្វាយ ពាំកប្បាសគរសំឡី ។ យកមករៀបសសាប់ សរសោះព្រាប់ក្រាលលើដី រៀបឲ្យនាងបក្សី សារិកា

តែនាងទិទ្រា ៗ ទីមួយឲ្យនាងផ្ទុំ ជាទ្រង់ក្សត្តិយា ទីពីរឲ្យលីលា ដើរលេងជាសព្វថ្ងៃទៅ ៗ ស្រេចហើយចាត់ពលា ឲ្យនាំគ្នាប្រើនខ្មល ខ្មៅ កកាយរូងឲ្យជ្រៅ ធំទូលាយឥតគណនា ៗ ហើយប្រើអស់ពួក ពល ឲ្យខ្វាយខ្វល់គ្រប់ៗគ្នា រកសុភោជនា បេកទៀបទុំទំចំណី ៗ សំណែកស្រូវយ៉ាងល្អ ពោតប្រៅល្ងទាំងទុំខ្ចី គាត់ពាំនាំឃ្លាតខ្ចី យកមក ជូននាងសារិកា ៗ បរិភោគជាប្រក្រតី ឆ្អែតឥតបីមានទុក្ខា តាំងពី ថ្ងៃនោះណា នាងបានសុខឥតទុក្ខភ័យ ៗ ដោយសារស្តេចកណ្ដុរ- សទិ- មិលមានគុណក្រៃ ប្រណីនាងស្រីថ្លៃ ហាក់ដូចប្អូនឯកឧទរ ៗ សារិកា តែកល្យាណ បានសុខសាន្តឥតភ័យមរណ៍ ក្នុងចិត្តគិតគូរ ជាព្រះ រៀមរាជស្វាមី ៗ សព្វថ្ងៃទោះល្ងាចព្រឹក តែងក្នុកនឹកពល់រាត្រី ថាន ព្រះចក្រី ម៉្លេះសមស្ដេចវិលយាត្រា ៗ យាងមកពុំទាន់ដល់ រាជមណ្ឌល ក្រុងរដ្ឋា ឬពុំបានយាត្រា ឬមានហេតុម្ដេចក៏បាត់ ៗ ស្តេចពុំជ្រាបថា ខ្ញុំ កើតទុក្ខធំមកប្រាសព្រាត់ ចាកចោលប្រាសាទរ័ត្ន មកលំបាកនៅ ក្នុងដី ៗ បើស្តេចជ្រាបថាខ្ញុំ បាត់ហើយសមព្រះចក្រី ចាត់ប្រើពល សេនីយ ឲ្យតែរកសព្វព្រឹក្សា ៗ នេះម្ដេចក៏មកបាត់ ទាំងមហាក្សត្រនូវ សេនា ម៉្លេះហើយសមក្សត្រា ស្ដេចសព្វាយប្រពាតព្រៃ ៗ

នាងនឹកដល់កស្ត ធៀងនេត្រាគយរំពៃ កើតទុក្ខកន្លងហឫទ័យ ក្រៀម
ក្រំក្រព្រួលនេត្រា ៗ ពុំស្រាកពុំស្រាន្តស្រាល ពុំស្រយាលពីទុក្ខា
ផ្អែតផ្អិតក្នុងឧរា ព្រោះឃ្លាតឃ្លាចាកមេត្រី ៗ នាងទៅក្នុងរូងបាន
ជុះស្លាបបានដូចប្រក្រតី ប៉ុន្តែស្លាបនៅខ្ចី ហើរពុំបានទន់បក្ខា ៗ

ឯគាធិរសំ មូសិកាំចិន្តា មានកាលថ្ងៃមួយណា រីឯស្តេច
កណ្ដុរស ៗ នឹកខឹងនឹងធន្លា ចាប់សារិកាជាសត្វល្អ រាំបោចស្លាបខ្លួន
ឲ្យលំបាកស្មើរមរណា ៗ កណ្ដុរគិតព្យាបាទ ចងពិឃាតនាងធន្លា
លុះយប់ចូលសន្យា ស្ដេចកណ្ដុរចេញចាករន្ធ ៗ ឡើងលើផ្ទះធន្លា
ស្រីត្រៀបត្រាច្រើនលើសលន់ កណ្ដុររាវគយគន់ ររកមើលនាងធន្លា ៗ
ឃើញតែពួកទាសី ដេកប្រក្រតីពេញគ្រឹហា ពុំស្គាល់នាងធន្លា រូប
ដូចមេ្តចខ្មៅឬស ៗ កណ្ដុររាវមើលគ្រប់ ល្វែងបន្ទប់ខែនទីល្អ សព្វ
ប្រកដ្រុងត ៗ គ្មានចន្លោះបល់គ្រង់ណា ៗ ហើយស្ទុះចូលទៅក្នុង
រាវដេប់គ្រង់គ្រែក្រឡា ធន្លាលក់សេយ្យា ពិតពុំដឹងខ្លួនសូន្យសោះ ៗ
កណ្ដុរឃើញរូបប្លែក ល្អបម្លែកគេទាំងអស់ មុខមាត់ក៏ស្រស់បស់ ថា
នេះហើយនាងធន្លា ៗ ប្រាកដពិតពុំខុស គិតហើយស្ទុះឡើងមិម្មា
លើគ្រែនាងធន្លា លោលោតផ្លោះទាំប្រមុះ ៗ ខាំម្ដងជាប់កំបុត ពាំ
សាច់រត់រំពេចចុះ ដល់ដីហើយកាលណោះ ឯធន្លាភ្ញាក់អាត្មា ៗ ឈឺ

ចាប់ចេញឈាមប្រាល ទែងរន្ទាលពេញកាយា ស្រែកហៅអស់ពួកពល ថ្ងូរហ៊ឺះៗ ឮឡឺៗ ៗ ដោយដាច់ច្រមុះធេង ថ្ងែកសម្លេងសូរគ្រលរ ស្រែកចេញឮឡឺៗ ពួកបរិវារស្តាប់មិនបាន ៗ ស្រីខ្លះស្ទុះចូលទៅ ឃើញឈាមខ្មៅប្រាលអស់ប្រាណ មើលមុខស្គាល់មិនបាន ទាំងសំដីមិនដូចមុន ៗ ច្រមុះដាច់គ្រហូ ឈរមើលយូរខ្លាចពេកពន់ ញ័ររខ្លួនដូចគេគ្រុន រត់ចេញក្រៅថាយើៗ ៗ ខ្លះថាហងវាចី សួរមិនស្តីមេខែមណី ខ្លះចូលមើលថាយី អ្នកនាងបីកំក្រឡិត ៗ ខ្លះឆ្លើយថាម៉ាយទេ សឹមយើងកែឲ្យអស់ចិត្ត គិតសូនក្រមួនបិទ យកតែល្អចេតមួយគ្រា ៗ ខ្លះដេរថាមីចោរ ស្តីឡែឡេាពាក្យមាយា មិនចេះគិតវេទនា អាណិតអ្នកឈឺខ្ទូរទន់ ៗ មេខ្លះឆ្លើយថាអើ ហងគ្រាន់បើមិនគួរគេន់ វាយលេខហោរទព្វន្ត ខ្មោចអ៊ីវាធ្វើកញ្ចិត ៗ បើកក្បួនបើកតម្រា មើលជតាឲ្យអស់ចិត្ត ច្រមុះអ្នកកញ្ចិត បិទក្រមួនជាប្តូរទេ ? ៗ មេមួយឆ្លើយទៅវិញ ថាអញជ្រេញមេមុខឆ្កែ ទេន្ទេញពាក្យថៃ ៗ គ្មានគិតតែតរកថ្នាំ ៗ ណ្ហើយចុះហងកុំស្តី មេអប្រិយស្តីសាំញ៉ាំ ជជែករកគ្គិកាំ ដើរចេញចាប់មេចង្រៃ ៗ រីឯមេធន្ទា រងវេរពលឈឺជូនក្រែ ស្រយង់អស់សរសៃ ពិសពើតចាប់ញ័រអស់ប្រាណ ៗ ឯអស់ស្រីនានា ចាត់គ្នីគ្នារត់សព្វឋាន យកពេទ្យថ្នាំមកបាន ផ្សំថ្នាំបិទមិនបាត់ឈាម ៗ ឃាត់ឈាម

មិនបាត់សោះ គ្រប់ទាំងអស់ឡើងទីមទាម សែកមន្តផាសយ៉ាត់ឈ្នះម
ផ្សំថ្នាំបិទមិនជល់សោះ ៗ បាញ់ឈាមព្រួសពាសពេញ ហូរខ្លួរខ្ទាញ់
មកស្រស់ ៗ ឆន្ទាថ្ងូរខ្សាចសោះ ថ្ងស់មុខស្ងាំងអាប់ស្មើ ៗ ខុនណាង
ពួកអស់អ្នក មើលយល់ជាក់ច្បាស់អស់ក្តី ខ្ទះថាឯងមើលរុី ដូចស្នាម
មាត់កណ្តុរខាំ ៗ មេមួយថាអញច្បាស់ គិតមិនយល់កណ្តុរខាំ កណ្តុរ
ម្តេចធំម៉ាំ ឆក់តែម្តងជាប់កញ្ចិត ៗ មេមួយអស់សំណើច ហាមាត់
សើចយកដៃបិទ ខ្ទះថាវ៉ុយគោតចិត្ត ហ៊ានហាសើចមិនអនិច្ចា ៗ
ឆន្ទាឈឺចុកសៀត ដើរមកក្បៀតអន្ទះសា ពើតបាប់សព្វកាយា ពេទ្យ
អាគមផ្លុំមិនបាត់ ៗ ពេទ្យថ្នាំបិទមិនបាន ឈឺញ័រប្រាណដើមប្រមាត់
ចេញឈាមហូរមិនបាត់ ហូរខ្លួរខ្ទាញ់ពេញកាយា ៗ អស់ពេទ្យថ្នាំ
អាគម ថែបប់ធំតាល់ប្រាជ្ញា អន្ទុយស៊ីតែស្លា ឧបជង្គង់ដង្ហើមធំ ៗ
ឆន្ទាឈឺខ្លាំងក្រៃ ហាក់ហៀបក្ស័យដល់ស្រែកយំ ខ្លារទ្រូងជាប់ជុំ ៗ
ប្រះនទៀលប្រែផ្កាប់ផ្ងារ ៗ កម្មព្រោះប្រើតាសី ឲ្យញក់ញ៉ីបោច
សារិកា ឲ្យនាងវេរវេទនា កម្មនេះឯងតាមថ្មី ៗ ៗ ឯស្តេច
កណ្តុរស ខាំហើយអរលោតចុះដី បោលចូលរូងឃ្លាតខ្ចី ដល់
ហើយប្រាប់នាងសារិកា ៗ ថាមេឆន្ទានោះ អស់បានរស់ជាមនុស្ស
បងខាំត្រូវមុខា ជាប់ប្រមុះជ្រុះទៅហើយ ៗ កាឈឺខ្លាំងស្រែកយំ

ដៃជាលដំទ្រូងមិនស្បើយ សម្ទេនយំព្រលើយ ដប់ថ្ងៃទៀតស្លាប់មិនខាន ។ ឯនាងសារិកាស្ដាប់ កណ្ដុរប្រាប់ភ័យញ័រប្រាណ កើតទុក្ខទៀតមិនក្សាន្ត ថាទុះទុមេធ្វា ។ វាប្រើអស់ពួកពល រកកណ្ដុរកូនត្រីហា បើឃើញកណ្ដុរវា ឃើញទាំងខ្លួនអញនេះផង ។ ឥឡូវអញដុះស្លាប គ្រប់ដកបអស់ហើយហោង ល្មមតែឲ្យកន្ទង អំពីភ័យពេលនេះណា ។ សារិកាគិតដូច្នោះ ហើយក្រោកចុះចរយាត្រា អង្វរកណ្ដុរថា អ្នកមានគុណធ្ងន់ក្រាស់ក្រៃ ។ ដូចមាតាបិតា ថែរក្សាខ្ញុំសព្វថ្ងៃ ពុំគួរឲ្យឃ្លាតឃ្លៃ គួរតែនៅតបគុណអ្នក ។ ដកបអស់ជីវិតទៅនៃបនិត្យវៃឆ័រួមក្ស គាល់ហៀបំរើអ្នក ជាព្រះរៀមពជបេស្ដា ។ គឺមោះខ្ញុំបារម្ភ ដ្បិតខ្លួនខ្ញុំមានទោសា ធន្ទាក់ឫស្សា តាមពាណាធ្វើទោសខ្ញុំ ។ ហេតុនេះសូមក្រាបលា អម្ចាស់ជាប្អូនសូមសុំ អនុញាតបើកឲ្យខ្ញុំ បានចេញពាក់រួចពីភ័យ ។ កណ្ដុរស្ដាប់សារិកា លាគ្នាដូច្នោះវៃ ខ្សឹកខ្សួលអួលហឫទ័យ និកអាណិតនាងសារិកា ។ ដោយធ្លាប់នៅប្រក្រតី ឲ្យចំណីបរិភោគ្គា ធ្លាប់ថៃធ្លាប់រក្សា ធ្លាប់សាន្តសុខកន្ទុហឫទ័យ ។ មិនដែលឲ្យលំបាក ទាបតោកយាកដល់មួយថ្ងៃ ក្រៃដើរវង្វេនព្រៃ គ្មានអ្នកណាជូនជាគ្នា ។ ចរអើស្លាបនៅខ្ចី ដើរដោយដីក្រៃជួនជា ប្រទះនឹងមនុស្សម្នា វាចាប់យកធ្វើទោសពៃរ៍ ។ គិត

ហើយឃាត់តៅថា ហៃប្អូនក្លាដួងហឫទ័យ សូមឃាត់ប្អូនមាសថ្លៃ កុំគាល បរចេញយាត្រា ៗ ខ្ញុំប្អូនមិនទាន់សះ ជាស្រឡះក្នុងកាយា ចំរេង ស្លាបក្តីណា នៅខ្ចីទន់ហើរពុំបាន ៗ បងឃាត់ប្អូនមាសស្នេហ៍ ទំរាំ តែជាក្នុងព្រាណ មួយក្រែងដើរអត់ឃ្លាន គ្មានចំណីបរិភោក្តា ៗ សារិ· កាស្តាប់ហើយថា សូមមេត្តាខ្ញុំសូមលា កុំម្ចាស់ព្រួយចិត្តា ខ្លួនខ្ញុំ ក្រែងអត់ឃ្លាន ៗ លែងតែទ្រង់បើកខ្ញុំ ហើយសូមសុំពរប្រទាន ឲ្យខ្ញុំ អម្ចាស់មាន ការសុខស្រួលបើយាត្រា ៗ កណ្តុរឃាត់សាសង ពីរ បីដងដោយមេត្តា រីឯនាងសារិកា ពុំព្រមនៅជូហេ្មះនៃ ៗ កណ្តុរយក ចំណី ទាំងទុំខ្ចីឲ្យអាស្រ័យ បរិភោគឆ្អែតឆ្អន់ក្រៃ លុះព្រលប់យប់ សន្ធ្យា ៗ សារិកាលាវិលចរ កណ្តុរសឲ្យបរិពារ ហែបក្សីសារិកា ជូនដំណើរទាំងរាត្រី ៗ ហែមុខនាងប្រាំរយ មានហែក្រោយនាងបក្សី បន្ទាប្ទុះស្នោក្តី កណ្តុរនាំជាមាគ៌ា ៗ ទោះបីដីខ្ពស់ទាប កណ្តុរប្រាប រាបស្មើគ្នា រលីងដូចផ្លូវថ្លា ពីបុរាណរៀងប្រក្រតី ៗ សារិកាកែវការេ នោះ ស្លាបទើបដុះនៅទន់ខ្ចី ហេតុនោះនាងដើរដី តាមកណ្តុរនាំ មាគ៌ា ៗ ដើរតាំងពីព្រលប់ មិនហ៊ានឈប់ឈរពេក ដើរដល់យល់ នាយទ្វារ ចាំយាមល្បាតមិនដេកសោះ ៗ ចេញតាមទ្វារពុំបាន ដើររុក រានរកចន្លោះ គេប្រកគ្នាទសូឲ្យសោះ សឹងកំពែងឥដ្ឋបាយអ ៗ កំពែង

ប្រាំពីរជាន់ ដាប់ដាក់ស្បាន់ឥដ្ឋលាយថ្ម គ្រប់ថែងលាយបាយអ រកចន្លោះចេញពុំបាន ។ សារិកាគន់គិតថា ទាល់ប្រាជ្ញាឈប់សម្រាន្ត កណ្ដុរសតិតម្បាន នាំអស់ពលខាំបាយអ ។ ខាំឥដ្ឋធ្លាក់ខ្ចាត់ខ្ចាយ ដើងកកាយកកេរថ្ម ថ្មបែកធ្លុះប្រហ នាំសារិការួចចេញបាន ។ កណ្ដុរនាំសារិកា ចរយាត្រាដល់ក្រៅឋាន កំពែងក្រៅប៉ុន្មាន កណ្ដុរខាំធ្លុះគ្មានសល់ ។ ប្រាំពីរជាន់កំពែង ក្រាស់ក្រួរស្មែងដោយគិតយល់ កកេរធ្លាយគ្មានសស់ ធំទូលាយជាមាគ៌ា ។ កណ្ដុរជូននាងទៅ ហួសលំនៅផ្ទះមនុស្សម្នា ចូលក្នុងព្រៃអដ្ឋា ឈើគ្រសុំផ្គុំល្អ ។ នាងលាស្ដេចកណ្ដុរ សទិមិលចិត្តស្មោះសរ កណ្ដុរលានាងចរ វិលមកនៅឋានថេរថិត ។ លុះព្រឹកនាងសារិកា រកព្រឹក្សាព្រៃស្បាតជិត លាក់ខ្លួនពួននៅនិត្យ ស៊ីផ្លែឈើត្រួយស្មៅខ្ចី ។ ផ្អែតផ្អល់ស្កល់ក្នុងចិត្ត លែងភ័យភិតលុះកន្ត្រី នាងចេញដើរដោយដី វៀងកល់យប់មិនឈប់ខាន ។ គម្រប់ ១០ ថ្ងៃច្បាស់ ដុះរោមក្រាស់ហើរឡើងបាន នាងហើរចេញចាកឋាន ផ្ដោះជម្រង់ព្រៃធំនោះ ។

និងថ្ងៃងពីធន្នា កាចឬស្យាចិត្តមិត្រទ្រុស្ដ កាលកណ្ដុរខាំនោះ ដាច់ប្រមុះជ្រុះបាត់ទៅ ។ គ្រូថ្នាំគ្រូអាគម ទាល់ស្ដោះផ្ញុំស្មៀមនិត្យ នៅ ដំបៅរូងកលជ្រៅ កលជាលរាលធំមហិមា ។ ខាងលើពល

ដល់ក្អែក ជាប់សាច់ស្បែកជ្រុះគ្រាំគ្រា រងទុក្ខវេទនាឈឺ
ទូរទន់ជូនជួលជាប ៗ គត់ចាយគ្រប់ដប់ថ្ងៃ ស្គាំងស្គមក្រៃសរមេងរ៉ាប
កូទស្អុយជុំផ្អេះផ្អាប ជាប់កំលាំងក្បែរជន្មា ៗ

ពីរឿងធ្នាស្លាប់ ស្ទះវែងចាប់ជួបពណ៌នា ថ្ងៃតីទានជាយា
សារិកាកែវកាលហើរចាន ៗ នាងហើរទន្ទាបទំ លើឈើធំឈើច
សម្រាន្ត មានពស់កាចសាមាឡ នៅក្នុងរូងរន្ធឈើនោះ ពស់
ឃើញនាងសារិកា ចិត្តឫស្សាកាចច្រេវច្រុស្ត បង់ចឹកសារិកានោះ យក
បរិភោគជាភោជនា ៗ កាលនោះមានបក្សី ក្នុងបាលីថាសកុណា
បើប្រែឲ្យពិស្តារ ជាពាក្យសត្វថាតាដក់ ៗ លលាដ៍ក្បាលរលីង
ធំទ្រមឹងគ្មានផុះសក់ សត្វនោះពេញអាក្រក់ ជើងវែងពេកខ្ពស់ជំហរ ៗ
មានសាច់មួយជុំទើរ ដូចគេផ្ញើនៅដើមក បុកណាស្រដីត ប្រាប់កូន
ចៅថាយាមវ៉ា ៗ តាដក់ហើរមកទំ ជិតទ្រនំនាងសារិកា ឃើញ
ពស់ចិត្តឫស្សា បង់ចឹកនាងសារិកានោះ ៗ តាដក់លោតទៅចឹក
ចាប់ប្រញាំកទីងចំពុះ រីឯពស់វែកនោះ ចឹកតាដក់ជាសត្រូវ ៗ
សត្វពីរប្រខាំគ្នា ស្មើពលាចិត្តឃោរឃៅ ប្រខាំគ្នាយូរទៅ ស្លាប់-
អាំងពីរកាលនោះណា ៗ សារិកាមើលយល់ជាក់ ភិតភ្ញាក់
ញ័រកាយា នាងហើររកព្រឹក្សា ដទៃទៀតទំសម្រាន្ត ៗ នាងនឹក

ដល់កស្ត អួលឧកផតស្រោកស្រាទ្ធ ថាឱមហាក្សត្រក្សត្ត ស្តេចប្រពាត ទីឋានណា ៗ ឬមួយក្សត្រឧត្តម វិលបមេកដរដ្ឋា ឱទ្រូងខ្ញុំខ្ទោប ផ្សា កើតទុក្ខត្រូតព្រួតច្រើនក្រៃ ៗ ទុក្ខមួយព្រោះកំណើត ក្លាយមក កើតជាបក្ស ទុក្ខមួយព្រាត់ស្វាមី ព្រាត់អស់ស្នំក្រុមបរិវារ ៗ ទុក្ខមួយមិនដឹងផ្លូវ ទីលំនៅទេពធីតា ដែលព្រោសព្រោណអាត្មា នឹងសុំថ្វាយលេបប្រែប្រាណ ៗ ឲ្យក្លាយជាមនុស្ស នឹងយាត្រាវិលទៅ ឋាន ឥឡូវជាតិរច្ឆាន រងលំបាកសែនវេទនា ៗ

បទពំនោល

តេជៈហេតុបុណ្យសម្ភារ បុណ្យនាងធីតា វិសាលវិសេសថ្កើងថ្កុល ៗ កក្រើកអំពើតទៅដល់ ក្រឡាកម្ពល មណ្ឌលមន្ទីរកោស្នា ៗ អមរិន្ទអង្គ ឥន្ទ្រឧណ្ហា ក្តៅក្តាត់មហិមា ឧបមាបីដូចអគ្គី ៗ អុជអាលុះពេលពលញាក់ ញី ក្តួលក្តៅទេនទី ទ្រង់ផ្ទុំសំពត្តពិស្តុល់ ៗ បែរបើកទិព្វចក្ខុទៅយល់ ទតទាំងមណ្ឌល សកលជម្ពូទ្វីបា ៗ ទតសត្វយល់នាងសារិកា ទួញទល់ ទុក្ខា អនាថអាណិតអង្គឯង ៗ លុទ្ធដល់ទ្នោបកណ្តាង ក្នុងព្រៃធំធេង ជាសត្វតិរច្ឆានបក្សី ៗ ហេតុនាងបានសាងបារមី សម្តេចកោសីយ ក៏ ប្រោបសព្វគ្រប់ប្រការ ៗ ថានាងជាពុទ្ធមាតា មេត្តាប្រែក្រឡា ជាសត្វ តិរច្ឆានព្រោសព្រាត់ ៗ ពុំគួរឡើងទៅជាសត្វ តិរច្ឆានសូន្យស្ងាត់ គួរអញ

សង្គ្រោះធីតា ៗ ឲ្យនាងកើតជាមនុស្ស គិតស្រេចយាត្រា ហិចហោះ
ចេញចាកវិមាន ៗ មកដល់ព្រៃធំទីឋាន និម្មិតប្រែប្រាណ ជាខ្លាធំធាត់
មហិមា ៗ ចំពោះមុខនាងជាយា ឯនាងសារិកា ក៏ទតយល់ខ្លាធំនោះ ៗ
ឯខ្លាឃើញនាងទតស្មោះ ទើបខ្លាលោតផ្លោះ ស្ទុះឡើងលើព្រៃសាខា ៗ
ស៊ីផ្លែព្រៃមកបច្ចិមា ក្លាយជាបក្សា នាមាពុំបានសំដែង ៗ បក្សា
មហិមាខះខែង ហើរទំលោតលេង មែកខាងឧត្តរទិសា ៗ ចឹកស៊ីផ្លែ
ព្រៃសាខា ប្រែក្លាយកាយា ជាប្រើសមាសមៃឆ្អិនឆ្អៅ ៗ ប្រើសមាសបែរ
ពោលទៀតទៅ ស៊ីផ្លែព្រៃនៅ មែកខាងឯបូព៌ទិសា ៗ ប្រើសប្រែខ្លួន
ក្លាយជាស្វា ស្វាលោតម្នីម្នា ទៅមែកទក្សិណឈប់នៅ ៗ បេះផ្លែ
មែកនោះស៊ីទៅ ប្រែប្រាណដោយនៅ អានុភាពឧសថផ្លែថ្លា ៗ ក្លាយ
ខ្លួនកើតជាមនុស្ស ល្អល្អះជ្រះថ្លា គ្រមុំកម្លាំងទិភយ ៗ កាយាល្អ
ល្អះល្មមល្មៃ មុខមាត់ល្អក្រៃ គ្រប់គ្រង់ជ្រះថ្លា ៗ មានធ្មឹមអម្ពរកស្ត្រ
ស្រោបនៅកាយា ដ៏ប្រាលរន្ទាលព្រោងព្រោយ ៗ សឹងគ្រឿងទិព្វទេស
ចេតឆាយ ដាំត្បូងក្លំសាយ ពៃទូរ្យសុរិកាន្តមុក្តា ៗ ស្រេចហើយ
ចុះចាកព្រឹក្សា ដើរដោយគន្លា បានតបនិម្មិតបាត់ទៅ ៗ ប្រែជាអង្គឥន្ទ្រ
ចមទៅ ហិចហោះឡើងទៅ វិមានសួគ៌ត្រៃត្រឹង្ស ៗ តំសកកុណាំធិស្ត្រា
រីនាងសារិកា ក៏ទតយល់សព្វសេចក្តី ៗ នាងគិតថាអង្គកោសីយ អម្រិន្ទ្រ-

ធិបតី ហិចហោះចុះចាកសួគ៌ា ។ មកប្រាប់ទុសថសោភា ឲ្យអញបានជា មនុស្សដូចអំពីមុនមិញ ។ បើបោះគួរគប្បីអញ ស៊ីផ្លែជ្រៃវិញ នឹងបានដូចចិត្តប្រាថ្នា ។ គិតហើយហើរពីព្រឹក្សា ទំលើសាខា មែកជ្រៃបស្ចិមនោះឯង ។ ចឹកស៊ីផ្លែជ្រៃទុំខែង ក្លាយខ្លួនជាក់ស្តែង ជាសត្វបក្សាធំក្រៃ ។ បក្សាហិចហើរវិលវៃ ទៅទំមែកជ្រៃ នៃខាងឧត្តរទិសា ។ ចឹកផ្លែជ្រៃមែកឧត្តរា លេបទៅកាលណា ក៏កើតជាប្រើសមាសឆ្នៅ ។ ប្រើសមាសលោលោតទៀតទៅ ស៊ីផ្លែជ្រៃនៅ មែកខាងឯបូព៌ទិសា ។ ប្រែកាយក្លាយកើតជាស្វា ស្វាលោតសោះសា ទៅមែកទិសទក្សិណទី ។ ស្វាបេះប្រឡេះផ្លែស៊ី ប្រែកាយឥន្ទ្រីយ ជាមនុស្សស្រស់ស្រៀវកាយា ។ ដួងភក្ត្រត្រចះជ្រះថ្លា មានគ្រឿងវេទនា ប្រដាប់ស្រោប់ស្រេចគ្រប់ង៉ ។ កបកាយធេតធាយបញ្ចង្គ ល្វាសល្ងទ់អស់អង្គ ប្រៀបដូចស្រីទេពអប្សរ ។ នាងមានចិត្តកក្ខគ្រេកអរ ទើបគិតការក្រ ឯក្រោយក្រែងពុំសប្បាយ ។ ត្បិតកេទជាមនុស្សកបកាយ ដើរដោយព្រៃឆ្ងាយ វិលវិញទៅហានអាត្មា ។ នឹងកើតទោសពៃរម៉ិនជា គួរអញកោត្ត ឲ្យក្លាយជាបក្សីវៃ ។ គិតហើយនាងបេះផ្លែជ្រៃ គ្រប់មែកដងខែ ហើយវេចទុកផ្សេងពីគ្នា ។ វេចស្រេចសម្តេចជាយា នាងយាងបាត ទៅបេះផ្លែជ្រៃទុំ ១ ។ បរិភោគផ្អែមដូចទឹកឃ្មុំ ក្ងនក្ងបដំធំ ក្រឡូបក្រអែបល្អោបល្អង ។ នាងសោយ

ស្កប់ស្កល់កន្ទួង ប្រែកាយសៅហ្មង ជាបក្សីធំមហិមា ៗ ពេមស្លាបចេះ
ដកាបអង្គា ក្លីថ្លុកសោភា ប្រដូចនូវសត្វពជហង្ស ៗ ខេក្រញ៉ាំដូចកែវ
មណីវង្ស រស្មីរលង់ រលើបរលោចស្រស់ស្រេច ៗ ហើយនាងចឹក
ពាំបន្ទួច ផ្លែជ្រៃដែលទេច ហើយហើរឡើងលើវេហាស៍ ៗ រស្មី
ធុះផ្ទាសព្យោមា ស្វស្តិ៍សមសោភា ត្រចះត្រចង់អស់ប្រាណ ៗ
នាងហើរត្រាច់ត្រង់ទៅហាន ព្រឹក្សព្រៃហិមពាន្ត បានដល់អាស្រម
សាលា ៗ តាមសទ្រង់ព្រឹទ្ធសីលា សន្ធតនាមា ព្រះមិត្តាជិនឥសី ៗ
មានស្រះស្រង់បោក្ខរណី ទៀបទីកុដី ទឹកថ្លាឥតព្រាំស្មៅផង ៗ
ឈូកដុះក្នុងស្រះកន្ទួង ផ្កាដូចគេចង ជំប្រាលរន្ទាលពាសពេញ ៗ
មច្ឆាគជាក្រឹមក្រាញ់ ផ្សោងផ្លូក់រៀលលេញ ហែបហែលហិចហក់
ត្រៀបត្រា ៗ នាងចុះដល់ដីពីតា ស៊ីផ្លែព្រឹក្សា ដែលរេចពាំទាំមក
នោះ ៗ ផ្លែមែកទក្សិណបំពោះ ប្រាណប្រែស្មានសោះ ជាមនុស្ស
ល្អអស់កាយា ៗ ហាក់ដូចស្រីទេពកញ្ញា សួគ៌ត្រៃត្រិង្សា មានគ្រឿង
ប្រដាប់អស់អង្គ ៗ ស្រេចនាងចរចូលត្រាច់ត្រង់ អាស្រមទីគង់
ទីកុដិឥសីសីលា ៗ ដើរដល់នាងថ្វាយនមស្ការ ស្រេចហើយធីតា
នាងគង់ទីមួយគួរសម ៗ ឥសីយល់នាងឧត្តម មកថ្វាយបង្គំ កំសួរ
ដោយបទបាលី ៗ តរតោ អាគតាសិ ប្រែជាសេចក្តី ថាហែឧបា.

សិកា ។ ជួនក្រ្តលល្អល្អះជ្រះថ្លា ឆើតឆាយកាយា ប្រកបដោយស្រី
សួស្តី ។ នាមអ្នកនាងតើឈ្មោះអ្វី នាងមកអំពី ជនបទនគរឋានណា ។
ទើបនាងចង្អុលឆ្លើយថា ខ្ញុំព្រះករុណា មកពីវិទេសរាស្ត្ររដ្ឋ ។ ឥសីសួរ
ទៀតទៅថា៖ ហេតុម្ដេចប្រាសព្រាត់ ស្វាមីមាតាបិតា ។ កណ្ដាលតែឯង
ឯកា តើមានប្រាថ្នា មកដល់ឋាននេះរកអ្វី ។ នាងថាបពិត្រឥសី
ខ្លួនខ្ញុំក្រក្រី ពុំមានមាតាបិតា ។ ជាទីពុំទាក់អាត្មា ខ្លួនខ្ញុំនេះជា
មហេសីស្ដេចវិទេសរាស្ត្រ ។ សត្រូវផ្ចាញខ្ញុំវិនាស ខ្ញុំព្រាត់ទពស
មាតាបិតាស្វាមី ។ ខ្ញុំតែចេញចាកបុរី សូមពឹងបារមី ព្រះអង្គសូម
ទ្រង់មេត្តា ។ ព្រះអង្គជាម្ចាស់សិរសា ទុកជាបិតា រក្សាចិញ្ចឹមខ្ញុំផង ។
ទុកជាទាសីទៅហោង សូមជ្រកក្រោមល្អង ធូលីព្រះបាទករុណា ។
ឥសីស្ដាប់នាងថា អង្វរអាត្មា សូមជាទីពឹងអាស្រ័យ ។ នាងនេះ
ពុំកស្ដ្រវិស័យ ជាមហេសីថ្លៃ ឥសីមានព្រះមេត្តា ។ ទើបថ្វាយព្រះពរ
សួរថា មាតាបិតា ហេតុម្ដេចពុំមានជួយធ្លោះ ។ ស្វាមីម្ដេចព្រាត់សូន្យ
សោះ ចូរប្រាប់ដោយស្មោះ បង់ដឹងដំណើរនោះណា ។ នាងស្ដាប់
ឥសីសួរសោះ នាងទូលទៅថា រៀបរាប់អំពីដើមដាន ។ ពីកាលនាង
នៅរាជឋាន សព្វគ្រប់គតិមាន ដូចមាននិទានមុនស្រាប់ ។ ព្រះមិត្តាជន
បាននស្ដាប់ នាងទូលរៀបរាប់ សព្វគ្រប់ឥតខ្វះត្រង់ណា ។

(នៅមានត)

# រឿងព្រេងអារ៉ាប់

### ចែងអំពីលាសរបស់តាស៊ុក

## ភិក្ខុ ម៉ែន-រៀម

សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

ប្រែពីភាសាអង់គ្លេស

> អ្នកណាលួចមាសអ្នកដំណើរ ?
> មានតែមនុស្សពីរនាក់ទេ ដែលបានដឹង,
> ហើយម្នាក់នោះ មិនអាចនិយាយបានឡើយ ។

ខ្ញុំ (១) បានធ្វើដំណើរកាត់វាលខ្សាច់ ជាមួយលោកតាស៊ុក ម៉ាហមូដ អ៊ិបប៊ិន មូសា ព្រមទាំងអ្នកដំណើរកាត់វាលខ្សាច់ចំនួន ១៩ នាក់ ទាំងអូដ្ឋ ៩០ ។

តាស៊ុក ជាមនុស្សចាស់ម្នាក់យ៉ាងវែងវ៉ែង, មានភ្នែកខៀវនិងគួរខ្លាច និងមានពុកចង្កាសស្គុះ ។ ការបង្គាប់បញ្ជារបស់គាត់ទៅលើអ្នកដំណើរ

---

១-ពាក្យថា "ខ្ញុំ" នេះ ជាសំដីរបស់អ្នកដំណើរម្នាក់ ដែលបានធ្វើដំណើរកាត់វាលខ្សាច់ ជាមួយតាស៊ុក......នោះ ។

រាលទ្រាប់ គឺជាច្បាប់មួយ ដែលអ្នកដំណើរត្រូវស្តាប់-ដឹង ។

តាស៊ីក ដែលមានពុកមាត់ពុកចង្កាទេះ ជិះលាធំមួយពណ៌ស ហើយលានេះ កំប៉ិនប្រសប់ដែរ ។ តាស៊ីក បានពប់គាំទស្រឡាញ់វា ដូចជាសំឡាញ់គាត់ៗ ឲ្យតម្លៃស្មើនឹងគាត់ ។ គាត់នឹងលានេះ ស៊ើរតែនៅជាមួយគ្នាជានិច្ចកល់ថ្ងៃ, ដេកក្នុងទុស្សក្រុជ (ខ្ទមសំពត់) ជាមួយគ្នាកល់យប់ ។

ខ្ញុំបានយកទៅជាមួយខ្លួនខ្ញុំ នូវមាសចំនួន ៨០ ដុំ ដែលខ្ញុំបានទុកក្នុងហឹបស្បែករបស់ខ្ញុំ ។ ពេលយប់ៗ ខ្ញុំដាក់ហឹបមាសនោះក្នុងទុស្សក្រុជរបស់ខ្ញុំ, ហើយខ្ញុំតែងដាក់ដៃទៅលើហឹបនោះកល់ព្រឹក ដើម្បីឲ្យដឹងថា «វានៅទេ ឬបាត់ទៅហើយ» ។ នៅព្រឹកទី ៩ ស្រាប់តែហឹបនោះបាត់ពីកន្លែងតែម្តង! ។ ខ្ញុំបានចូលទៅរកលោកតាស៊ីកភ្លាម ហើយនិយាយទៅកាន់គាត់ថា ៖

-ម៉ាហាម្មូដ អ៊ិបប៊ិន មូសា! ចំនួន ៨ ថ្ងៃហើយ ដែលខ្លួនខ្ញុំជាភ្ញៀវរបស់លោក, ខ្ញុំសូមសម្តែងនូវកតញ្ញូធម៌ដ៏ស្មោះស្ម័គ្ររបស់ខ្ញុំ ចំពោះមេត្រីភាពរបស់លោក ។

អ៊ិបប៊ិន មូសា ដាក់ដៃទៅលើទ្រូងគាត់ហើយនិយាយថា ៖

-ការផ្តល់មេត្រីភាពចំពោះអតិថិជន ជាសេចក្តីសោមនស្សមួយដ៏

ជ្រាលជ្រៅ ហើយមានជាទិច្ចកនឹងខ្លួនខ្ញុំ ។

ខ្ញុំនិយាយតទៅគាត់វិញថា ៖

ខ្ញុំបាទ មានសេចក្តីសោកស្តាយនឹងជំពប់លោក ឲ្យបានជ្រាបថា ៖ ឥឡូវនេះ ខ្ញុំបាទព្រួយចិត្តខ្វល់គំនិតណាស់ ហើយដោយខ្ញុំជាភ្ញៀវ ខ្ញុំតោងតែជំពប់លោកឲ្យជ្រាបអំពីការព្រួយនេះ ។

ពេលនោះ ខ្ញុំបានជំរាបគាត់ អំពីការបាត់ហិបមាស ដែលមានមាស ៨០ ដុំនៅខាងក្នុងនោះ ។ គាត់សួរខ្ញុំពីរ-បីសំនួរ រួចអង្គុយច្បូតពុកចង្កាដោយស្ងាត់ស្ងៀម ។ ទីបំផុតគាត់ពោលថា ៖

-ថ្ងៃនេះ អ្នកដំណើរវាលខ្សាច់ទាំងអស់គ្នា មុខតែឥតចេញទៅណាមកណា ពីជំរំទេ, មុនពេលល្ងាចនេះ អ្នកឯងនឹងបានឃើញមាសរបស់ខ្លួនវិញមិនខាន ។

មួយម៉ោងក្រោយមក បាហុនកៈរបស់ខ្ញុំនោះ បានដើរចេញពីជំរំតែម្នាក់ឯង, ថ្ងៃជ្រេរទើបគាត់និវត្តវិញ ។ ហាមប្រាមអ្នកដំណើរទាំងអស់នោះ កុំឲ្យយកហេតុការណ៍ផ្សេង ៗ ទៅកង្វល់ដល់គាត់រួចគាត់ក៏បានចូលខ្លួនបាត់ទៅក្នុងទុស្សក្រុងរបស់គាត់ ហើយបិទគម្រប់ជិត ខ្ញុំចេះតែច្រួលច្របល់ចិត្ត ពីមាសរបស់ខ្ញុំមិនឈប់ឈរសោះ ។ ខ្ញុំសង្ឃឹមថា មានតែមនុស្សម្នាក់ទេ ដែលអាចរកមាសនោះឲ្យឃើញ

ដល់ខ្ញុំបាទ,  ឥឡូវស្រាប់តែគាត់ទៅសំកន្ទក្នុងទុស្សកុដិរបស់គាត់ធ្វើព្រងើយ !

ប៉ុន្តែ ក្រោយវេលាសាយកត្ត បាហុនក:របស់ខ្ញុំ បានចេញសឡឹមៗ ពីទុស្សកុដិរបស់គាត់មកក្រៅវិញ ដោយស្លៀកពាក់ចេតផាយជាទីបំផុត ។ គាត់បានទៅអង្គុយលើកំពូលគំនរហឹបដែលនៅចំកណ្តាលជំរំ ហើយបង្គាប់ខ្ញុំឲ្យអង្គុយក្បែរគាត់ក្នុងទីនោះ ។ ពេលនោះ ក្នុងសម្លេងដ៏មធ្យ័តរបស់គាត់ គាត់ពោលថា :

–ទៅហៅមនុស្សទាំងអស់មកឲ្យខ្ញុំ !

មនុស្សទាំងឡាយចេញតាមផ្លូវរបស់ខ្លួន រួចមកឈរជំរៀបគ្នានៅមុខលោកតា ស៊ុក ៗ ជួបជុំគ្នាហើយ, លោកតាស៊ុក អង្គុយស្ងប់ស្ងៀមសម្លឹងមើលទៅមនុស្សទាំងនោះ ហើយបៀតពុកចង្ការបស់គាត់ ៗ គាត់ឥតមានការប្រញាប់ប្រញាល់អ្វីទេ ។ គាត់សំឡឹងមើលគ្រប់មនុស្សទាំងអស់ ក្នុងពេលដ៏យូរ ហើយមនុស្សទាំងនោះ ក៏បានសម្លឹងមើលមកគាត់វិញដោយស្ងប់ស្ងៀមដែរ ។ ទីបំផុតគាត់ពោលថា :

–ថ្ងៃនេះ មានការកន្ទ្រល់ខ្លះ បានកើតឡើងដល់គៀររបស់ខ្ញុំ គឺអ្នកដំណើរនេះឯង (គាត់បង្អួលប្រាប់) ។ លួចគេជាអំពើទក្រិដ្ឋមួយ, ហើយបើអ្នកណាលួចអ្វីៗ ពីគៀរ បទឧក្រិដ្ឋរិតតែអាក្រក់ថែមប្រាំពីរដង

ទៅទៀត, អ្នកដំណើរនេះ បានឲ្យសិទ្ធិខ្ញុំនូវគាត់ (ក្នុងការរកមុខចោរ) ចំពោះខ្ញុំ; មានជនខ្លះបានលួចវត្ថុគាត់ នៅក្នុងអាស្រយដ្ឋានរបស់ខ្ញុំ, ដោយហេតុតែគ្មានអ្នកណាមួយ ដែលបិតនៅខាងក្រៅចូលមកក្បែរដំរ យើង, ចោរដែលលួចអ្នកដំណើរនេះ គឺបិតនៅខាងមុខខ្ញុំក្នុងពេលនេះឯង វាកំពុងតែឈរនៅពីមុខខ្ញុំ ក្នុងពេលដែលខ្ញុំកំពុងនិយាយនេះ ហើយវា គិតថា វាអាចលាក់នូវបទទុក្រិដ្ឋនេះបាន ។

សម្លេងរបស់តាស៊ុក កាន់តែលាន់ឮខ្លាំងឡើងៗ លាយជាមួយកំហឹង នៅពេលដែលគាត់និយាយពីបទទុក្រិដ្ឋនេះ ។ គាត់និយាយទៀតថា:

-អាទិទេពខ្ញុំនព្រះអគ្គិ នឹងប្រាប់គាត់ឲ្យឃើញនូវចោរហើយនឹង មាសមកវិញមិនខាន ។

រួចហើយ សំឡេងតាស៊ុក ត្រឡប់ជាស្ងប់ស្ងាត់ រួចបែបឡើង មធ្យមទៀត ។ ឬតពុកបន្តិចហើយ គាត់បន្តពាក្យទៅមុខទៀតថា:

-លាស ដែលនៅក្នុងទ្រុងរបស់ខ្ញុំ មិនមែនជាសត្វសាមញ្ញ ទេ គឺជាសត្វតំណពូជដោយផ្ទាល់អំពីលា ដែលព្រះមោហាមម៉េដ ទ្រង់ជិះ ។ លារបស់ខ្ញុំ ជាសត្វមួយចេះណាស់,វាស្គាល់សច្ចៈ , វា តែងប្រាប់ខ្ញុំនូវពាក្យសច្ចៈជានិច្ច ពីព្រោះអាទិទេពបានប្រទានវាអំពីកិច្ចការ ពិតៗ មែនៗ តែម្យ៉ាង ។

-តាស៊ុក ឈប់និយាយមួយនាទី រួចសម្លឹងមើលគ្រប់មនុស្សទាំងអស់នោះ ហើយនិយាយបន្តទៅទៀត៖

-លារបស់ខ្ញុំ មុខតែនឹងប្រាប់ខ្ញុំឲ្យដឹងថា អ្នកណាដែលលួចមាសអ្នកដំណើរនេះមិនខាន; បាទ ! លាមិនអាចនិយាយភាសាយើងបានទេ ប៉ុន្តែ កាលណាវានិយាយមកកេខ្ញុំតាមភាសាវា ខ្ញុំយល់បានជានិច្ច ៗ ឥឡូវនេះ ខ្ញុំសូមឲ្យអ្នកទាំងអស់គ្នា ចូលទៅក្នុងទុស្សក្រុងរបស់ខ្ញុំ ម្នាក់ម្តងៗ រួចបិទគម្រប់វាឲ្យជិត កុំឲ្យអ្នកណាមើលឃើញឲ្យសោះវៀរលែងតែលាខ្ញុំ នឹងព្រះអាទិទេពប៉ុណ្ណោះ, រួចហើយចូរចាប់កន្ទុយលារបស់ខ្ញុំ ៗ កាលបើដៃឥតទោស ទៅប៉ះនឹងកន្ទុយលានោះ វានឹងបិតនៅស្ងប់ស្ងៀម, ប៉ុន្តែកាលបើដៃរបស់ចោរទៅប៉ះវិញ លានោះនឹងនិយាយមកកាន់យើងនូវរឿងទាំងអស់ (នៃចោរនោះ) តាមភាសាវា ហើយយើងនឹងចាប់យកចោរនោះមកប្រហារជីវិតចោលភ្លាម ដោយឥតករុណាឡើយ ៗ

-និយាយរួច, តាស៊ុក បានបង្គាប់មនុស្សដែលបិតនៅខាងចុងជួរឲ្យទៅមុនគេ ៗ មនុស្សនោះ ក៏ចូលទៅក្នុងទុស្សក្រុងតាស៊ុក, បិទគម្រប់ជិត ហើយបន្ទាប់ពីខណៈស្ងប់ស្ងៀមមួយភ្លែតមក ក៏បានចេញមកវិញ ៗ

មនុស្សទី២ បានចូលទៅ…រួចចេញមកវិញ , រួចដល់វេនមនុស្សទី៣ . . . . .១២ នាក់ បានចូល រួចចេញមកវិញហើយ ប៉ុន្តែនៅតែ

គ្មានសំឡេងអ្វីលាន់ចេញមកសោះ ។

មនុស្សទី១៣...១៤...១៥...១៦; នៅតែមនុស្ស ៣ នាក់ទៀតទេ, ...ទី១៧...១៨...។ ស្ទួរនៅតែមនុស្សម្នាក់ទៀតទេ, គាត់ទី ១៩ នេះ បានចូលទៅក្នុងទុស្សក្រុង ។

តាមពិតគួរតែមានសំឡេងអ្វីចេញពីទុស្សក្រុងរបស់តាស៊ុក ! តែបុរសទី ១៩ នេះ ចូលទៅហើយ ចេញមកវិញ ក៏នៅតែគ្មានសំឡេងអ្វីលាន់ចេញមក ។ ដូច្នេះហើយ ឃើញថាលាគ្មានការវ៉ាងវៃ ដូចតាស៊ុក អួតនោះសោះឡើយ ។

ប៉ុន្តែ តាម៉ាហាមូដ អ៊ិបប៊ិន មូសា និយាយមកកាន់ខ្ញុំដោយស្ងាត់ថា :

-កុំបារម្ភអ្វីឡើយសោះ, ការនេះវាយ៉ាងហ្នឹងហើយ, អ្នកឯង មុខតែនឹងបានឃើញទូហឹបមាសវិញជាប្រាកដ ។

មនុស្សទាំងឡាយ មកនៅពីមុខគាត់ម្តងទៀត រួចគេអង្គុយចុះ ។

- ឈរឡើង ! (តាស៊ុកបង្គាប់) ។ មនុស្សទាំងអស់ក៏ធ្វើតាម រួចគាត់បង្គាប់ទៀតថា :

- សណ្តោកដៃត្រង់ទៅមុខគ្រប់គ្នា, ហើយលាផ្ងារបាតដៃឡើងលើ ។

មនុស្សទាំងអស់ក៏ធ្វើតាម ។ ពេលនោះ តាស៊ុកដើរចុះពីគំនរហឹប ដោយយឺតៗ ឆ្ពោះទៅមនុស្សទី ១ ក្នុងជួរ ។ គាត់ឱនខ្លួនចុះ ហើយ

ដាក់មុខទៅលើបាតដៃជននោះ ៗ បន្ទាប់ពីមួយនាទីមក គាត់ដើរទៅធ្វើរបៀបនេះលើដៃមនុស្សទី ២ ទៀត ។ ខ្ញុំទៅជាស្រឡាំងកាំង ដោយឃើញគាត់ធ្វើយ៉ាងនេះ ម្តងហើយ ម្តងទៀត ពីមួយទៅមួយតាមជួរមនុស្សទាំងនោះ ។ គាត់ធ្វើបែបនេះ រហូតទៅដល់មនុស្សទី ១២ ក៏ស្រាប់តែគាត់ងើបមុខឡើង, ហូតដាវខ្វាកចេញមកហើយស្រែកសន្ធាប់ថា

—អាឯងហ្នឹងហើយ ដែលជាចោរគំរក់ បានលួចយកហិបមាស, អញសំឡេះអាឯងឥឡូវហ្នឹង!

ជនទុច្ចរិត បានដាក់មុខចុះ, អង្វរសុំឲ្យគាត់អាណិត រួចរាំស្ទុះងើបឡើង ហើយរត់ចេញទៅក្រៅជំរុំ ៗ វាទៅកើចទាញថ្មមួយដុំ ហើយត្រឡប់មកវិញ ដោយយកហិបមាសពីស្បែកនោះមកជាមួយផង ។

—ឲ្យទៅអ្នកដំណើរទៅ, (តាស៊ុកបង្គាប់) ។

ជនអកុសលបានប្រគល់ហិបមាសនោះមកក្នុងដៃខ្ញុំ ហើយខ្ញុំបានពិនិត្យឃើញថា មាសទាំង៨០ដុំ នៅគង់ក្រង់ទាំងអស់ក្នុងហិបនោះ ។ ពេលបន្ទាប់នោះ តាស៊ុក ឲ្យមនុស្ស ២ នាក់ស៊ិតចងចោរនោះ ៗ មួយនាទីក្រោយមក ខ្ញុំសុំឲ្យគាត់អាណិតឈប់វាយវា ហើយតាមការបង្គាប់អំពីផ្ទាំហុនកះរបស់ខ្ញុំ ជន ២ នាក់នោះ បានបើកឲ្យវាទៅតាមកន្លែងខ្លួនវិញ ។ តាស៊ុក ក៏ចូលកាន់ទុស្សកុដិរបស់គាត់ មនុស្សទាំងនោះ

ក៏ត្រឡប់ទៅកាន់កន្លែងខ្លួនវិញដែរ ។

ខ្ញុំសប្បាយចិត្តណាស់ ដោយបានឃើញមាសរបស់ខ្ញុំ , ប៉ុន្តែខ្ញុំចង់ដឹងអំពីបាតុភូតអស្ចារ្យនេះជាពន់ពេក ។ កាលដែលយើងបន្តដំណើរទៅមុខទៀត នៅពេលថ្ងៃក្រោយមក ខ្ញុំបានសួរបាហុនកៈរបស់ខ្ញុំ សុំឲ្យគាត់ពន្យល់អំពីបាតុភូតនោះ ។

គាត់សំឡឹងមើលមុខខ្ញុំ, ប្បួតពុកចង្ការួច និយាយមកកាន់ខ្ញុំថា ៖

-អ្នកឯង កុំនិយាយប្រាប់ពួកខ្ញុំឲ្យសោះណា !

-បាទ ! , (ខ្ញុំឆ្លើយ) ។

-ល្អហើយ, (គាត់ចាប់ផ្តើមបរិយាយ), កាលដែលខ្ញុំបិតទៅក្នុងទុស្សកុដិរបស់ខ្ញុំ ពីម្សិលមិញនោះ ខ្ញុំបានយក " ស្លឹកជ័រនាងវង " ទៅត្រាំទឹក ។ កាលទឹកនោះ ប្រែក្លិនដូច ជ័រនាងវងហើយ ខ្ញុំបានយកកន្ទុយលា ទៅជ្រលក់ត្រាំវាឲ្យពាល់តែជាប់ក្លិនជ័រឡើងល្អួយ ទើបឈប់ត្រាំ ។ ល្ងាចនោះ អ្នកចាំបានហើយថា មនុស្សគ្រប់គ្នា បានចូលទៅក្នុងទុស្សកុដិរបស់ខ្ញុំ រួចចាប់ទាញកន្ទុយលា , តាមពិតនោះ មានតែចោរទេ ដែលវាមិនហ៊ានចាប់ទាញ ព្រោះខ្លាចលាខ្ញុំដឹងរឿងរបស់វា ។ ម្ល៉ោះហើយ ដៃរបស់វា ក៏ឥតជាប់ក្លិនជ័រនាងវង ដូចអ្នកឯទៀតឡើយ ។

# រឿងព្រេងនិងរឿងបុរាណជប៉ុនក្នុងមធ្យមសម័យ

(តមក)

លោក ក៏យ–ប៊ុក ប្រែរៀបរៀង

## រឿង ឆ្មា - ជ្រឹង

មានឆ្មាមួយធំ សម្បុរខ្មៅ ដើរលេងៗតាមឧទ្យានដែលព្រះអង្គម្ចាស់ ហ៊ុហ៊ិរុទណាបេស្ហីម៉ា និងស្នំឯកព្រះនាម អូតូយ៉ុ ធ្លាប់ទ្រង់យាងក្រសាលព្រះទ័យនៅទីនោះ ។ ឆ្មានោះ បានទៅលាក់ខ្លួនពីពួកអាត្មានៅក្នុងគុម្ពោតព្រៃ ដែលគេក្រឡេកទៅឃើញពន្លឺភ្នែកវាបញ្ចាំងរស្មីមកដល់ ។

ព្រះអង្គម្ចាស់ទ្រង់ស្តេចមកដល់ទីនោះ ទ្រង់មានព្រះដំណើរប្រកបដោយអភិជនភាពដ៏ប្រសើរ ព្រះភក្ត្រទ្រង់បញ្ចេញនូវព្រះសុខភាពដ៏បរិបូណ៌ និងព្រះហឫទ័យប្រកបដោយមេត្តាករុណា ។ ឯព្រះនាងអូតូយ៉ុ ទ្រង់មានព្រះភក្ត្រវែង, មានពងស្តើងល្មមល្អស, ព្រះឆវីវណ្ណភ្លឺថ្លា, ព្រះនេត្រមានលំនាំផ្អៀង, ព្រះនាសាស្តើង, ព្រះឧស្ឋតូចល្មមទ្រង់ព្រះពស្ត្រព្រះភូសាពណ៌ប្រផេះ ។

ព្រះអង្គម្ចាស់និងព្រះនាង ទ្រង់យាងតាមឧទ្យាន ដែលមានរុក្ខជាតិតូច-ធំ និងដើមផ្កាយ៉ាងស្រស់បំព្រង ជាទីគួរទស្សនាពន់ពេក ។ កន

ពេលនោះ ជាវដូវដែលផ្កាតិសស៊ុន បះញាញផ្កាក្រមួលឈ្មុយឈ្ងប់មានមែកប្រវែង ២០ ឬ ៣០ ម៉ែត្រ, ឯផ្កាមានពណ៌ស ស្វាយ ប្រមូលជាកញ្ចុំមូលល្អមើលណាស់ ។

ព្រះនាងអ៊ូតូយ៉ូ ដែលជាវិទូយាំងជំនាញ ទ្រង់បានសូត្រនូវកាព្យនិពន្ធមួយ ដោយព្រះសូរសៀងដ៏ពីរោះ ដែលកវីបណ្ឌិតពីសតវត្សរ៍ទី ៨ បានតែងថា ៖

តិស៊ុនរុក្ខា បះញាញបុប្ផា រីកស្រស់រុងរឿង
ត្រពាំងបឹងបួ ម្តេចមិនប្រៀងឡើង គាប់ទ្រង់គ្រឿង មិនស្រែកយំទៅ !

ព្រះអង្គម្ចាស់នឹងព្រះនាងទ្រង់ទតទៅវិញទៅមក ហើយក៏ទ្រង់ញញឹម ។

ក្នុងពេលនោះ ព្រះអង្គម្ចាស់នឹងព្រះនាង ឥតដឹងថាមានច្នោខ្មៅមួយបានឃ្លាំមើល ហើយដើរតាមក្រោយព្រះអង្គសោះឡើយ ។

លុះទតទូទៅរួចហើយ, ព្រះអង្គម្ចាស់នឹងព្រះនាងអ៊ូតូយ៉ូទ្រង់ត្រឡប់មកព្រះដំណាក់វិញ ។

ក្នុងពាក់កណ្តាលអធ្រាត្រនៃរាត្រីនោះ ព្រះនាងអ៊ូតូយ៉ូទ្រង់សុបិននិមិត្តឃើញនាយពេជ្ឈឃាតម្នាក់កំពុងឃ្លាំមើលព្រះស្វាមី ហើយបំរុងនឹង

លោតទៅលើស្មាម៉ោនោះ, ព្រះនាងក៏ទ្រង់តេនឡើង ទ្រង់ញាប់ញ័រព្រះកាយជាខ្លាំង ទ្រង់បើកព្រះនេត្រធំទតទៅឃើញពន្លឺពីមានស្មើពណ៌ប្រផេះ ខៀវ លឿង ខៀវខ្ចី ។ គឺឆ្មាខ្មៅនោះឯង ដែលបានលបចូលទៅក្នុងក្រឡាព្រះបន្ទំ ហើយអង្គុយជិតសំរៀងព្រះនាងមិនបប្រែបក្ដែកសោះ ។

ទ្រង់ទតឃើញឆ្មាខ្មៅដូច្នោះ, ទ្រង់មានព្រះហឫទ័យតក់ស្លុតឥតឧបមា មានព្រះសោតហួសស្រាក់ ទ្រង់បើកព្រះឱស្ឋបម្រុងនឹងស្រែកហៅឲ្យគេជួយ តែបំពង់ព្រះសូរង់ដូចគេស្ទៀត រកខ្យល់ដកដង្ហើមមិនបាន មានព្រះសរីរៈមិនរួច ។ ព្រះនាងទ្រង់មិនអាចមានពេលឱកាសនឹងបញ្ចេញកាយវិការបែបណាមួយសោះ ។ ស្រាប់តែឆ្មាខ្មៅនោះ លោតទៅចំព្រះសូរង់ ហើយយកមាត់ខាំដើងករខ្វារខ្វាំពិឃាដព្រះនាងទីវង្គតមួយរំពេច ។ ឆ្មាខ្មៅនោះ មានពលកាតអស្ចារ្យរាំអូសព្រះសពព្រះនាងតាមយ៉ាងក្រៅចុះទៅកាន់ទឡាន ហើយមិនឲ្យនរណាឃើញស្នាមអូសថែមទៀត វាយកសាកសពទៅកប់នៅកន្លែងមួយយ៉ាងស្ងាត់ វាត្រឡប់វិលមកកាន់ក្រឡាព្រះបន្ទំព្រះនាងដែលនៅទំនេរ ហើយកឋិដ្ឋានរូបដោយមន្តអាគមឲ្យដូចជាព្រះនាងអូតូយ៉ូ ។

មនុស្សទាំងអស់ដែលចិតនៅទីនោះ មិនអាចដឹងបានទូវការប្រែកាឡាឆ្មាខ្មៅទៅជាព្រះនាងអូតូយ៉ូឡើយ, ព្រោះថា ព្រះនាងថ្មីនេះ

មានសណ្ឋានទ្រង់ទ្រាយដូចព្រះនាងអ្នកយ៉ូណាស់ ប៉ុន្តែព្រះនាងថ្មីនេះគ្រាន់តែមានព្រះកាយទន់ល្វន់ល្មាសជាងមុន ព្រះនេត្រមានរស្មីភ្លឺចាំងថែងខ្លាំង ៗ

ចំណែក ព្រះអង្គម្ចាស់មិនបានជ្រាបនូវព្រឹត្តិការណ៍នេះសោះឡើយ ទ្រង់សព្វព្រះហឫទ័យចំពោះនាងនោះ កាន់តែខ្លាំងឡើង ៗ, ទ្រង់បានយាងកំសាន្តក្នុងឧទ្យាន ដែលមានផ្កាកែសុះស្គាយពាសពេញ មានពណ៌គ្រប់បែប, នៅតាមវិថីឧទ្យានមានក្រាលដីខ្សាច់ និងស្ពានតូចជាទីកាយពន់ពេក ៗ

តែមិនយូរប៉ុន្មាន ស្រាប់តែព្រះអង្គម្ចាស់ទ្រង់មានព្រះរោគាពាធ, បើតាមពិនិត្យនូវព្រះរូបគ្មានមោះមៃអ្វីសោះ តែទ្រង់បែរតែមានព្រះកាយពលថមថយជានិច្ច ព្រះភក្ត្រមានពណ៌ស្វាយ ព្រះប្រាជ្ញាក៏បានថយបន្តិចម្តង ៗ ទ្រង់មិនស្រួលព្រះអង្គ បែរតែអស់ព្រះកាយពលល្ហិតល្ហៃ ហើយទ្រង់ផ្ទំមិនលក់សោះ ៗ

ព្រះវរមាតាបិតា ទ្រង់បានត្រាស់បង្គាប់ឲ្យគ្រូពេទ្យមកពិនិត្យ នូវព្រះអាការរោគព្រះអង្គម្ចាស ៗ គ្រូពេទ្យទាំងឡាយ បានមកពិនិត្យមើលដោយហ្មត់ចត់ ខ្លះថ្វាយឱសថផ្សេងៗ ខ្លះយកថ្នាំមករឹតព្រះកាយតែគ្មានគ្រូពេទ្យណាមួយផ្សំឱសថធ្វើឲ្យសះស្បើយចាកព្រះរោគបានឡើយ ៗ

ផុយទៅវិញ, ព្រះអាការពេគរបស់ព្រះអង្គម្ចាស់ រឹងរឹតតែមានអានុភាពខ្លាំងឡើងៗជាដរាប ។ ពេលយប់ទ្រង់ផ្ទំមិនលក់សោះ ទ្រង់មានព្រះទ័យរសាប់រសល់ជានិច្ច ។

ព្រះអង្គម្ចាស់ក្សត្រី ទ្រង់បានហៅអាមាត្យម្នាក់សំណប់មកប្រឹក្សាក៏មិនបានគ្រាន់, តមក បានចាត់ស្និទ្ធក្រមការ ១០០ នាក់មកយាមល្បាត, ប៉ុន្តែ ក្នុងពេលយប់ដំបូង សុំក្រមការទាំងនោះ ស្ងាបតាំងពីល្ងាចរហូតនាំគ្នាដេកលក់គ្មានសល់ម្នាក់ ។

យប់ទី ២ បានផ្លាស់អ្នកយាម, អ្នកយាមថ្មីនេះ ក៏ដេកលក់ពីល្ងាចទៀត ។

យប់ទី ៣ ពួកអាមាត្យបាននាំគ្នាចូលទៅយាម ប៉ុន្តែអត់ទ្រាំនឹងការងោកងុយពុំបាន ហាក់ដូចជាមានពលកាយអ្វីមួយមកសង្រ្គិបឲ្យដេកលក់ទៀត ។

គេបានសង្កេតពិនិត្យឃើញថា ក្នុង ១ យប់ៗ ព្រះកាយពលរបស់ព្រះអង្គម្ចាស់ ព្រះលោហិតបេះតែហូរចេញក្រៅបន្តិចម្តងៗ តែព្រះកាយព្រះអង្គគ្មានឃើញស្នាមរបួសអ្វីសោះ ។

ទីប្រឹក្សាសំណប់របស់ព្រះអង្គម្នាក់ នឹកចូលក្នុងចិត្តថា ប្រហែលជាព្រះអង្គម្ចាស់ទទួលគ្រោះថ្នាក់ដោយមន្តអាគមបិសាច ឬអ្នកតាក៏មិនដឹង

ឬដោយមានខ្មោចព្រាយមកពេលយប់ ធ្វើបាបព្រះអង្គហើយ ទើបធ្វើព្រះកាយពលរបស់ព្រះអង្គឲ្យថមថយយ៉ាងនេះ, ប្រសិនបើរកព្រះសង្ឃសូត្រធម៌, អាការរោគនោះ នឹងជាសះស្បើយដឹង ?

ទីប្រឹក្សានេះ ឈ្មោះអ៊ីសាហា យ៉ាប៊ុយហេរ្ទ ក៏បានទៅពិតពុទ្ធដីកា លោកគ្រូ រីតេន គង់នៅព្រះវិហារម៉ីយូអិនចំពោះរឿងប្លែកនេះ ។

លោកគ្រូ រីតេន មានថេរដីកាថា លោកនឹងជួយដោះទុក្ខនេះល្បងមើល ។ ពេលសាយណ្ហសម័យ លោកគ្រូ រីតេន ក៏បានបួងសួងដល់ពពួកទេវតាឲ្យបង្អុរនូវទុសថទិត្ត មកថ្វាយព្រះអង្គម្ចាស់នោះឲ្យបានជាស្បើយនូវព្រះរោគាពាធនោះ ។

ពេលយប់មួយ លោកគ្រូ រីតេន សូត្រធម៌ជិតចប់ លោកបានឮសម្លេងមួយជិតអណ្តូងប្រចព្រះវិហារ, លោកបានបើកបង្អួចក្រឡេកមើលទៅឃើញទាហានម្នាក់ឋិតនៅក្នុងយុរកាព ។ ទាហាននេះក្រោយដែលបានលុបមុខជម្រះកាយស្អាតបាត ដោយទឹកអណ្តូងហើយ ក៏ឱនក្បាលសំដែងគារវកិច្ចចំពោះព្រះពុទ្ធរូប ។

ក្នុងពេលយប់ស្ងាត់នោះ លោកគ្រូបានឮសំឡេងទាហាននោះសូត្រធម៌បួងសួងសុំឲ្យព្រះអង្គម្ចាស់ប៉ុហ្សិនណាបេស៊ីម៉ាបាន ទទួលនូវសុខភាពដ៏បរិបូណ៌ឡើងវិញ ដោយឆាប់រួសរាន់ទាន់ចិត្ត ។

លោកគ្រូ វិតេន មានចិត្តសោមនស្សត្រេកពេក ដោយឃើញទាហាននេះ មានចិត្តកក្តីចំពោះចៅហ្វាយនាយ ៗ លុះទាហាននេះបួងសួងរួចហើយ, លោកគ្រូក៏ស្រែកហៅឲ្យទាហានចកកាន់សំណាក់លោក ៗ ទាហាននោះ ក៏ចូលទៅក្រាបថ្វាយបង្គំលោកគ្រូ ហើយនិយាយថា ៖

ខ្ញុំព្រះករុណាឈ្មោះ អ៊ីតូស៊ូដា , ជាទាហាននៃកងទ័ពរបស់ព្រះអង្គម្ចាស់ ហើយខ្ញុំព្រះករុណាចង់បូជាជីវិត ដើម្បីថ្វាយព្រះអង្គជាទីបំផុត ខ្ញុំព្រះករុណាមានបំណងចង់ថែទាំព្រះអង្គណាស់ តែខ្ញុំព្រះករុណាជាទាហានសាមញ្ញ ឥតកិត្តិយស មិនអាចបិតនៅជិតព្រះអង្គបាន ព្រោះហេតុដូច្នោះខ្ញុំព្រះករុណាគ្រាន់តែស្រែកអំពាវនាវ ចំពោះទេវតាឲ្យជួយថែទាំព្រះអង្គ សូមព្រះអង្គទ្រង់មានសុភាពបរិបូណ៌ឡើងវិញប៉ុណ្ណោះ ៗ

លោកគ្រូវិតេនមានទុក្ខដឹកថា លោកមានវ័យនៅក្មេងណាស់ តែលោកមានចិត្តកក្តីចំពោះចៅហ្វាយនាយ . . . អាត្មាមានសេចក្តីកោតសរសើរលោកណាស់ . . .; តើលោកជ្រាបឬទេ? ព្រះអង្គម្ចាស់ទ្រង់មានអាការរោគបែបណាខ្លះ? តើលោកជ្រាបឬទេ? ព្រះអង្គម្ចាស់ទ្រង់សុបិននិមិត្តប្លែកពីធម្មតា នាំឲ្យព្រះអង្គថមថយព្រះកាយពល ហើយពួកទាហានដែលយាមព្រះអង្គ តែងនិទ្រាលក់ឥតដឹងខ្លួនសោះឡើយ ៗ

លោក អ៊ីតូស៊ូដា ក៏ទូលលោកគ្រូថា ប្រហែលជាព្រះអង្គម្ចាស់

ត្រូវអំពើគេទេដឹង ? ម្យ៉ាងទៀត ប្រហែលជាខ្ញុំព្រះករុណាអាចទប់ទល់នូវការនិទ្រានេះបាន ហើយខ្ញុំព្រះករុណានឹងអាចរកបុព្វហេតុនៃព្រះអាការរោគរបស់ព្រះអង្គបាន ។

លោកគ្រូមានពុទ្ធដីកាថា រឿងនេះ អាត្មាសូមប្រាប់ដល់ទីប្រឹក្សាព្រះអង្គម្ចាស់ ។

លោក អ៊ីតូស្វូដាគបថា ខ្ញុំព្រះករុណា មានចិត្តគេគអរណាស់ ដោយលោកគ្រូមានព្រះទ័យល្អ, ខ្ញុំព្រះករុណា សូមសំដែងនូវកតញ្ញូតាធម៌ចំពោះលោកគ្រូ សូមលោកគ្រូទូលព្រះអង្គម្ចាស់ថា ខ្ញុំព្រះករុណាឥតប្រាថ្នាឡើងប្រាក់ខែ យសសក្តិ ប៉ុន្មានអ្វីសោះឡើយ គឺខ្ញុំព្រះករុណាមានបំណងតែមួយ សូមឲ្យតែព្រះអាការរោគរបស់ព្រះអង្គជាសះស្បើយប៉ុណ្ណោះ ។

លោកគ្រូមានពុទ្ធដីកាថា បើដូច្នេះ សូមលោកមកជួបនឹងអាត្មាពេលស្អែក អាត្មានឹងនាំលោកទៅជួបលោកទីប្រឹក្សា ។

លុះព្រឹកឡើង លោកគ្រូ រ៉ាគេន បាននាំទាហាននោះទៅជួបនឹងលោកទីប្រឹក្សានាម អ៊ីសាហាយាប៉ុយហ្សេន ។

លោកទីប្រឹក្សាបានទូលលោកគ្រូថា មិនសមសោះ ! លោកគ្រូឲ្យមនុស្សសាមញ្ញចូលទៅជិតព្រះអង្គម្ចាស់ ។

លោកគ្រូបានតបទៅលោកទីប្រឹក្សាថា សូមលោកអនុញ្ញាតឲ្យទាហាននេះ ចូលទៅក្រាបបង្គំគាល់ព្រះអង្គម្ចាស់ចុះ ។

លោកទីប្រឹក្សាបានហៅទាហានក្មេងនោះ មកពិនិត្យមើលអាកប្ប-កិរិយាឃើញថា ទាហាននេះ មានចិត្តស្វាមីភក្តិពិតប្រាកដចំពោះព្រះអង្គម្ចាស់, ហើយក៏ទូលលោកគ្រូថា ទង៏នាំទាហាននេះទៅក្រាបបង្គំគាល់ព្រះអង្គម្ចាស់ក្នុងថ្ងៃស្អែក ។

លុះដល់កំណត់ លោកអ៊ីតូសូដា បានចូលទៅរួមរួមក្នុងពួកកងទាហានយាមព្រះអង្គម្ចាស់ ក្នុងក្រឡាព្រះបន្ទំ ។

លុះដល់ម៉ោង ១០ យប់ លោកអ៊ីតូសូដា បានក្រឡេកមើលទៅទាហានឯទៀតដេកលក់អស់ ឯខ្លួនឯង ក៏ចូនគ្របភ្នែកចង់ដេកណាស់ដែរ, តែបានរៀបចំផែនការរបស់ខ្លួនយ៉ាងហ្មត់ចត់ គឺយកក្រដាសស្ដើងមួយដាក់លើកន្ទេល យកកាំបិតតូចមួយវះក្បាលជង្គង់របស់ខ្លួន ឲ្យឈាមស្រក់លើក្រដាសនោះ ។ មធ្យោបាយបែបនេះធ្វើមិនឲ្យខ្លួនដេកលក់ព្រោះឈឺដោយរបួសក្បាលជង្គង់ ។

ដៃព្រាយនោះ ស្ទាបលើគ្របភ្នែកទាហាន ដើម្បីឲ្យទាហាននោះដេកលក់, តែទាហានបានយកកាំបិតតូចចាក់ត្រង់របួសនោះ, ហើយដោយការឈឺចាប់, ក៏ភ្នែកនោះស្ថិតនៅបើកជានិរន្តរ៍ ។

លុះដល់ពេលអធ្រាត្រស្ងាត់, ទាហាននោះក្រឡេកទៅឃើញស្រាប់តែបើកហើយមាននារីម្នាក់ មានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ ចូលទៅក្នុងក្រឡាព្រះបន្ទំព្រះអង្គម្ចាស់ ។ នារីនោះដើរដោយឆាប់រហ័សយកដៃបិទភ្នែកពួកទាហានយាម; រួចនាងទៅដល់ព្រះខ័នអង្គម្ចាស់ ក៏ទុននោះទៅលើទ្រូង ថេប ទុយ ហើយក៏ជប់យកព្រះលោហិតពីទ្រូង . . .

ក្នុងមួយរំពេច នាងព្រាយក៏ក្រឡេកទៅឃើញរស្មីចាំងពីភ្នែកក្នុងទីងងឹតមួយ គឺភ្នែកលោកអ៊ីតូសូដា ។

នាងព្រាយក៏ស្រែកថា "អ្នកឯងជាអ្វី ? ខ្ញុំមិនធ្លាប់ឃើញអ្នកឯងស្ថិតនៅទីនេះ" ។

លោកអ៊ីតូសូដា ក៏តបទៅនាងវិញថា "ខ្ញុំឈ្មោះអ៊ីតូសូដា ខ្ញុំទើបនឹងមកយាមព្រះអង្គម្ចាស់ នៅលើកទី ១ ក្នុងពេលនេះ" ។

នាងព្រាយពោលថា "ទាហានទាំងអស់ដេកលក់គ្រប់ ៗ គ្នា នៅតែអ្នកម្នាក់ឯង មិនបានដេកលក់ដូចអ្នកឯទៀត, ភ្នែកអ្នកឯងបើកជានិរន្តរ៍, ខ្ញុំកោតសរសើរអ្នកឯងណាស់" ។

លោកអ៊ីតូសូដា តបទៅនាងព្រាយថា "ឱនាង, កុំសរសើរខ្ញុំ ៗ ចង់ដេកណាស់ដែរ" ។

(នៅមានត)

## កណ្ឌទី ៤១

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកវាងវៃឆ្លាតបើបានអាន<br>នឹងបេះឧបាយកលចំណាន<br>ទាំងមានសន្តានស្នេហាជាតិ។ |

## សាមកុកខ្សែ ៤២

តាំងពីចូជូជួបជុំនឹងសេនាទាហានតុំផឹកក្នុងទូកផែទឹក ចូជូស្រវឹងស្រាប្រមាថគុំគួនថា ជីវយីនឹងឡោសុកនឹងជល់ទូវាសបក្តីអន្តរាយ លុះដល់អ៊ុយកាយចូលទូកទៅដុតទ័ពចូជូឆេះអស់។

---

ខណៈនោះចូជូផឹកស្រាស្រវឹងជាមួយនឹងពួកមន្ត្រីខុំរាជការ លុះដល់ពេលយាម ២ យប់ ចូជូស្រវឹងស្រាខ្លាំងណាស់ ក៏កំរើបចិត្តគិតប្រមាថ រួចក្រោកឡើងលើកកែវចង្អុលទៅទាហានទាំងពួងថា ជីវយីនឹងឡោសុកនោះ មិនបានដឹងថាអាកាសនឹងសំដែងហេតុឲ្យឃើញថាខ្ញុំទាំង ២ នឹង

ដល់នូវសេចក្តីស្លាប់ក៏ឥតអន្តីមាន ប្រការមួយទៀតបណ្តាពួកទាហានក្នុង
កងទ័ពវាក៏ប្រែចិត្តគិតតែដោះគៀសចេញ មកចូលនៅខាងយើងជាច្រើន
ណាស់ បីដូចជានឹងឃើញច្បាស់ថា ទេពតាទាំងឡាយមកបញ្ចូលចិត្ត
គិតនាំមក ប្រាថ្នានឹងឲ្យយើងយកនូវជ័យជំនះដល់វា ៗ ស៊ុនហ៊ីវក៏ឃាត់
ហាមប្ញូថា លោកកុំមានប្រសាសន៍ឲ្យព្រួយខ្វល់ខ្វាយទៅច្រើន ក្រែងបែក
សេចក្តីនេះដឹងទៅដល់ដីវយ៉ីនឹងខូចការរបស់យើង ៗ

ប្ញូតបថា បណ្តាពួកទាហានដែលបានមកប្រជុំគ្នានៅទីនេះ ក៏សុទ្ធ
តែជាពួកម៉ាករបស់យើងរួមចិត្តគំនិតមួយ អ្នកកុំគប្បីព្រួយថាការនោះនឹង
ដឹងដល់ទៅដីវយ៉ីឡើយ ហើយលើកដៃចង្អុលទៅត្រង់ទិសស្រុកកាំងហៃ
ថា ឡៅពីនឹងខុងបេងគ្រានេះ គឺមិនមែនបេះគ្នាប្រមាណក្នុងកំឡាំងរបស់
ខ្លួនសោះ ប្រៀបដូចកណ្តៀរពូនដំបូក អាចគិតលូកទៅទំលាយក្នុងដំបំ
ខ្ពស់ គួរនឹងទប់ទល់បានឃើញឬ ឯអាយុរបស់យើងក៏បាន ៥០ ឆ្នាំ
ហើយ បើសិនណាយើងបានស្រុកកាំងតាំង ក៏នឹងមានសេចក្តីត្រេកអរ
សប្បាយ ១ ពេល ព្រោះពីដើមយើងក៏ដឹងច្បាស់ថា នាងកៀវកុកឡោ
មានបុត្រីសម្បូរល្អស្អាត ២ នាក់ ប្រកបដោយល័ក្ខណ៍ស័ក្តិសមជាឯក
លើសស្រីក្នុងផែនដីនេះ យើងក៏បានត្រិះរិះទុកមកជាយូរហើយ តែថា
ជាហេតុទេពតាបណ្តាលឲ្យព្រាត់ក្មាត់បានទៅជាភរិយាស៊ុនសេក នឹងដីវយ៉ី

ទាំង ២ នាក់ កាលយើងច្បាំងបានស្រុកកេងដីរនោះ យើងក៏បានឲ្យកសាងស្រុកជាថ្មី ធ្វើប្រាសាទកំពូលបីទុកត្រង់ឆ្នេរទន្លេជៀងហោ គ្រានេះបើយើងបានស្រុកកាំងតាំងគង់ទឹងឃើញមុខនាងកៀវកុកឡោ យើងទឹងទៅទ្រប៊ស្ត្រីទាំង ២ នាំទៅនៅលើប្រាសាទស្រុកកេងដីរ ឲ្យធ្វើវត្តប្រតិបត្តិយើងតាមត្រូវការ ដើម្បីជាទីស្នេហាត្រាតែអស់ជីវិតក្នុងទីនោះ ហើយចូច្ចក៏អស់សំណើចសើចក្អាកក្អាយ ទទួលក្រឡេកទៅឃើញក្អែកមួយហួងហើរព្រោងព្រាតជម្រង់ទៅទិសទក្សិណ ចូច្ចក៏សួរទីប្រឹក្សាទាំងពួងថា ហេតុម្តេចបានជាក្អែកហើរស្រែកខុសវេលាដូច្នេះ នឹងកាចឬជាប្រការម្តេច ?

ទីប្រឹក្សាទាំងពួងឆ្លើយថា ឯក្អែកដែលហើរស្រែកមកនេះ ព្រោះឃើញខែភ្លឺស្រឡះ វាសំគាល់ច្បាស់ថាជិតភ្លឺ ប្រាថ្នានឹងហើរទៅរកស៊ី ដែលលោកមកសំគាល់ថាជាឬកាចនោះមិនត្រូវទេ ចូច្ចឮដូច្នោះក៏អស់សំណើច ហើយលើកពែងស្រាផឹកថែមទៅទៀត ២-៣ ពែង ស្រវឹងខ្លាំងណាស់រឹតតែមានចិត្តកំរើមឡើង ក៏កន្ទ្រាក់យកលំពែងចេញទៅឈរនៅក្បាលទូក ហើយស្រែកប្រកាសទាហានទាំងពួងថា ផ្លូលំពែងនេះយើងកាន់សម្រាប់ដៃមកពីដើមកាលនៅជាកូនទាហាន ទាល់តែតាំងខ្លួនបានដល់ទីនេះបានប្រាបប្រាមពួកចោរជួតក្បាលលឿង នឹងលីប៉ោ, អួន

សៀវ, អួនស៊ិត ហើយបានប្រាប់ប្រាមការណាខែត្រតាំងពួងតមកទៀត ក៏មិនដែលថ្មស់ការ កើតមកជាជាតិទាហានហើយត្រូវតែមានចិត្តក្លៀវក្លា ដូច្នេះ រូបប៊ូឆុកក៏ប្រៀនក្មេងមានទំនុកថា:

វិស័យកំណើតកើតគួរស្លាប់ កាលរស់គួរគ្រាប់គ្រងកិត្យាយ
ត្រូវលេងល្បែងអ៊ឲ្យសប្បាយ សម្រាប់រូបកាយដែលត្រូវការ ។
តែមកឃើញថ្ងៃក្អែកតាំងហ្វូង ផ្លើលហើរទៅត្បូងជាអស្ចារ្យ
សូម្បីព្រៃឈើរល្ហើលតា គ្មានសោះបក្សាទំមិនបាន ។
បានជាហើរថ្ងៃបែកបាត់អស់ គួរឲ្យស្រណោះសត្វតិរច្ឆាន
ធម្មជាតិក្ដីធំដុំដែនដាន មែនមានកំពូលស្រួលខ្ពង់ខ្ពស់ ។
រីឯសមុទ្រជ្រៅផុតដែន ដីដែនទ្រង់ទ្រទ្រូងទិសទស
ចិត្តយើងចិត្តគេគោរពរស់ គឺមោះបៀសទុក្ខមើលសុខា ។

ឡៅ ហុកទីប្រឹក្សាពួកដូច្នោះក៏និយាយថា លោកលើកទ័ពមក ប្រាថ្នានឹងធ្វើការសង្គ្រាមយកជ័យជំនះ ហេតុម្ដេចមកពោលពាក្យជាបរាជ័យដូច្នេះ ។ ប៊ូឆុកសួរថាអញធ្វើក្មេងលេង ហេតុម្ដេចមកថាបរាជ័យវិញ ។ ឡៅ ហុកថា ខ្ញុំបាទបានឮក្មេងថាហ្វូងក្អែកគ្មានសំបុកទីដែលមកឈើទំអាស្រ័យ នាំគ្នាហើរប្រែកទៅឲ្យខុសវេលា បានជាខ្ញុំបាទថាជាពាក្យបរាជ័យដូច្នេះ ។ ប៊ូឆុកពួកដូច្នោះក៏ខឹងប្រទៀត ខ្លួនឯងនេះហ៊ាននិយាយ

មើលឆ្ងាយប្រមាថអញ ហើយក៏យកលំពែងចាក់ឡោហុកដួលចុះដាច់ខ្យល់ស្លាប់ ទាហានទាំងពួងឃើញដូច្នោះក៏គត់ស្លុតខ្លួតស្មារតី ទើបនាំចូចូបេកងបន្ទាយ ៗ

លុះពេលព្រឹក ចូចូស្វាងស្រវឹងស្រា ក្រោកពីដេកឡើងក៏គិតឃើញថា យប់មិញអញសម្លាប់ឡោហុកចេញនោះខុសនោះ ៗ ឯឡោហ៊ុជាកូនឡោហុកក៏ចូលទៅស្រែកទ្រហោយំឲ្យចូចូថា បិតាខ្ញុំបាទគ្មានទោសខុសអ្វីសោះ លោកមកសម្លាប់ចេញ ឥឡូវខ្ញុំបាទសូមយកសពបិតាទៅដាក់តាមទំនៀម ៗ ចូចូឮដូច្នោះ ក៏មានសេចក្តីអាណិតគនាថ យំស្រក់ទឹកភ្នែកហើយថា កាលពីយប់មិញយើងផឹកស្រាស្រវឹងខ្លាំងណាស់ ដែលសម្លាប់បិតាអ្នកស្លាប់នោះ គឺយើងធ្វើលោកបំពានទៅ ហើយអ្នកកុំតូចចិត្តនឹងយើងឡើយ ចូរយកសពបិតាទៅរៀបចាត់ចែងតាមតំណែងកូនស្តេចកងក្រុងហ៊ូកោចុះ ហើយក៏ចាត់ទាហានឲ្យហោហ៊ុជួយនាំសពយកទៅ ៗ

លុះវេលាព្រឹកឡើង អ៊ុគិមនឹងម៉កាយដែលជានាយទ័ពទឹក ក៏ឡើងទៅជំពបប្តឹងចូចូថា ទូកចម្បាំងទាំងធំទាំងតូច ក៏បានចាត់ចែងត្រៀមបំរុងព្រមទាំងគ្រឿងសាស្ត្រាវុធសព្វគ្រប់ហើយ លោកនឹងលើកកងទ័ពទៅវេលាណាសុំឲ្យកំណត់ថ្ងៃចុះ ខ្ញុំបាទនឹងចាត់ចែងរៀបចំឲ្យព្រមគ្នា ៗ

ចូច្ឆជូរ ព្រះក៏ចុះទៅកាន់ទូកបម្រុង តាំងឲ្យប្រមូលទាហានទាំងទ័ពទឹកមកបញ្ចូលគ្នា ហើយចាត់ឲ្យមានទង់ពណ៌ផ្សេងៗ ៤ យ៉ាង សម្រាប់កងទ័ពគោកទ័ពទឹកទឹងបានដោតសំគាល់ទាំង ៤ កង ឯទូកខ្នាតមេកងធំទ័ពហ្លួងត្រូវដោតទង់ពណ៌លឿង ទូកខ្នាតអ៊ុគមនឹងម៉កាយជានាយទ័ពស្រួចទង់ពណ៌ក្រហម ឲ្យលីយយជាប៉ែកស្ដាំនាំទូកខ្នាតដោតទង់ពណ៌ខៀវ ប៊ុនផែននាំទូកខ្នាតជាប៉ែកឆ្វេងដោតទង់ពណ៌ស ឲ្យទៀវតាប់នាំទូកខ្នាតជាកងទ័ពក្រោយដោតទង់ពណ៌សេក ។

ឯទ័ពគោកនោះសោត ចាត់ឲ្យលីកងជានាយទ័ពស្រួចដោតទង់ពណ៌ក្រហម ឲ្យលីទៀនជាប៉ែកស្ដាំដោតទង់ពណ៌ខៀវ ឲ្យអ៊ាក់ជិនជាប៉ែកឆ្វេងដោតទង់ពណ៌ស ឲ្យហៃហ៊ួរអៀនជានាយកងទ័ពហ្លួងដោតទង់ពណ៌លឿង ឲ្យស៊ុយឡុងជានាយកងទ័ពក្រោយដោតទង់ពណ៌សេក ហើយឲ្យហៃហ៊ួរទុនទឹងទៅហាងជាកងល្បួន សម្រាប់ជួយបំពេញកំឡាំងទាំងទ័ពគោកទ័ពទឹក ហើយទឹងឲ្យយកដំណឹងជាផ្លូវពេជការមកប្ដឹងតម្រល់គ្រប់ពេល ឯទៀវលៀវទឹងទៅធ្វើឲ្យកាន់ឥតញ្ញាសិទ្ធិជាសាវត្រង់ សម្រាប់ត្រួតទ័ពបណ្ដាទាហានឯក - ទោ ទាំងឡាយក៏ចាត់ឲ្យជានាយពួកនាយកងទ័ពទឹកទាំងអស់ លុះចាត់ការស្រេចហើយ នាយទាហានទាំងអស់ក៏ទៅចាប់ស្នាក់តាមកែណ្ឌទ័ពគោកទ័ពទឹក ។

ក្នុងខណៈនោះទទួលផាត់ខ្យល់បក់មក បុប្ផក៏ឲ្យផែកយុក្តាបើកក្ដោង ទូកខ្នានទាំងអស់ឡើងលឿនគ្រៀនតាមមាត់ទន្លេ បណ្ដាចាបានធំតូច ទាំងពួងក៏រត់ទៅមកជាទីជួយគ្នាច្បាំងតយុទ្ធ ៖ នោះទូកខ្នានទាំងអស់ដែល ត្រូវខ្យល់វល់នឹងរលកក៏នឹងក្ដប់ដូចនៅលើផែនដី គ្មានផ្អៀងផ្អងយោង ផល់តិចសោះ ពួកចាបានស្រុកៈលើក៏មិនមានពុលលេក នាំគ្នាធ្វើការជាប្រក្រតី ។

បុប្ផៈឃើញដូច្នោះក៏មានចិត្តកំរើបថា គ្រានេះនឹងមានជ័យជំនះសឹកសត្រូវជាប្រាកដ ហើយគិបដ្ឋាប់ឲ្យទូកខ្នានទាំងពួងបូក្ដោងទុក ចូលទៅបតនៅទីដដែលដូចដើម បុប្ផក៏ត្រឡប់ឡើងទៅលើបន្ទាយគោក ហើយនិយាយនឹងទីប្រឹក្សាទាំងពួងថា គ្រានេះទេពតាជួយយើង ទើបបណ្ដាលចិត្តបាំងបង មកប្រាប់ឲ្យយើងធ្វើការយកប្រវាក់រយគាបទូកចម្បាំងចងភ្ជាប់គ្នាជាផែខ្នាន ដូច្នេះក៏នឹងផ្ដល់ដូចផែនដី នឹងតតាំងច្បាំងគ្នាបានយាងបំណាច់ណាស់ ឃៀយ៉ុកឆ្លើយថា ការដែលរៀបចាត់ចែងទាំងពួងនេះក៏ឃើញថា ជាស្រួលមែនហើយ តែនៅបារម្ភក្រែងសឹកសត្រូវនឹងលបយកភ្លើងមកដុតឲ្យឆេះឡើង នោះឃើញថាទូកចម្បាំងទាំងពួងដែលចងភ្ជាប់គ្នានោះ នឹងកែខៃថយចេញពីគ្នា មិនទាន់នឹងថ្វាស់ការសុំឲ្យលោករិះគិតចាត់ចែងប្រយ័ត្នខាងការពារគ្រោះភ្លើងឲ្យមាំមួន ទើបនឹងមិនមានអន្តរាយ ។

ចូចូអស់សំណើចហើយថា ដែលអ្នកគិតបង្ខាំងរាំងការពារទុកដូច្នេះក៏ល្អ ហើយ តែថាដូចជាមិនដឹងផ្លូវសេចក្ដីបានជាបារម្ភភ័យដូច្នេះ ដែលអ្នកថាខ្លាចសត្រូវនឹងយកភ្លើងមកដុតនោះ កុំព្រួយបារម្ភឡើយព្រោះហេតុថាជាទេសកាលខែប្រាំង ឥឡូវនេះមានតែខ្យល់ដំនោរទិសខ្យល់បក់មកពីទិសឯលិច ឯកងទ័ពយើងនេះក៏តាំងនៅពីលើខ្យល់ ខាងទ័ពជីវយីនៅពីក្រោមខ្យល់ បើទោះបីជីវយីនឹងឲ្យទាហានមកលបដុតភ្លើង ខ្យល់ក៏ផាត់បក់បោកមិនឲ្យភ្លើងឆេះមកបាន គង់ត្រឡប់ឆេះឆាបតាមចុងខ្យល់បក់ប្រានទៅលើកងទ័ពជីវយីវិញ បើជាទេសកាលខែកក្ដិកខាងខ្មែរ ចុងរដូវភ្លៀងក៏នឹងកើតខ្យល់ព្យុះឈ្មោះសលាត់នមកខ្លះ គ្រានេះកន្ទុងមកដល់ខែបុស្សហើយផុតទេសកាលភ្លៀងហើយយើងក៏មិនត្រូវខ្លាចអ្វី ទីប្រឹក្សាទាំងពួងឮដូច្នោះក៏គ្រវីក្បាលនាំគ្នាគំនាប់ចូចូសរសើរថា តម្រិះប្រាជ្ញាជ្រៅទូលាយឆ្ងាយណាស់ ដឹងការទេសកាលភ្លៀងខ្យល់មិនសល់ត្រង់ណា ។

ចូចូក៏និយាយថា ទាហានរបស់យើងសុទ្ធតែពួកអ្នកលើក្នុងព្រៃ បើមិនបានតម្រិះរិះគិតគំនិតបាំងបង់មកពខ្យល់ឲ្យធ្វើដូច្នេះ ឃើញថាមិនបានឆ្លងកាត់ជ្រោយបណ្ដោយចូលទៅក្នុងស្រុកកាំងតាំងបានឡើយ ។

(នៅមានត)

# ពាក្យវិប្បធម៌

លោក នាង-ហ៊ូ រៀបរៀង

លោក សម-ថាំង ពិនិត្យ

---

## អស់លោកអ្នកអានទាំងឡាយ !

វេលានេះយើងសូមអធិប្បាយអំពីពាក្យ "ក្រសួង, ក្រុម" ដើម្បីបញ្ជាក់ជូនអស់លោកអ្នកអាន ឲ្យបានចាំច្បាស់ នូវព្រំដែនរបស់ពាក្យនីមួយៗ ព្រោះមានជនរួមជាតិយើងខ្លះ ពុំទាន់ច្បាស់លាស់អំពីព្រំដែននៃពាក្យទាំងនោះនៅឡើយ ។

ដើម្បីជាគ្រឿងរំលឹកដល់ព្រំដែនរបស់ពាក្យទាំងនោះ យើងសូមបញ្ជាក់ជាថ្មីម្ដងទៀតថា ពាក្យក្រសួងនេះ គណៈកម្មការវប្បធម៌បានកំណត់ថា ឲ្យប្រើបានតែចំពោះទីស្ដីការរបស់រដ្ឋមន្ត្រី ត្រូវគ្នានឹងពាក្យបារាំងថា Ministère, Département ប៉ុណ្ណោះ ។ ឧទាហរណ៍: ក្រសួងធម្មការ, ក្រសួងមហាផ្ទៃ, ក្រសួងសិក្សាធិការ ។ល។ ឯពាក្យក្រុម ប្រើបានតែចំពោះកន្លែងធ្វើការរដ្ឋការ ដែលទទួលបង្គាប់ពីទៅក្រសួង គឺរដ្ឋមន្ត្រីនីមួយៗ ត្រូវគ្នានឹងពាក្យបារាំងថា Service ។ ឧទាហរណ៍: ក្រុមសុរិយោដី, ក្រុមគយនឹងរដ្ឋាករ ។ល។ សូមកុំប្រើហៅថាក្រសួងសុរិយោដី,

ក្រសួងគយទីនរដ្ឋាករដូចមុន ៗ ទៀតឡើយ ។

ក្នុងពេលនេះ យើងសូមលើកយកពាក្យពីរម៉ាត់គឺពាក្យ មន្ទីរ និង ទី មកអធិប្បាយជូនដូចតទៅ ៖

តាមដែលបានសំគាល់មក ឃើញថាខ្មែរយើងធ្លាប់ប្រើពាក្យទាំងពីរម៉ាត់នេះ ដោយច្រឡំបល់គ្នាតាមតែទំនើងចិត្តចង់ថាចង់សរសេរ គឺថាបើចង់ហៅកន្លែងណាមួយថា "មន្ទីរ" ក៏ថាទៅ ឬចង់ហៅថា "ទី" វិញក៏ថាទៅ ។

ឧទាហរណ៍ដែលបានសំគាល់ឃើញមក : មន្ទីរពេទ្យស្តុក, មន្ទីរក្រឡាបញ្ជី, មន្ទីរទេសចរណ៍, មន្ទីរបាក់ការ, មន្ទីរកាត់សក់, មន្ទីរគ្រូពេទ្យ មន្ទីរជួសជុលគោយន្ត ។ល។ ជួនកាលឃើញមានប្រើថា "ទី" ខ្លះក៏មានដែរ ។

ក្នុងវចនានុក្រមខ្មែរ ពាក្យថា "មន្ទីរ" បានន័យថាគ្រឹហា, ផ្ទះ, វិហារមានទាំងពន្យល់ថា ខ្មែរប្រើទំហៅគ្រឹហាធំ ៗ ដូចយ៉ាងរាជមន្ទីរ, សារមន្ទីរជាដើម ។

ឯពាក្យ "ទី" បានន័យថា កន្លែង, តំបន់ ឧទាហរណ៍ : ទីនេះ, ទីនោះ; មុខងារ, ក្រសួង: ទីសេនាបតី, ស្ដីទីបាលហ្លួង ។ ទីពឹង អ្នកពំនឹង, អ្នកជួយទំនុកបំរុង, ទីស្រឡាញ់ ។ ទីពំនាក់ អ្នកឲ្យពឹងពាក់ ។

បើតាមន័យក្នុងវចនានុក្រមនេះ ទម្លាប់របស់យើងដែលប្រើពាក្យ

"មន្ទីរ" និង "ទី" នេះ ឃើញថានៅប្រឡូកប្រឡល់ពេក ហាក់ដូចជាពាក្យទាំងពីរម៉ាត់នេះប្រើជំនួសគ្នាបាន ។

បើយើងនាំគ្នាក្រឡេកមើលទៅពាក្យបារាំងត្រង់សព្ទស្តីអំពីឈ្មោះរបស់ទីកន្លែងវិញ យើងនឹងឃើញថាគេមានពាក្យច្រើនណាស់ ហើយសុទ្ធតែមានព្រំដែនជាក់លាក់ដាច់ដោយឡែក ៗ ពីគ្នា ។ ឧទាហរណ៍ ដូចជា Ministère, service, office, direction ។ល។

ចំពោះពាក្យទាំងនេះ កាលបើពួកគេនិយាយថា Ministère គេគាប់ស្តាប់បានភ្លាមថា ពិតជាកន្លែងធ្វើការរបស់រដ្ឋមន្ត្រី ឥតភ័ន្តច្រឡំថាជាទីដទៃសោះឡើយ ។ បើពួកថា Service គេស្តាប់បានភ្លាមថា ជាកន្លែងធ្វើការ ដែលទទួលបន្ទាប់ពីទីស្តីការរបស់រដ្ឋមន្ត្រីនីមួយៗ ។ បើពួកថា Office គេស្តាប់បានភ្លាមថា ជាកន្លែងចាត់ការរាជការ ដែលជាប់ទាក់ទងខាងរូបិយវត្ថុ ។ បើពួកថា Direction គេក៏ស្តាប់បានភ្លាមថា ជាទីចាត់ការរបស់ផ្នែកនៃក្រសួងដែលសំខាន់ ៗ នីមួយ ៗ ដែរ ។

ដូចដែលដកបទានលើនេះ បើងាកមកមើលពាក្យរបស់ខ្មែរយើងថា "មន្ទីរ និង ទី" ម្តងទៀត យើងនឹងឃើញថាសព្ទនេះ ខ្មែរទម្លាប់និយាយមកឥតមានលក្ខខណ្ឌជាក់លាក់សោះឡើយ ដូចជាយើងហៅថា "ទីសំណាក់ការ, ទីស្នងការ, ទីចាត់ការ, ទីប្រជុំ, ទីទុកឯកសារ, ទីស្តីការ" ។ល។ ដូន

កាលបែរជានិយាយហៅថា "មន្ទីរសំណាក់ការ, មន្ទីរស្នងការ, មន្ទីរញត្តការ, មន្ទីរប្រជុំ, មន្ទីរទុកឯកសារ, មន្ទីរស្ដីការ, ដូច្នេះទៅវិញក៏ស៊ីមាន ។ ទម្លាប់ប្រើបៀបនេះនាំឲ្យឥតសណ្ដាប់ធ្នាប់ផង ខុសពីពាក្យដែលគណៈកម្មការវប្បធម៌កំណត់ឲ្យប្រើផងទៀត ។

ចុះហេតុដែលចាស់ធ្ងន់នេះមកពីអ្វី ?

ឆ្លើយថា មកពីយើងចេះតែនាំគ្នានិយម និយាយ សរសេរឲ្យខុសបាក់មាត់, ធ្លាប់ដៃ ពីដើមទីមកហើយនោះ ទម្លាប់ខុសបែបនេះ លុះយូរៗទៅអាចមានពលានុភាព ធ្វើឲ្យពាក្យរបស់យើងមានន័យរលូកជាលប្រឡូកប្រឡំឥតលក្ខណ៍ហានព្រំដែនទៀងទាត់ ទៅតាមការនិយម, តាមទម្លាប់របស់យើង កម្រនឹងកែតម្រង់ឲ្យត្រូវបាន ។

ដូច្នេះ ដើម្បីបំបាត់ទម្លាប់ ដែលប្រញាប់ទៅរកផ្លូវខុសនេះ កុំឲ្យមានកម្លាំងក្លាយទៅជាពេកសង់ផ្ទះលើយើងរាល់គ្នាបាននោះ ទើបគណៈកម្មការវប្បធម៌ ចំឆ្លៀតយកឱកាសនេះមកអធិប្បាយ តាមការកត់បំណាំ, ដោយជួយបំបែរលោកអ្នកអាន ទៅរកផ្លូវត្រូវតាំងពីពេលនេះតទៅ ។

នៅទីនេះ យើងគួរលើកយកពាក្យ "មន្ទីរ" និងពាក្យបារាំងថា Office មកផ្ទឹមគ្នាមើល ដើម្បីឲ្យដឹងថាតើ "មន្ទីរ" មានទំហំន័យប៉ុណ្ណា ? ។

ពាក្យមន្ទីរនេះ ដូចយើងបានឃើញរួចមកហើយ បានន័យត្រឹមតែ

ហៅ មុខការ, ត្រឹះស្ថាន ឬអង្គការណាមួយតែប៉ុណ្ណោះ ឥតមានន័យវែងឆ្ងាយទៅទៀតទេ ។

ឯពាក្យ Office នោះមានន័យច្រើនប្រការណាស់

១-កិច្ចការ:, មុខងារ: Office de secrétaire;

២-បន្ទុកស៊ីវិល (មុខងារជាអ្នកឧបត្ថម្ភ): Acheter un office;

៣-ជួនកាលប្រើការជាការិយាល័យ Office de puplicité;

៤-ការជួយយកអាសា, ការធ្វើហិតប្រយោជន៍: Prêter ses bons offices;

៥-ការធ្វើដោយច្បាប់តម្រូវលើ: Déplacement d'office

៦ បើប្រើជាឥត្ថីលិង្គវិញ មានសេចក្តីថា បន្ទប់ដែលគេដាក់គ្រឿងបរិភោគ ។

ឧទាហរណ៍ដែលនាំមកអធិប្បាយប៉ុណ្ណោះនេះ ល្មមបញ្ជាក់ឲ្យដឹងថាពាក្យ Office នេះ មានន័យច្រើនណាស់ តែមិនឃើញន័យត្រង់ណាដែលថាមន្ទីរកាត់សក់ មន្ទីរបោកអ៊ុតនោះសោះឡើយ ។

ពាក្យមន្ទីរនេះគណៈកម្មការវប្បធម៌បានកំណត់ហៅឈ្មោះ អង្គការឬទីចាត់ការដូចតទៅ ៖

១-មន្ទីរសង្គហៈនិស្សិតខ្មែរ: Office des Etudiants cambodgiens;

២-មន្ទីរឥណទានសម្រាប់ប្រជាជន: Office de crédit populaire:

៣-ជាតិមន្ទីរទេសចរណ៍ Office national de Tourisme;

៤-ជាតិមន្ទីរប្តូរប្រាក់ Office national des changes;

៥-មន្ទីរស្រូវ Office de riz;

ប៉ុន្តែចំពោះគ្រឹះស្ថាន ឬ អង្គការធំ ៗ ខ្លះ គំគួរហៅមន្ទីរបានដែរ ដូចជា: មន្ទីរពេទ្យ, ធម្មមន្ទីរ, សារមន្ទីរ, ព្រះរាជមន្ទីរ, សន្និមន្ទីរ; ។ល។

ឯពាក្យដែលយើងធ្លាប់ប្រើដោយច្រឡូកច្រឡំមកហើយនោះ គប្បីកែប្រែឡើងបានត្រឹមត្រូវឡើងវិញដូចយ៉ាង

មន្ទីរប៉ុស្តិ៍ ត្រូវហៅ ការិយាល័យប៉ុស្តិ៍,

មន្ទីរក្រឡាបញ្ជី ត្រូវហៅ ការិយាល័យក្រឡាបញ្ជី,

មន្ទីរខ្មៅដៃ ត្រូវហៅ ក្រុមខ្មៅដៃ,

មន្ទីរបាតការ ត្រូវហៅ ទីបាតការ,

មន្ទីរជួសជុលគោចក្រយានយន្ត ត្រូវហៅ ទី, ផ្ទះ ឬ រោងវិញ ។

ឥឡូវសុំលើកយកពាក្យ "ទី" មកអធិប្បាយវិញ ។ ពាក្យនេះបានជាយើងលើកយកមកបញ្ជាក់ ព្រោះមានគេប្រើលាយឡំគ្នានឹងពាក្យមន្ទីរ ដូចបានរាយរាប់ខាងលើរួចហើយ ដូចជាទម្លាប់ហៅ មន្ទីរបាតការ, មន្ទីរសំណាក់ការ, មន្ទីរស្តីការ ។ល។ ដែលគណៈកម្មការបានកំណត់ឲ្យហៅថា "ទីបាតការ, ទីសំណាក់ការ, ទីស្តីការ" ជាដើម ។

ឯពាក្យទាំងប៉ុន្មានេះ គណៈកម្មការវប្បធម៌ប្រែពាក្យបារាំងថា : Direction, Siège ministère ។ ទីបាតការមានន័យតែមួយចំពោះ

កន្លែងដែលជាស្ថានការរបស់ក្រុមនីមួយៗតែប៉ុណ្ណោះ ។ ចំណែកពាក្យបារាំងថា Direction មានទំហំន័យយ៉ាងវែងច្រើនប្រការដូចតទៅ :

១-ការដើរទៅរកទិសណាមួយដែលជាទិសដៅ;

២-ការដឹកនាំឬត្រួតត្រាលើការ, អង្គការណាមួយ;

៣-ការផ្តោតសំដៅទៅរកគោលបំណងណាមួយ;

៤-មុខការរបស់នាយកការិយាល័យ ឬទីធ្វើការនៃនាយកនោះ;

៥-គ្រឿងចក្រសំរាប់ទាញបង្កូតរថយន្ត

ដូច្នេះ ឃើញថាពាក្យ Direction នេះ មានន័យច្រើនណាស់ មិនដូចខ្មែរយើងដែលបកប្រែមកប្រើ ត្រឹមតែកន្លែងសម្រាប់ធាត់ការរបស់រាជការ ឬរបស់អង្គការណានោះឡើយ ។

សរុបសេចក្តីទៅ ពាក្យមន្ទីរ គណៈកម្មការវប្បធម៌បានផ្តល់ទៅនឹងពាក្យបារាំងថា Offiec តែមានន័យមិនប៉ុនគ្នានឹងបារាំងទេ ។ ឯពាក្យទី មានន័យត្រឹមតែ កន្លែង, តំបន់ប៉ុណ្ណោះ ។

ក្នុងអវសានកថានេះ គណៈកម្មការវប្បធម៌ សូមថ្លែងអំណរគុណចំពោះអស់លោក-អ្នកអានជាទីមេត្រីទាំងឡាយ ហើយសូមជឿសេចក្តីសង្ឃឹមថា តទៅមុខកម្មុខជានឹងមានការបំបាត់កំហុសដូចបានលើកយកជាឧទាហរណ៍ទាំងនេះពុំខាន ។

## ផ្នែកកំណត់ពត៌ប្រវត្តិការណ៍

### ពត៌មានផ្សេងៗរបស់ក្រសួងធម្មការ

### អំពីការតាំងមន្ត្រីសង្ឃ

-បានតាំងលោកគ្រូចៅអធិការ ជ័យ-អ៊ឹង អាយុ៨០ ឆ្នាំ វស្សា៦០ នៅវត្តមុនីកែវសួរគាន ឃុំសួរគង់ ជាព្រះគ្រូបញ្ញាវង្ស ស្រុកកងមាស ខេត្តកំពង់ចាម ។

-បានតាំងភិក្ខុ យា-អ៊ុម អាយុ ៥៥ ឆ្នាំ វស្សា ៣៥ នៅវត្តមុនីកែវសួរគាន ឃុំសួរគង់ ជាព្រះវិន័យធរ ស្រុកកងមាស ខេត្តកំពង់ចាម ។

-បានតាំងភិក្ខុ ស៊ូ-ស៊ុយ អាយុ ៤៨ ឆ្នាំ វស្សា ២៦ នៅវត្តមុនីកែវសួរគាន ឃុំសួរគង់ ជាព្រះសមុហ៍ ស្រុកកងមាស ខេត្តកំពង់ចាម ។

-បានតាំងភិក្ខុ អ៊ុង-ហ៊ុន អាយុ ៤១ ឆ្នាំ វស្សា ២១ នៅវត្តមុនីកែវសួរគាន ឃុំសួរគង់ ជាអនុលេខាធិការអនុគណ ស្រុកកងមាស ខេត្តកំពង់ចាម ។

-បានតាំងភិក្ខុ អ៊ឹម-ចាន់ អាយុ ៣៤ ឆ្នាំ វស្សា ១៤ នៅវត្តត្រពាំងខ្វារ ឃុំភ្នំកុង ជាព្រះវិន័យធរ ស្រុកបន្ទាយមាស ខេត្តកំពត ។

-បានតាំងភិក្ខុ ហ៊ឹម-កែម អាយុ ៦១ ឆ្នាំ វស្សា ៤២ នៅវត្តទង់លាន ជាព្រះសមុហ៍ ស្រុកបន្ទាយមាស ខេត្តកំពត ។

-បានតាំង ភិក្ខុ សឹង-ធុច អាយុ ២២ វស្សា ១ នៅវត្តស្រែកាន់ ឃុំទូកមាស ជាអនុលេខាធិការអនុគណ ស្រុកបន្ទាយមាស ខេត្តកំពត ។

-បានតាំងភិក្ខុ សេក-ប្រង់ អាយុ២៣ ឆ្នាំ វស្សា១ នៅវត្តព្រះព្រហ្មរ័តន៍ ជាអនុលេខាធិការអនុគណ ស្រុកសៀមរាប ខេត្តសៀមរាប ។

---

# វចនានុក្រមសំស្ក្រឹត ខ្មែរ

(តមក)

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិទុះខ នបុ. សេចក្ដីទុក្ខក្រៃលែង ។ — *ទុះខិត* គុ. ដែលមានទុក្ខក្រៃលែង ។ — *ទុះខាន្វិត* គុ. ដែលប្រកបដោយសេចក្ដីទុក្ខក្រៃលែង ។

អតិទុគ៌ម គុ. ដែលទៅបានដោយកម្រក្រៃលែង ។

អតិទុទ៌ិន បុំ. ទុទ៌ិនក្រៃលែង ។

អតិទុព៌ល គុ. ដែលមានកម្លាំងខ្សោយក្រៃលែង; — *តា* ស្ត្រី. ភាពនៃបុគ្គលដែលមានកម្លាំងខ្សោយក្រៃលែង ។

អតិទុម៌នស៑ គុ. ដែលខូចចិត្តក្រៃលែង ។

អតិទុវ៌ហត្វ នបុំ. ភាពនៃ . . . ដែលនាំទៅបានដោយកម្រក្រៃលែង ។

អតិទុវ៌ិមហ គុ. ដែលអាចនាំទៅបានដោយកម្រក្រៃលែង ។

អតិទុវ៌ឫត្ត គុ. ដែលប្រព្រឹត្តទៅបានដោយកម្រក្រៃលែង ។

អតិទុះឝ្រវ គុ. ដែលស្ដាប់បានដោយកម្រក្រៃលែង, ដែលពិបាកស្ដាប់ ។

អតិទុឞ្ករ គុ. ដែលធ្វើបានដោយកម្រក្រៃលែង ។

អតិទុស្តរ គុ. ដែលឆ្លងបានដោយកម្រក្រៃលែង ។

( នៅមានត )